ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍ថ្នាក់ជាតិស្ដីពីលទ្ធផលចុងក្រោយ នៃជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២៣

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ

សហការជាមួយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

និងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ

Food and Agriculture Organization of the United Nations

ខែឧសភា ឆ្នាំ២០២៥

# របាយការណ៍ថ្នាក់ជាតិស្តីពីលទ្ធផលចុងក្រោយ
# នៃជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា
# ឆ្នាំ២០២៣


**វិទ្យាស្ថានជាតិស្ថិតិ**

**ក្រសួងផែនការ**

ខែឧសភា ឆ្នាំ២០២៥

# ព័ត៌មានបន្ថែម

***អ៊ិនធ័រណែត*** http://www.nis.gov.kh គឺជាគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិសម្រាប់ស្ថិតិផ្លូវការ ដែលផលិតដោយវិទ្យាស្ថានជាតិស្ថិតិ និងក្រសួង ស្ថាប័ន/អង្គភាពផ្សេងៗទៀតនៅក្នុងរាជរដ្ឋាភិបាលកម្ពុជា។ គេហទំព័រនេះ ជាកន្លែងចាប់ផ្តើមដ៏ល្អបំផុតសម្រាប់ការទទួលបាននូវទិន្នន័យបឋមពីការបោះពុម្ពថ្មីៗបំផុត និងព័ត៌មានអំពីវិទ្យាស្ថានជាតិស្ថិតិ និងស្ថាប័ន/អង្គភាពស្ថិតិផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល។

***បណ្ណាល័យពិគ្រោះ*** ឯកសារពិគ្រោះផ្សេងៗជាច្រើនអាចរកបាននៅមជ្ឈមណ្ឌលសេវាព័ត៌មានស្ថិតិនៃវិទ្យាស្ថានជាតិស្ថិតិសម្រាប់អ្នកប្រើប្រាស់ទិន្នន័យ។

***សេវាផ្តល់ព័ត៌មាន*** បុគ្គលិករបស់វិទ្យាស្ថានជាតិស្ថិតិបម្រើការនៅមជ្ឈមណ្ឌលសេវាព័ត៌មានស្ថិតិដែលជួយដល់អ្នកប្រើប្រាស់ទិន្នន័យទាំងឡាយក្នុងការដោះស្រាយនូវតម្រូវការទិន្នន័យ។ វិទ្យាស្ថានជាតិស្ថិតិមានឯកសារបោះពុម្ពផ្សាយសម្រាប់លក់ហើយសេវាកម្មជាវអាចត្រូវបានរៀបចំជូន។ ចំពោះសេវាទិន្នន័យពិសេសក៏អាចរកបានផងដែរ ប៉ុន្តែអ្នកប្រើប្រាស់ទិន្នន័យត្រូវបង់ប្រាក់។

***ព័ត៌មានសម្រាប់ទាក់ទង***


មជ្ឈមណ្ឌលសេវាព័ត៌មានស្ថិតិ<br>
វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ<br>
អគារលេខ ៣៨៦ ផ្លូវលេខ៣៦០ សង្កាត់បឹងកេងកង១<br>
ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ<br>
ព្រះរាជាណាចក្រកម្ពុជា។<br>
ទូរស័ព្ទ: (855) 023 726 934<br>
(855) 023 726 624

# មាតិកា

**បុព្វកថា** ........ ៩
**សូចនាករសេខ្វេប** ........ ១១
**ពាក្យសរសេរកាត់** ........ ១៦
**ជំពូកទី១** ........ ១៧
**ទំហំ ទិសាលភាព និងការជ្រើសរើសសំណាកគំរូ** ........ ១៧
១.១- សេចក្តីផ្តើម ........ ១៧
១.២- គោលបំណង ........ ១៧
១.៣- វិធីសាស្រ្ត ........ ១៨
១.៤- វិសាលភាពជំរឿន ........ ១៩
១.៥- ទីតាំងភូមិសាស្រ្តគ្របដណ្តប់ ........ ២០
១.៦- កាលបរិច្ឆេទយោងជំរឿន ........ ២០
១.៧- នីតិវិធីជំរឿន ........ ២១
១.៨- ការផ្សព្វផ្សាយជំរឿន ........ ២២
១.៩- ដំណើរការចុះប្រមូលទិន្នន័យ ........ ២២
១.១០- ការកែច្នៃទិន្នន័យ ........ ២៣
**ជំពូកទី២** ........ ២៥
**ភូមិសាស្រ្ត និង ហេដ្ឋារចនាសម្ព័ន្ធនៃប្រទេសកម្ពុជា** ........ ២៥
២.១- សណ្ឋានដី ........ ២៥
២.២- ប្រភេទដី ........ ២៦
២.៣- តំបន់ងាយរងសម្ពាធទាប ........ ២៦
២.៤- គ្រោះហានិភ័យ និង គ្រោះមហន្តរាយ ........ ២៨
២.៥- សកម្មភាពសេដ្ឋកិច្ច ........ ២៩
២.៦- ប្រព័ន្ធដាំដុះដំណាំ ........ ៣០
២.៧- ការកែច្នៃកសិផល និង ហេដ្ឋារចនាសម្ព័ន្ធជនបទ ........ ៣១
២.៨- មធ្យោបាយដឹកជញ្ជូន ........ ៣២
២.៩- ផ្លូវជាតិ និង ទីផ្សារ ........ ៣៣
២.១០- មធ្យោបាយទំនាក់ទំនង ........ ៣៤
២.១១- សេវាសុខាភិបាល និង ការអប់រំ ........ ៣៥
២.១២- ប្រភពទឹកប្រើប្រាស់ ........ ៣៧
២.១៣- អង្គការ/សមាគម ........ ៣៨

**ជំពូកទី៣** ........................................ **៤១**
**ការកាន់កាប់កសិកម្ម និង ការកាន់កាប់ដី** ........................................ **៤១**
៣.១- គ្រួសារកាន់កាប់កសិកម្ម ........................................ ៤១
៣.២- ទំហំនៃការកាន់កាប់កសិកម្ម ........................................ ៤៣
៣.៣- គ្រួសារកាន់កាប់កសិកម្ម ........................................ ៤៦
៣.៤- ការប្រើប្រាស់ក្បាលដីជាចម្បង ........................................ ៤៧
៣.៥- សិទ្ធិនៃការកាន់កាប់ក្បាលដី ........................................ ៤៩
៣.៦- ការប្រើប្រាស់ដីជុំវិញលំនៅឋានសម្រាប់ធ្វើសកម្មភាពកសិកម្ម ........................................ ៥១
៣.៧- ការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ ........................................ ៥២
**ជំពូកទី៤** ........................................ **៥៥**
**ការដាំដុះដំណាំ** ........................................ **៥៥**
៤.១- ដំណាំធញ្ញជាតិ និង ធញ្ញជាតិយកគ្រាប់ ........................................ ៥៦
៤.២- ដំណាំយកឫស និង មើម ........................................ ៦២
៤.៣- រុក្ខជាតិពពួកសណ្តែក (គ្រាប់ធញ្ញជាតិ) ........................................ ៦៣
៤.៤- ដំណាំធញ្ញជាតិប្រេង ........................................ ៦៤
៤.៥- គ្រឿងទេស គ្រឿងក្រអូប និងរុក្ខជាតិឱសថ ........................................ ៦៥
៤.៦- ដំណាំឧស្សាហកម្ម ........................................ ៦៧
៤.៧- ដំណាំយកសរសៃ ........................................ ៦៩
៤.៨- ដំណាំបន្លែ ........................................ ៦៩
៤.៩- ដំណាំរយៈពេលវែង ........................................ ៧៥
៤.១០- ដំណាំក្រូច ........................................ ៧៥
៤.១១- ដំណាំហូបផ្លែ ........................................ ៧៧
៤.១១.១- ដំណាំស្វាយ ........................................ ៧៨
៤.១១.២- ដំណាំចេក ........................................ ៧៩
៤.១១.៣- ដំណាំខ្នុរ ........................................ ៨០
៤.១២- ដំណាំប្រភេទគ្រាប់អាចបរិភោគបាន (ស្វាយចន្ទី) ........................................ ៨១
៤.១៣- ដំណាំយកប្រេង (ដូង) ........................................ ៨២
៤.១៤- ដំណាំសម្រាប់គ្រឿងទេស ........................................ ៨៣
៤.១៥- ដំណាំកៅស៊ូ ........................................ ៨៤
៤.១៦- ដំណាំមិនមែនអាហារ ........................................ ៨៥
**ជំពូកទី៥** ........................................ **៨៦**
**ធាតុចូល និង សេវាកម្មកសិកម្ម** ........................................ **៨៦**
៥.១- ការប្រើប្រាស់ឧបករណ៍បរិក្ខា និង គ្រឿងម៉ាស៊ីនកសិកម្ម ........................................ ៨៦

៥.២- ការប្រើប្រាស់ប្រព័ន្ធស្រោចស្រព ........ ៨៧
៥.៣- ការប្រើប្រាស់ជី ........ ៨៩
៥.៤- ការប្រើប្រាស់ថ្នាំកសិកម្ម ........ ៩១
៥.៥- ភាពអាចទទួលបានឥណទាន និង ប្រាក់កម្ចី ........ ៩៣
៥.៦- ទីផ្សារលក់ផលិតផលកសិកម្ម ........ ៩៤
៥.៧- ការចំណាយ នៃការកាន់កាប់ ........ ៩៥
៥.៧.១- ផលិតកម្មដំណាំ ........ ៩៥
៥.៧.២- ផលិតកម្មបសុសត្វ និង បសុបក្សី ........ ៩៦
**ជំពូកទី៦ ........ ៩៨**
**ការចិញ្ចឹមបសុសត្វ និង បសុបក្សី ........ ៩៨**
៦.១- បសុសត្វ និង បសុបក្សី ........ ៩៨
៦.២- គោ ក្របី និងជ្រូក ........ ១០៣
៦.២.១- បសុសត្វធំ ........ ១០៣
៦.២.២ បសុសត្វតូច (ជ្រូក) ........ ១០៥
៦.២.៣ បម្រែបម្រួលបសុសត្វ ........ ១០៧
៦.៣- សត្វមាន់ និង សត្វទា ........ ១០៨
៦.៣.១- គោលបំណងចម្បងក្នុងការចិញ្ចឹមបសុបក្សី ........ ១០៩
៦.៣.២- បម្រែបម្រួលបសុបក្សី ........ ១១០
៦.៣.៣- បសុបក្សីងាប់ដោយសារជំងឺ ........ ១១១
**ជំពូកទី៧ ........ ១១៣**
**សកម្មភាពសេដ្ឋកិច្ចបន្ថែមនៃគ្រួសារកសិកម្ម ........ ១១៣**
៧.១- សកម្មភាពទាក់ទងនឹងព្រៃឈើ ........ ១១៣
៧.២- សកម្មភាពសេដ្ឋកិច្ចផ្សេងទៀតរបស់សមាជិកគ្រួសារកសិកម្ម ........ ១១៤
**ជំពូកទី៨ ........ ១១៥**
**គ្រួសារកសិកម្ម និង ចំនួនប្រជាជន ........ ១១៥**
៨.១- គ្រួសារកសិកម្ម ........ ១១៥
៨.២- ក្រុមអាយុប្រជាជន ........ ១១៧
៨.៣- អត្រាអ្នកនៅក្នុងបន្ទុកគ្រួសារកសិកម្ម ........ ១១៨
៨.៤- ទំនាក់ទំនងមេគ្រួសារ ........ ១១៩
៨.៥- ការអប់រំ ........ ១២០
៨.៦- ស្ថានភាពអាពាហ៍ពិពាហ៍ ........ ១២១
**ឧបសម្ព័ន្ធ ........ ១២៣**
**វិសាលភាព វិធីសាស្ត្រ និងគុណភាពនៃទិន្នន័យ ........ ១២៣**

៩.១- សេចក្ដីផ្ដើម ........ ១២៣
៩.២- គោលបំណង ........ ១២៤
៩.៣- វិសាលភាពការធ្វើជំរឿន ........ ១២៤
៩.៤- ការគ្របដណ្ដប់ទីតាំងភូមិសាស្ត្រ ........ ១២៦
៩.៥- ពេលវេលាជំរឿន និងរយៈពេលយោង ........ ១២៦
៩.៦- នីតិវិធីនៃការធ្វើជំរឿន ........ ១២៧
៩.៧- ផែនការផ្សព្វផ្សាយ ........ ១២៨
៩.៨- ដំណើរការចុះប្រមូលទិន្នន័យ ........ ១២៨
៩.៩- ដំណើរការកែច្នៃទិន្នន័យ ........ ១៣១
៩.១០- ការបំប្លែងសម្រាប់ដំណាំរយៈពេលវែង ........ ១៣២
៩.១១- ភាពត្រឹមត្រូវ និងការជឿជាក់នៃទិន្នន័យកសិកម្មកម្ពុជា ........ ១៣៥
៩.១១.១- ការផ្ទៀងផ្ទាត់ទិន្នន័យពីខាងក្រៅ ........ ១៣៥
៩.១១.២- ទស្សនទាន និងនិយមន័យ ........ ១៣៧
៩.១២- ប្រភពនៃកំហុស ........ ១៣៧
៩.១៣- កំហុសមិនមែនសំណាកគំរូ ........ ១៣៨
៩.១៣.១- នៅក្រោមការគ្របដណ្ដប់ ........ ១៣៨
៩.១៣.២- លើសពីការគ្របដណ្ដប់ និងការចុះបញ្ជីច្រើនដង ........ ១៣៨
៩.១៣.៣- កំហុសក្នុងការវាស់វែង ........ ១៣៩
៩.១៤- កំហុសមិនឆ្លើយតប ........ ១៣៩
៩.១៥- ការវាយតម្លៃជារួមនៃទិន្នន័យជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣ ........ ១៤០
៩.១៦- តារាងទិន្នន័យស្ថិតិសំខាន់ៗ ........ ១៤០

# បុព្វកថា

របាយការណ៍ថ្នាក់ជាតិស្ដីពីលទ្ធផលចុងក្រោយនៃជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ គឺជាលទ្ធផលជំរឿនកសិកម្មជាតិលើកទីពីរ បន្ទាប់ពីជំរឿនកសិកម្មនៅលើកដំបូងដែលបានធ្វើនៅក្នុងឆ្នាំ២០១៣។ របាយការណ៍នេះ ផ្ដល់ទិន្នន័យស្ថិតិសំខាន់ៗអំពីគ្រួសារកាន់កាប់កសិកម្ម និងជាប្រភពទិន្នន័យយ៉ាងសំខាន់ សម្រាប់ការវាយតម្លៃផលិតភាពកសិកម្មនៅកម្ពុជា និងបង្ហាញស្ថានភាពស្ដីពីផ្នែកដំណាំ ការចិញ្ចឹមសត្វ ការធ្វើវារីវប្បកម្ម ការនេសាទ និងសកម្មភាពពាក់ព័ន្ធដទៃទៀត ក្នុងការឆ្លុះបញ្ចាំងអំពីស្ថានភាពកសិកម្ម បរិស្ថាន សេដ្ឋកិច្ច សង្គម និងសន្តិសុខស្បៀងរបស់គ្រួសារកសិកម្មកម្ពុជា។ លើសពីនេះទិន្នន័យជំរឿនកសិកម្មកម្ពុជា ជាធាតុចូលដ៏សំខាន់បំផុត សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០២៣-២០២៨ ការកាត់បន្ថយភាពក្រីក្រ ការវាស់វែងកំណើនសេដ្ឋកិច្ចជាតិ និងកម្មវិធីអភិវឌ្ឍន៍នានា។

របាយការណ៍ជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣ នឹងផ្ដល់ជូនដល់គ្រប់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ អង្គការជាតិ និងអន្តរជាតិ ស្ថាប័នស្រាវជ្រាវ វិស័យឯកជន និងសាធារណជនទូទៅអាចប្រើប្រាស់របកគំហើញទាំងនេះតាមតម្រូវការ។ ទិន្នន័យជំរឿនកសិកម្មកម្ពុជា នឹងបម្រើជាមូលដ្ឋានសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន ដើម្បីសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ដែលចាត់ទុកការអភិវឌ្ឍវិស័យកសិកម្មជាសសរស្ដម្ភស្នូលនៃយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ និងដៃគូអភិវឌ្ឍនានាដែលបានជួយគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះថ្នាក់ដឹកនាំ អ្នកគ្រប់គ្រង សមាជិក សមាជិកានៃគណៈកម្មាធិការជាតិជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ គណៈកម្មការបច្ចេកទេសជំរឿនកសិកម្ម គណៈកម្មការឃោសនាជំរឿនកសិកម្ម គណៈកម្មការជំរឿនកសិកម្មរាជធានី ខេត្ត និងមន្ត្រីក្រុមការងារបច្ចេកទេសជំរឿនកសិកម្ម មន្ត្រីត្រួតពិនិត្យ មន្ត្រីសម្ភាសន៍របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដែលបានចូលរួមខិតខំប្រឹងប្រែងបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់ក្នុងដំណើរការអនុវត្តការងារជំរឿនកសិកម្មឆ្នាំ២០២៣ និងសូមអរគុណចំពោះប្រជាពលរដ្ឋដែលបានចូលរួមសម្ភាសន៍ផ្ដល់ចម្លើយធ្វើឱ្យជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ ឈានសម្រេចបានជោគជ័យ៕

**រដ្ឋមន្ត្រីក្រសួងផែនការ**

**ប៊ិន ត្រាឈៃ**

# សេចក្តីសង្ខេប

ជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ (CAC 2023) បានប្រើប្រាស់នូវកម្រងបញ្ជីសំណួរចំនួនបួនគឺ (១) **តារាងសំណួរមេភូមិ** ត្រូវបានប្រើប្រាស់សម្រាប់ធ្វើការសម្ភាសដោយផ្ទាល់ជាមួយមេភូមិទាំងអស់នៅទូទាំងរាជធានីខេត្តនៃព្រះរាជាណាចក្រកម្ពុជា (២) **តារាងសំណួរចុះបញ្ជីគ្រួសារ** ត្រូវបានប្រើប្រាស់សម្រាប់ធ្វើការចុះបញ្ជីគ្រួសារទាំងអស់ដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា (៣) **តារាងសំណួរព័ត៌មានមូលដ្ឋានគ្រួសារកសិកម្ម** ត្រូវបានប្រើប្រាស់សម្រាប់ការសម្ភាសប្រមូលព័ត៌មានលម្អិតពីគ្រួសារកាន់កាប់កសិកម្មទាំងអស់បន្ទាប់ពីធ្វើការចុះបញ្ជីគ្រួសាររួច និង(៤) **តារាងសំណួរសហគ្រាសកសិកម្មខ្នាតធំ** ត្រូវបានប្រើប្រាស់សម្រាប់ការសម្ភាសទៅលើការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ (មិនមែនជាគ្រួសារកាន់កាប់កសិកម្ម)។

គ្រប់គ្រួសារដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងអស់ គឺត្រូវបានជ្រើសរើសយកមកសម្ភាស លើកលែងតែខណ្ឌចំនួនបួននៃរាជធានីភ្នំពេញ ដែលត្រូវបានដឹងថាជាតំបន់ទីប្រជុំជន និងមានចំនួនគ្រួសារកសិកម្មតិចជាង ៥គ្រួសារ នៅក្នុងភូមិទាំងនោះ (យោងតាមជំរឿនទូទៅប្រជាជនកម្ពុជាឆ្នាំ២០១៩)។ ជំរឿនកសិកម្មនេះក៏ត្រូវបានសម្ភាសផងដែរទៅលើសហគ្រាសកសិកម្មខ្នាតធំ រួមមានក្រុមហ៊ុនសាជីវកម្ម សហករណ៍ ដីសម្បទានសេដ្ឋកិច្ច ស្ថាប័នរដ្ឋាភិបាល និងស្ថាប័នឯកជនដែលធ្វើកសិកម្មមិនមែនជាលក្ខណៈគ្រួសារ។

ព្រះរាជាណាចក្រកម្ពុជា មានអង្គភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ដូចជាភូមិ ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ និងរាជធានី ខេត្ត។ ភូមិ ជាកម្រិតអង្គភាពរដ្ឋបាលតូចបំផុតដែលមានសរុបចំនួន ១៤ ២០១ភូមិ បន្ទាប់មកគឺ ឃុំ/សង្កាត់ មានចំនួន ១ ៦៣៣ បន្ទាប់ទៀតគឺ ក្រុង/ស្រុក/ខណ្ឌ មានចំនួន ២០៦ និងចុងក្រោយ គឺរាជធានី ខេត្ត ដែលមានចំនួន ២៥ រាជធានី ខេត្ត។ ទិន្នន័យសំខាន់ៗដែលទទួលបានពីជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ ត្រូវបានបង្ហាញដូចខាងក្រោម៖

**តារាងទី១.១ ហេដ្ឋារចនាសម្ព័ន្ធនៃប្រទេសកម្ពុជា (បានពីការសម្ភាសប្រធានភូមិ)**

| | |
|---|---|
| ភាគរយនៃភូមិដែលបានដាំដំណាំតែម្តងក្នុងមួយឆ្នាំ | ៦៣,៣ % |
| ភាគរយនៃភូមិដែលមានរោងម៉ាស៊ីនកិនស្រូវ និង កែច្នៃកសិឧស្សាហកម្ម | ៥៧,៥ % |
| ភាគរយនៃភូមិដែលបានប្រើប្រាស់ទូរសព្ទដៃ | ៩២,៣ % |
| ភាគរយនៃភូមិដែលមានមណ្ឌលសុខភាព ឬគ្លីនិកសុខភាព ឬមន្ទីរពេទ្យ | ២៩,៧ % |
| ភាគរយនៃភូមិដែលប្រើប្រាស់ទឹកទុយោទឹកស្អាត និងទឹកអណ្តូង | ៨៨,៦ % |

| | |
|---|---|
| ភាគរយនៃភូមិដែលមានការប្រើប្រាស់ផ្លូវជាតិដែលនៅជិតបំផុត | ៦១,៤ % |
| ភាគរយនៃភូមិដែលរងផលប៉ះពាល់ពីគ្រោះទឹកជំនន់ ក្នុងរយៈពេលប្រាំឆ្នាំមុនពេលធ្វើជំរឿន | ៣៩,២ % |
| ភាគរយនៃភូមិដែលរងផលប៉ះពាល់ពីគ្រោះរាំងស្ងួត និងអសន្តិសុខស្បៀងអាហារ ក្នុងរយៈពេលប្រាំឆ្នាំមុនពេលធ្វើជំរឿន | ៤៧,៦ % |

**តារាងទី១.២ ការកាន់កាប់កសិកម្ម និង ការកាន់កាប់ដី**

| | |
|---|---|
| គ្រួសារដែលបានចុះបញ្ជី (២៥ រាជធានី ខេត្ត និងភូមិនៅរាជធានីភ្នំពេញ) | ៣,៤ លាន |
| គ្រួសារកាន់កាប់កសិកម្ម (បានដាំដុះដំណាំលើផ្ទៃដីយ៉ាងតិច ០,០៣ ហិកតា និង/ឬយ៉ាងតិចមានបសុសត្វប្រភេទធំចំនួន ២ក្បាល និង/ឬបសុសត្វប្រភេទតូចចំនួន ៣ក្បាល និង/ឬមានបសុបក្សីចំនួន ២៥ក្បាល) | ១,៨ លាន |
| ផ្ទៃដីសរុបនៃគ្រួសារកាន់កាប់កសិកម្មទាំងអស់ (រួមទាំងផ្ទៃដីជុំវិញលំនៅឋាន) | ៣,២ លានហ.ត. |
| ផ្ទៃដីសរុបនៃការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំទាំងអស់ ២៩១ | ០,៦ លាន ហ.ត. |
| គ្រួសារដែលធ្វើសកម្មភាពកសិកម្មលើក្បាលដី | ១,៧ លាន |
| គ្រួសារដែលធ្វើសកម្មភាពកសិកម្មលើដីជុំវិញលំនៅឋាន | ១៥៤ ១០២ |
| ភាគរយនៃគ្រួសារកាន់កាប់កសិកម្ម ក្នុងចំណោមគ្រួសារសរុបដែលបានចុះបញ្ជី | ៥៤,២ % |
| ភាគរយនៃគ្រួសារដែលបានធ្វើកសិកម្មលើដីជុំវិញលំនៅឋាន ក្នុងចំណោមគ្រួសារសរុបដែលបានចុះបញ្ជី | ៨,៣ % |
| ភាគរយនៃគ្រួសារដែលបានដាំដុះដំណាំលើដីកសិកម្ម ក្នុងចំណោមគ្រួសារកសិកម្មសរុប | ៩៣,៩ % |
| ក្បាលដីជាមធ្យមក្នុងមួយគ្រួសារកាន់កាប់កសិកម្ម រួមជាមួយដីជុំវិញលំនៅឋាន | ២,០ ហ.ត. |
| ផ្ទៃដីជាមធ្យមក្នុងមួយក្បាលដីនៃគ្រួសារកាន់កាប់កសិកម្ម រួមជាមួយដីកសិកម្មជុំវិញលំនៅឋាន | ០,៩ ហ.ត. |
| ទំហំក្បាលដីជាមធ្យមក្នុងមួយគ្រួសារកាន់កាប់ក្បាលដីកសិកម្ម (មិនរាប់បញ្ចូលដីកសិកម្មជុំវិញលំនៅឋាន) | ១,៨ ហ.ត. |
| ទំហំក្បាលដីជាមធ្យមក្នុងមួយគ្រួសារកាន់កាប់ក្បាលដីកសិកម្ម (រួមបញ្ចូលដី កសិកម្មជុំវិញលំនៅឋាន) | ១,៩ ហ.ត. |

| | |
|---|---|
| ផ្ទៃដីជាមធ្យមនៃគ្រួសារកាន់កាប់ដីកសិកម្មទាំងអស់ (រួមទាំងដីកសិកម្មនៅជុំវិញលំនៅឋាន) | ១,៧ ហ.ត. |
| ភាគរយនៃគ្រួសារកាន់កាប់កសិកម្មដែលមានផ្ទៃដីតិចជាង ១ហិកតា ក្នុងចំណោមគ្រួសារកាន់កាប់កសិកម្មដែលមានដីដាច់ដោយឡែក (ក្បាលដី) | ៤៣,៦ % |
| ភាគរយនៃគ្រួសារកាន់កាប់កសិកម្មដែលមានផ្ទៃដីទំហំ ២០ហិកតា ឬច្រើនជាងនេះ ក្នុងចំណោមការកាន់កាប់គ្រួសារកសិកម្មដែលមានដីដាច់ដោយឡែក (ក្បាលដី) | ០,៤ % |

**តារាងទី១.៣ ការដាំដុះដំណាំ**

| | |
|---|---|
| ភាគរយនៃផ្ទៃដីសរុបដែលបានដាំដំណាំធញ្ញជាតិ និងធញ្ញជាតិយកគ្រាប់ ក្នុងចំណោមផ្ទៃដីសរុបទាំងអស់របស់គ្រួសារការកាន់កាប់គ្រួសារកសិកម្ម | ៦៩,៤ % |
| ភាគរយនៃផ្ទៃដីសរុបដែលបានដាំដំណាំស្រូវ ក្នុងចំណោមផ្ទៃដីសរុបទាំងអស់របស់គ្រួសារការកាន់កាប់គ្រួសារកសិកម្ម | ៦៦,៦ % |
| ភាគរយនៃផ្ទៃដីសរុបដែលបានដាំដំណាំស្រូវធម្មតា ក្នុងចំណោមផ្ទៃដីដាំដំណាំធញ្ញជាតិ និងធញ្ញជាតិយកគ្រាប់សរុប | ៧៤,៧ % |
| ភាគរយនៃផ្ទៃដីសរុបដែលបានដាំដំណាំដំឡូងមី ក្នុងចំណោមផ្ទៃដីសរុបរបស់គ្រួសារការកាន់កាប់កសិកម្ម | ១៣,២ % |
| ភាគរយនៃផ្ទៃដីសរុបដែលបានដាំដំណាំដំឡូងមី ក្នុងចំណោមផ្ទៃដីដាំដំណាំយកមើមសរុប | ៩៨,៨ % |
| ភាគរយនៃផ្ទៃដីសរុបដែលបានដាំដំណាំយកប្រេង ក្នុងចំណោមផ្ទៃដីសរុបរបស់គ្រួសារការកាន់កាប់កសិកម្ម | ០,២ % |
| ភាគរយនៃផ្ទៃដីសរុបដែលបានដាំដំណាំបន្លែ ក្នុងចំណោមផ្ទៃដីសរុបរបស់គ្រួសារការកាន់កាប់កសិកម្ម | ០,៤ % |
| ភាគរយនៃគ្រួសារកាន់កាប់កសិកម្មដែលបានប្រើប្រាស់ប្រព័ន្ធស្រោចស្រព | ២០,៦ % |
| ភាគរយនៃផ្ទៃដីបានស្រោចស្រព ក្នុងចំណោមផ្ទៃដីរបស់គ្រួសារកាន់កាប់កសិកម្មសរុប | ១៤,៦ % |
| ភាគរយនៃគ្រួសារកាន់កាប់កសិកម្មដែលបានប្រើប្រាស់ជីគីមី | ៧៧,៩ % |

| | |
|---|---|
| ភាគរយនៃគ្រួសារកាន់កាប់កសិកម្មដែលបានប្រើប្រាស់ជីសរីរាង្គ | ៣៧,៦ % |
| ភាគរយនៃគ្រួសារកាន់កាប់កសិកម្មដែលបានប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃនិងថ្នាំសម្លាប់ផ្សិត | ១២,៦ % |

## តារាងទី១.៤ ការចិញ្ចឹមបសុសត្វ និង បសុបក្សី

| | |
|---|---|
| ភាគរយនៃគ្រួសារកសិកម្មដែលបានរក្សាទុកនិងចិញ្ចឹមបសុសត្វ និង/ឬ បសុបក្សី | ៥៨,៦ % |
| ភាគរយនៃគ្រួសារកសិកម្មដែលបានរក្សាទុកនិងចិញ្ចឹមបសុសត្វប្រភេទធំ | ៣៧,៣ % |
| ភាគរយនៃគ្រួសារកសិកម្មដែលបានរក្សាទុកនិងចិញ្ចឹមបសុសត្វប្រភេទតូច | ៥,១ % |
| ភាគរយនៃគ្រួសារកសិកម្មដែលបានរក្សាទុកនិងចិញ្ចឹមបសុបក្សី | ៣៩,៣ % |
| ភាគរយនៃគ្រួសារកសិកម្មដែលបានរក្សាទុកនិងចិញ្ចឹមសត្វជ្រូក ក្នុងចំណោមគ្រួសារចិញ្ចឹមបសុសត្វប្រភេទតូចសរុប | ៩៧,៧ % |
| ភាគរយនៃគ្រួសារកសិកម្មដែលបានរក្សាទុកនិងចិញ្ចឹមបសុសត្វប្រភេទធំដែលមានពី ២ ទៅ ៩ក្បាល ក្នុងចំណោមគ្រួសារចិញ្ចឹមបសុសត្វប្រភេទធំសរុប | ៨៣,៣ % |
| ភាគរយនៃគ្រួសារកសិកម្មដែលបានរក្សាទុកនិងចិញ្ចឹមបសុបក្សី ដែលមានពី ២៥ ទៅ ៤៩៩ក្បាល ក្នុងចំណោមគ្រួសារចិញ្ចឹមបសុបក្សីសរុប | ៤៣,២ % |
| ភាគរយនៃសត្វគោដែលបានលក់រស់ ក្នុងចំណោមសត្វគោសរុបដែលបានចិញ្ចឹមដោយគ្រួសារ | ៧២,៦ % |
| ភាគរយនៃសត្វក្របីដែលបានលក់រស់ ក្នុងចំណោមសត្វក្របីសរុបដែលបានចិញ្ចឹមដោយគ្រួសារ | ៦៣,៧ % |
| ភាគរយនៃសត្វជ្រូកដែលបានលក់រស់ ក្នុងចំណោមសត្វជ្រូកសរុបដែលបានចិញ្ចឹមដោយគ្រួសារ | ៨៣,៨ % |
| ភាគរយនៃសត្វមាន់ដែលបានលក់រស់ ក្នុងចំណោមសត្វមាន់សរុបដែលបានចិញ្ចឹមដោយគ្រួសារ | ១៤,៧ % |

## តារាងទី១.៥ សកម្មភាពសេដ្ឋកិច្ចបន្ថែមនៃគ្រួសារកសិកម្ម

| | |
|---|---|
| ភាគរយនៃគ្រួសារកសិកម្មដែលបានចូលរួមក្នុងសកម្មភាពទាក់ទងនឹងព្រៃឈើ ក្នុងចំណោមគ្រួសារកាន់កាប់កសិកម្មសរុប | ១៩,៥ % |
| ភាគរយនៃគ្រួសារកសិកម្មដែលបានចូលរួមក្នុងសកម្មភាពទាក់ទងនឹង | ៩០,៨ % |

ព្រៃឈើ ក្នុងគោលបំណងរកអុសនិង/ឬប្រមូលផលឫស្សី ក្នុងចំណោមគ្រួសារកសិកម្មបានចូលរួមក្នុងសកម្មភាពទាក់ទងនឹងព្រៃឈើសរុប

**តារាងទី១.៦ ចំនួនគ្រួសារកសិកម្ម និង ប្រជាជន**

| | |
|---|---|
| ចំនួនប្រជាជនសរុបនៃគ្រួសារកាន់កាប់កសិកម្ម | ៧,៣ លាន |
| អត្រាភេទ (ចំនួនបុរស ក្នុងចំណោមស្ត្រី ១០០នាក់) នៃសមាជិកគ្រួសារកាន់កាប់កសិកម្មសរុប | ៩៨,៤ |
| ភាគរយបុរសជាមេគ្រួសារនៃគ្រួសារកាន់កាប់កសិកម្ម | ៨៤,៤ % |
| ភាគរយស្ត្រីជាមេគ្រួសារនៃគ្រួសារកាន់កាប់កសិកម្ម | ១៥,៦ % |
| អាយុមធ្យមរបស់ប្រជាជននៃគ្រួសារកាន់កាប់កសិកម្ម | ៣១,៨ ឆ្នាំ |
| ភាគរយនៃសមាជិកគ្រួសារនៅក្នុងបន្ទុក (អ្នកដែលមានតិចជាង១៥ឆ្នាំ និងអ្នកដែលមានអាយុ៦០ឆ្នាំឡើងទៅ) នៃចំនួនប្រជាជនសរុប | ៤៩ % |
| ភាគរយនៃការរៀបការរបស់សមាជិកគ្រួសារកាន់កាប់កសិកម្មសរុប | ៦៣,៦ % |

# ពាក្យសរសេរកាត់

ជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា (CAC)
អង្កេតកសិកម្មកម្ពុជា (CAS)
អង្កេតចន្លោះជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា (CIAS)
អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES)
នាយកដ្ឋានផែនការនិងស្ថិតិ (DPS)
នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល (DAHP)
អង្កេតប្រជាសាស្ត្រសុខភាពកម្ពុជា (DHS)
អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAO)
អង្គការស្ថិតិស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAOSTAT)
ផលិតផលក្នុងស្រុកសរុប (GDP)
អង្កេតចន្លោះជំរឿនប្រជាជនទូទៅនៅព្រះរាជាណាចក្រកម្ពុជា (CIPS)
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF)
ក្រសួងផែនការ (MOP)
គណៈកម្មាធិការជាតិជំរឿនកសិកម្ម (NCCA)
វិទ្យាស្ថានជាតិស្ថិតិ (NIS)
រាជរដ្ឋាភិបាលកម្ពុជា (RGC)
គណៈកម្មការបច្ចេកទេសជំរឿនកសិកម្ម (TCCA)
កម្មវិធីជំរឿនកសិកម្មសកលលោក (WCA)

# ជំពូកទី១
# ទំហំ ទំហំ វិសាលភាព និងវិធីសាស្ត្រជំរឿន

## ១.១- សេចក្តីផ្តើម

ជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ គឺផ្តោតសំខាន់ទៅលើការប្រមូលនិងចងក្រងស្ថិតិពីការដាំដុះដំណាំ ការចិញ្ចឹមបសុសត្វ និងបសុបក្សី និងសកម្មភាពវារីវប្បកម្ម។ ព័ត៌មានដែលទទួលបានពីជំរឿននេះនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំផែនការការកសាងគោលនយោបាយ និងកម្មវិធីសម្រាប់អភិវឌ្ឍន៍និងការលើកកម្ពស់វិស័យកសិកម្មនៅរបស់រាជរដ្ឋាភិបាលកម្ពុជា។ ជំរឿនកសិកម្មនៅឆ្នាំ២០២៣ គឺជាការធ្វើជំរឿនកសិកម្មនៅលើកទីពីរនៅព្រះរាជាណាចក្រកម្ពុជា។

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគឺជាស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលមានភារកិច្ចទទួលខុសត្រូវក្នុងការធ្វើជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣។ វិទ្យាស្ថានជាតិស្ថិតិ ត្រូវបានប្រគល់សិទ្ធិឱ្យធ្វើជំរឿនចំណែកឯក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាអ្នកប្រើប្រាស់ទិន្នន័យចម្បងដែលផលិតបានពីការធ្វើជំរឿនកសិកម្មនេះ។

## ១.២- គោលបំណង

គោលបំណងចម្បងនៃការធ្វើជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ គឺដើម្បីផ្តល់នូវបច្ចុប្បន្នភាពទិន្នន័យនៃស្ថានភាពកសិកម្មគ្រប់ប្រភេទនៅព្រះរាជាណាចក្រកម្ពុជាដែលនឹងត្រូវបានប្រើប្រាស់ដោយអ្នករៀបចំផែនការនិងអ្នកបង្កើតគោលនយោបាយ។ ជាពិសេសទិន្នន័យជំរឿននេះនឹងផ្តល់សារប្រយោជន៍ជាច្រើនផ្សេងទៀត ដូចជា៖

- ផ្តល់ទិន្នន័យកម្រិតមូលដ្ឋានទាបបំផុតនៃថ្នាក់ក្រោមជាតិក្នុងប្រទេសកម្ពុជា
- ផ្តល់ទិន្នន័យបច្ចុប្បន្នភាពពីរចនាសម្ព័ន្ធនៃការកាន់កាប់កសិកម្ម ការប្រើប្រាស់ដីការដាំដំណាំ ការចិញ្ចឹមបសុសត្វ បសុបក្សី និងវារីវប្បកម្មក្នុងប្រទេសកម្ពុជា
- ផ្តល់បញ្ជីមេសម្រាប់ការជ្រើសរើសសំណាកគំរូនៃអង្កេតកសិកម្ម។

ទោះបីជាសំណុំទិន្នន័យមានបង្ហាញនៅកម្រិតថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់រាជធានីខេត្ត ដែលមាននៅក្នុងតារាងស្ថិតិសង្ខេបដែលអាចចូលប្រើប្រាស់បាននៅលើគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ ក៏ដោយក៏ការគ្របដណ្តប់ពេញលេញនៃជំរឿនកសិកម្ម អាចត្រូវបានពិនិត្យ

យ៉ាងលម្អិតតាមរយៈកម្រងសំណួរដែលមាននៅក្នុងគេហទំព័រនេះផងដែរ។ ទិន្នន័យទាំងនេះគឺជាសក្ដានុពលសម្រាប់ការវិភាគស៊ីជម្រៅលើវិសាលភាពនៃរបាយការណ៍លទ្ធផលនេះ។

## ១.៣- វិធីសាស្ត្រ

វិធីសាស្ត្រនៃការធ្វើជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ ត្រូវបានកំណត់អត្តសញ្ញាណ និងបានចូលទៅដល់ក្រុមគ្រួសារទាំងឡាយនៅគ្រប់ ២៥រាជធានី ខេត្តនៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែនៅតំបន់ទីប្រជុំជនក្នុងរាជធានីភ្នំពេញដែលបានដឹងថាមានគ្រួសារកសិកម្មតិចជាង ៥ ក្នុងមួយភូមិ (យោងតាមជំរឿនប្រជាជនទូទៅនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩)។ មន្ត្រីសម្ភាសន៍ជំរឿនត្រូវបានជ្រើសរើសពីគ្រប់រាជធានី ខេត្ត និងទទួលបានការបណ្ដុះបណ្ដាលយ៉ាងលម្អិត និងច្បាស់លាស់ ដើម្បីធ្វើជំរឿនកសិកម្មនេះ។

គ្រួសារចំនួន ៣,៤ លាន ស្ថិតនៅក្នុងតំបន់គោលដៅជំរឿនកសិកម្ម ក្នុងនោះមានគ្រួសារកាន់កាប់កសិកម្មចំនួន ១,៨៥ លាន ត្រូវបានកំណត់អត្តសញ្ញាណជាគ្រួសារកសិកម្ម (ផ្អែកតាមនិយមន័យនៃគ្រួសារកសិកម្ម គឺយ៉ាងហោចណាស់ត្រូវមានផ្ទៃដីដាំដុះដំណាំ ០,០៣ ហិកតា និង/ឬមានចិញ្ចឹមបសុសត្វប្រភេទធំយ៉ាងតិច ២ក្បាល និង/ឬបសុសត្វប្រភេទតូចយ៉ាងតិច ៣ ក្បាល និង/ឬ យ៉ាងហោចណាស់មានបសុបក្សីចំនួន ២៥ក្បាល)។ ក្នុងចំណោមគ្រួសារចំនួន ១,៨៥លានគ្រួសារ គឺមានក្បាលដីកសិកម្មសរុបចំនួន ៣,៦ លានក្បាលដី (រួមទាំងដីជុំវិញលំនៅឋាន) និងមានផ្ទៃដីសរុបប្រមាណ ៣,២ លានហិកតា។ គ្រួសារកសិកម្មទាំងនេះបានផ្ដល់នូវព័ត៌មានស្ដីពីលក្ខណៈទូទៅនៃការកាន់កាប់ដីកសិកម្ម សកម្មភាពកសិកម្ម និងទិន្នន័យលម្អិតនៃសំណួរសំខាន់ៗដែលបានជ្រើសរើស។

សំណុំព័ត៌មានត្រូវបានពង្រីកបន្ថែមទៀត តាមរយៈតារាងសំណួរសម្ភាសន៍មេភូមិរួមជាមួយនឹងសហគ្រាសកសិកម្មខ្នាតធំដែលបានរកឃើញក្នុងពេលជំរឿនកសិកម្ម។ ដោយសារជំរឿនកសិកម្មត្រូវបានធ្វើតាមខ្នងផ្ទះនៃគ្រួសាររស់នៅក្នុងភូមិ ដូចនេះការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ ក៏ត្រូវបានរកឃើញនៅក្នុងដំណើរការធ្វើជំរឿនកសិកម្មនេះដែរ។ ព័ត៌មានស្ដីពីការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ គឺមិនត្រូវបានសិក្សាឱ្យស៊ីជម្រៅនោះទេ ដោយសារតែវិសាលភាពមានកំណត់ក្នុងអំឡុងពេលដំណើរការប្រមូលទិន្នន័យ។ គោលបំណងចម្បងនៃជំរឿនកសិកម្ម គឺដើម្បីរាប់អង្គភាពកសិកម្ម(គ្រួសារកសិកម្ម)ទាំងអស់ដែលមានតាំងទីលំនៅនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ជាពិសេសផ្ដោតទៅលើគ្រួសារកាន់កាប់កសិកម្ម ខណៈដែលគ្រួសារមានទីតាំងនៅក្នុងភូមិមួយចំនួននៃរាជធានីភ្នំពេញ ត្រូវបានដកចេញដោយសារភូមិទាំងនោះមានចំនួនគ្រួសារកាន់កាប់កសិកម្មតិចជាង៥គ្រួសារក្នុងមួយភូមិដែលបានរាយការណ៍នៅក្នុងទិន្នន័យជំរឿនប្រជាជនទូទៅនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩។

នៅពេលដែលគ្រួសារត្រូវបានកំណត់ច្បាស់លាស់ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាគ្រួសារកសិកម្មហើយ ការកាន់កាប់ដីកសិកម្មរបស់ពួកគាត់នឹងត្រូវបានប៉ាន់ប្រមាណដោយកំណត់ផ្អែកតាមលក្ខខណ្ឌគ្រួសារមានក្បាលដីកសិកម្មដាច់ដោយឡែកពីដីលំនៅឋាន ឬមានតែដីជុំវិញលំនៅឋាន ហើយសកម្មភាពផលិតកម្មត្រូវបានវាយតម្លៃសម្រាប់ប្រភេទផ្សេងៗគ្នានៃការកាន់កាប់កសិកម្មទាំងនោះ។

## ១.៤- វិសាលភាពជំរឿន

ជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ នេះបានប្រើប្រាស់នូវទម្រង់នៃកម្រងសំណួរចំនួនបួនសម្រាប់ការសម្ភាសជំរឿន។ **ទម្រង់១** (តារាងសំណួរភូមិ) ត្រូវបានប្រើប្រាស់សម្រាប់ការសម្ភាសប្រធានភូមិទាំងអស់នៅទូទាំងប្រទេសក្នុងកំលុងពេលធ្វើជំរឿន។ **ទម្រង់២** (តារាងសំណួរចុះបញ្ជីគ្រួសារ) ត្រូវបានប្រើប្រាស់សម្រាប់ចុះបញ្ជីគ្រួសារដើម្បីស្វែងរកគ្រួសារកាន់កាប់កសិកម្ម។ **ទម្រង់៣** (តារាងសំណួរព័ត៌មានមូលដ្ឋានលើការធ្វើកសិកម្មគ្រួសារ) ត្រូវបានប្រើប្រាស់សម្រាប់ប្រមូលព័ត៌មានមូលដ្ឋាន និងព័ត៌មានលម្អិតលើការងារកសិកម្មនៃគ្រួសារកាន់កាប់កសិកម្ម។ **ទម្រង់៤** (តារាងសំណួរព័ត៌មានមូលដ្ឋានលើការធ្វើកសិកម្មសហគ្រាសខ្នាតធំ) ត្រូវបានប្រើប្រាស់សម្រាប់ប្រមូលព័ត៌មានមូលដ្ឋាន និងព័ត៌មានលម្អិតលើការងារកសិកម្មនៃកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ(មិនមែនគ្រួសារ)។ ទម្រង់កម្រងសំណួរទាំងនេះ គឺអាចរកបាននៅលើគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ។

វិសាលភាពនៃកម្រងសំណួរនីមួយៗ នឹងត្រូវបានពិពណ៌នាដូចខាងក្រោម៖

- **ទម្រង់១ - តារាងសំណួរភូមិ** ប្រមូលព័ត៌មានស្តីពីប្រភេទដី លក្ខណៈចម្បងនៃតំបន់ភូមិសាស្ត្រ ប្រភេទគ្រោះហានិភ័យ ឬគ្រោះមហន្តរាយក្នុងរយៈពេល ៥ឆ្នាំកន្លងមក សកម្មភាពសេដ្ឋកិច្ចដែលមានកម្លាំងពលកម្មប្រែប្រួលតាមរដូវកាល រយៈពេលដាំដំណាំ ឧបករណ៍សម្ភារៈ និងមធ្យោបាយកសិកម្មកែច្នៃ គ្រឿងយន្ត និងបរិក្ខារដឹកជញ្ជូន សាលារៀន មធ្យោបាយទំនាក់ទំនង ការថែទាំសុខភាព ការប្រើប្រាស់ទឹក ស្ថានភាពផ្លូវថ្នល់និងទីផ្សារ វត្តមានបុគ្គលិកអង្គការ ព្រមទាំងវត្តមានអង្គការជាតិ អន្តរជាតិ វប្បធម៌ និងជំនឿសាសនា។

- **ទម្រង់២ - តារាងសំណួរចុះបញ្ជីគ្រួសារ** រួមមានព័ត៌មានភូមិសាស្ត្ររបស់គ្រួសារតាំងទីលំនៅ និងព័ត៌មានទាក់ទងនឹងគ្រួសារធ្វើសកម្មភាពកសិកម្ម ទំហំផ្ទៃដីដាំដុះដំណាំ ចំនួនសត្វ និងចំនួនសមាជិកគ្រួសារបែងចែកតាមភេទ។

- **ទម្រង់៣ និងទម្រង់៤ - ប្រមូលព័ត៌មានមូលដ្ឋានអំពីគ្រួសារកាន់កាប់កសិកម្ម**

**(ទម្រង់៣) និងសហគ្រាសខ្នាតធំ (ទម្រង់៤)** រួមមានព័ត៌មានភូមិសាស្ត្រនៃអ្នកផ្តល់ចម្លើយ និងព័ត៌មានរបស់ម្ចាស់កសិដ្ឋាន ភាពស្របច្បាប់របស់ម្ចាស់កសិដ្ឋាន កំណត់លក្ខណៈមូលដ្ឋានរបស់កសិដ្ឋាន ដូចជាទំហំផ្ទៃដី ចំនួនក្បាលដីដែលបានកាន់កាប់ជាក់ស្តែង គោលបំណងចម្បងនៃការប្រើប្រាស់ដី និងស្ថានភាពដីនៅក្នុងកសិដ្ឋាន ដីព្រៃនិងដីព្រៃឈើដទៃទៀត ការប្រើប្រាស់ប្រព័ន្ធស្រោចស្រពដំណាំរយៈពេលវែងដែលបានដាំ គោលបំណងចម្បងនៃផលិតកម្ម ការចិញ្ចឹមបសុសត្វ និងបសុបក្សី ការធ្វើវារីវប្បកម្ម ការប្រើប្រាស់កម្លាំងពលកម្ម ការប្រើប្រាស់គ្រឿងម៉ាស៊ីន និងសម្ភារៈកសិកម្ម និងព័ត៌មានពីការខ្ចីប្រាក់របស់គ្រួសារ/កសិដ្ឋានការកាន់កាប់កសិកម្ម។

គ្រួសារទាំងអស់នៅទូទាំងប្រទេសកម្ពុជាត្រូវបានធ្វើការសម្ភាសនៅក្នុងតំណាក់កាលទី១ ដោយប្រើប្រាស់តារាងសំណួរទម្រង់២ដើម្បីកំណត់រកគ្រួសារកសិកម្ម។ ប្រសិនបើគ្រួសារនោះត្រូវបានរកឃើញថាជាគ្រួសារកសិកម្មផ្អែកតាមនិយមន័យដែលបានកំណត់ គ្រួសារកសិកម្មនោះត្រូវបានកត់ត្រានិងស្នើសុំឱ្យចូលរួមផ្តល់បទសម្ភាសជាបន្តទៀតពេលខាងមុខ ដោយប្រើប្រាស់កម្រងសំណួរលម្អិត (ទម្រង់៣)។

## ១.៥- ទីតាំងភូមិសាស្ត្រគ្របដណ្តប់

ជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ បានគ្របដណ្តប់គ្រួសារទាំងអស់នៅក្នុងប្រទេសកម្ពុជា លើកលែងតែភូមិក្នុងខណ្ឌមួយចំនួននៃរាជធានីភ្នំពេញដែលមានគ្រួសារកាន់កាប់កសិកម្មតិចជាង៥គ្រួសារក្នុងមួយភូមិ ដែលបានរាយការណ៍ក្នុងជំរឿនប្រជាជនទូទៅនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ រួមជាមួយសហគ្រាសកសិកម្មខ្នាតធំដែលប្រតិបត្តិការដោយក្រុមហ៊ុន សហករណ៍ ស្ថាប័នសាធារណៈ និងផ្នែកឯកជនដែលឱ្យឈ្មោះថា "ការកាន់កាប់កសិកម្មខ្នាតធំ" នៅក្នុងវិស័យមិនមែនគ្រួសារផងដែរ។

ការកាន់កាប់កសិកម្មជាលក្ខណៈកម្មសិទ្ធិផ្ទាល់ខ្លួន ជាការគ្រប់គ្រង ឬដំណើរការដោយគ្រួសារ ឬអង្គភាពនៅទីប្រជុំជនដែលស្ថិតនៅក្រៅតំបន់គ្របដណ្តប់នៃជំរឿន គឺមិនត្រូវបានធ្វើការសម្ភាសនោះទេ ដោយរក្សាទុកនៅពេលក្រោយសម្រាប់ការធ្វើអង្កេត។

## ១.៦- កាលបរិច្ឆេទយោងជំរឿន

ជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ នេះត្រូវបានអនុវត្តជាពីរដំណាក់កាលដោយដំណាក់កាលទី១ គឺធ្វើការសម្ភាសប្រធានភូមិ (ទម្រង់១) និងការចុះបញ្ជីគ្រួសារ

(ទម្រង់២) នៅគ្រប់ភូមិទាំងអស់ទូទាំងប្រទេស ដែលមានរយៈពេល១០ថ្ងៃ (ចាប់ពីថ្ងៃទី១ដល់ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣) និងដំណាក់កាលទីពីរ គឺជាការសម្ភាសប្រមូលព័ត៌មានមូលដ្ឋានលើការធ្វើកសិកម្មគ្រួសារ (ទម្រង់៣) ជាមួយគ្នានឹងការសម្ភាសព័ត៌មានមូលដ្ឋានលើការធ្វើកសិកម្មសហគ្រាសខ្នាតធំ (ទម្រង់៤) ចាប់ពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣។ ការចំណាយពេលវេលាក្នុងការសម្ភាសនៅដំណាក់កាលទី១ និងដំណាក់កាលទី២ មានការប្រែប្រួលទៅតាមភាពជាក់ស្តែងនៃភូមិជនបទ/ទីប្រជុំជន ភូមិតូច/ធំ និងភូមិដែលមានគ្រួសារកសិកម្មច្រើន/តិច។ ចំពោះរយៈពេលយោងនៃជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ ត្រូវបានកំណត់រយៈពេល ១២ខែកន្លងមក។ កាលបរិច្ឆេទយោងគឺនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣ (មានន័យថាពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២២ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣) ដែលជាទូទៅ ត្រូវបានប្រើប្រាស់ភាគច្រើននៅក្នុងតារាងសំណួរទម្រង់២ ទម្រង់៣ និងទម្រង់៤ នៃជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣។ ទោះជាយ៉ាងណាក៏ដោយក៏រយៈពេលយោងនេះ មានភាពខុសគ្នាពីមួយទៅមួយតាមប្រភេទនៃកម្រងសំណួរនីមួយៗ និងការបែងចែកទិន្នន័យដទៃទៀតផងដែរ។

## ១.៧- នីតិវិធីជំរឿន

ទិន្នន័យទាំងអស់នៅក្នុងជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ ត្រូវបានប្រមូលតាមវិធីសាស្ត្រ **ឃើញរាប់ (de facto)** ដោយមន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យដែលទទួលបានការបណ្តុះបណ្តាលរួចហើយ និងត្រូវបានចាត់ចុះធ្វើយុទ្ធនាការសម្ភាសដោយផ្ទាល់នៅមូលដ្ឋានទីតាំងអង្គភាពកសិកម្ម ឬជាមួយសមាជិកគ្រួសារកាន់កាប់កសិកម្មទាំងនោះ។

អ្នកឆ្លើយតបការសម្ភាស គឺជាសមាជិកគ្រួសារពេញវ័យ (អាយុ១៨ឆ្នាំឡើង) នៃគ្រួសារកសិកម្មនិងមានការយល់ដឹងលើសកម្មភាពកាន់កាប់កសិកម្ម។ អ្នកឆ្លើយតបការសម្ភាសដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បំផុត គឺម្ចាស់កសិដ្ឋាន។ ទោះបីយ៉ាងណាក៏ដោយ ការអវត្តមានរបស់គាត់ មន្ត្រីសម្ភាន៍ក៏អាចសម្ភាសន៍ប្តី ឬប្រពន្ធ ឬកូនប្រុស ឬកូនស្រីដែលមានអាយុពី១៨ឆ្នាំឡើងទៅដែលនៅក្នុងគ្រួសារ និងអាចផ្តល់ចម្លើយបានផងដែរ ប៉ុន្តែមិនមានសមាជិកគ្រួសារណាដែលមានអាយុក្រោម១៨ឆ្នាំ ឬក៏អ្នកជិតខាង ឬក៏គ្រួសារដទៃទៀតមកឆ្លើយតបជំនួសការសម្ភាសប្រមូលព័ត៌មាននៃគ្រួសារកសិកម្មដែលត្រូវធ្វើជំរឿននោះឡើយ។

ទិន្នន័យនៅក្នុងជំរឿន ត្រូវបានប្រមូលដោយប្រើប្រាស់កម្រងសំណួរដែលរចនាឡើងជាលក្ខណៈស្តង់ដារ ដែលមានក្នុងសៀវភៅណែនាំមន្ត្រីសម្ភាសន៍ (បានផ្តល់នូវទស្សនទានលម្អិតនិយមន័យ និងនីតិវិធីដែលត្រូវបានអនុវត្តសម្រាប់ការប្រមូលប្រភេទទិន្នន័យនីមួយៗ)។

សេចក្តីព្រាងកម្រងសំណួរជំរឿននិងសៀវភៅណែនាំត្រូវបានកែលម្អឡើងវិញ និងបានបញ្ចប់ដោយផ្អែកលើលទ្ធផលនៃការធ្វើសម្ភាសជំរឿនសាកល្បង ជាមួយនិងបទពិសោធដែលទទួលបានក្នុងអំឡុងពេលអនុវត្ត។ សៀវភៅណែនាំមន្ត្រីសម្ភាសន៍ គឺត្រូវបានបន្ថែមដោយការត្រួតពិនិត្យភាពស៊ីសង្វាក់គ្នាលើទិន្នន័យជាបន្តបន្ទាប់ដែលបានអនុវត្តនៅតាមមូលដ្ឋាន ការបញ្ចូលទិន្នន័យ និងការកែច្នៃទិន្នន័យឱ្យបានត្រឹមត្រូវនៅក្នុងដំណាក់កាលបន្តបន្ទាប់ទៀត។

## ១.៨- ការផ្សព្វផ្សាយជំរឿនកសិកម្ម

មុនពេលការចុះប្រមូលទិន្នន័យបានចាប់ផ្តើម ការឃោសនាផ្សព្វផ្សាយជំរឿនត្រូវបានធ្វើឡើងដើម្បីទទួលបានការគាំទ្រ និងកិច្ចសហការពីគ្រួសារ និងមិនមែនគ្រួសារទាំងអស់នៅទូទាំងប្រទេសដែលបានចូលរួមនៅក្នុងសកម្មភាពកសិកម្ម។ ប្រធានភូមិ ត្រូវបានចូលរួមដើម្បីផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋនៅក្នុងភូមិ។ យុទ្ធនាការឃោសនាបង្កើនការយល់ដឹង ត្រូវបានធ្វើឡើងតាមរយៈ ប្រព័ន្ធផ្សព្វផ្សាយនានាដូចជាទូរទស្សន៍ វិទ្យុ បណ្តាញសង្គម បដា ខិត្តប័ណ្ណ ផ្ទាំងរូបភាពការបោះពុម្ពនៅលើចង់ អាវយឺត និងមួកត្រូវបានប្រើប្រាស់ក្នុងការធ្វើជំរឿន។ ខិត្តប័ណ្ណនិងអត្ថបទខ្លីៗ ត្រូវបានរៀបចំដោយមានសេចក្តីពន្យល់ដូចជា "តើជំរឿនកសិកម្មនៅកម្ពុជាគឺជាអ្វី? "តើស្ថាប័នណាមួយដែលទទួលខុសត្រូវធ្វើជំរឿនកសិកម្មនៅក្នុងប្រទេសកម្ពុជា?" "តើជំរឿនកសិកម្មនៅក្នុងប្រទេសកម្ពុជាមានសារៈសំខាន់ដូចម្តេចដែរ?" ឯកសារជំរឿនកសិកម្មទាំងនេះ គឺអាចរកបាននៅលើគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។

## ១.៩- ដំណើរការចុះប្រមូលទិន្នន័យជំរឿនកសិកម្ម

ប្រតិបត្តិការនៃការចុះប្រមូលទិន្នន័យតាមមូលដ្ឋាន គឺមានមន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យមានចំនួនជាង ៦០០០នាក់ ដែលជាមន្ត្រីថ្នាក់ជាតិមកពីវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ត្រីថ្នាក់ក្រោមជាតិ។ មន្ត្រីទាំងអស់ត្រូវបានបណ្តុះបណ្តាលយ៉ាងច្បាស់លាស់មុននឹងចុះប្រមូលទិន្នន័យ និងត្រួតពិនិត្យ។ ការបណ្តុះបណ្តាលត្រូវបានបង្កើតជាពីរដំណាក់កាលគឺ ក)- បណ្តុះបណ្តាលគ្រូបង្គោលដែលមានមន្ត្រីមកពីវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរ និងតំណាងមកពីមន្ទីរផែនការពីរាជធានី ខេត្ត។ ខ)- បណ្តុះបណ្តាមន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យមានមន្ត្រីថ្នាក់ក្រោមជាតិមកពីមន្ទីរផែនការ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្ត ស្រុក រួមបញ្ចូលទាំងមន្ត្រីត្រួតពិនិត្យនៅគ្រប់កម្រិតត្រូវបានបណ្តុះបណ្តាលឱ្យបានយល់ច្បាស់លើមូលដ្ឋានគ្រឹះនិយមន័យ និងនីតិវិធីសម្រាប់ការប្រមូលទិន្នន័យ។

ភាពត្រឹមត្រូវនៃលទ្ធផលជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា គឺអាស្រ័យលើគុណភាពនៃការចុះបញ្ជីគ្រួសារ និងការប្រមូលទិន្នន័យពីគ្រួសារកសិកម្ម។ ទោះបីជាការបណ្តុះបណ្តាលត្រូវបានធ្វើឡើងយ៉ាងត្រឹមត្រូវ និងដំណើរការទិន្នន័យត្រូវបានអភិវឌ្ឍន៍យ៉ាងល្អក៏ដោយក៏ការអវត្តមាននៃការត្រួតពិនិត្យគុណភាពប្រកបដោយប្រសិទ្ធភាព ក្នុងកំលុងដំណើរការប្រមូលទិន្នន័យអាចនាំឱ្យទិន្នន័យចុងក្រោយមិនមានគុណភាព។ ការត្រួតពិនិត្យ និងបណ្តាញទំនាក់ទំនងនៅក្នុងជំរឿននេះមានច្រើនកម្រិត ដូចបានរៀបរាប់លម្អិតនៅក្នុងសៀវភៅណែនាំមន្ត្រីត្រួតពិនិត្យ។ ឋានានុក្រមនៃការត្រួតពិនិត្យ និងបណ្តាញទំនាក់ទំនង រួមជាមួយនឹងគោលការណ៍ណែនាំទូលំទូលាយដាច់ដោយឡែកមួយនេះ ត្រូវបានរៀបចំសម្រាប់ប្រធានមន្ត្រីជំរឿនខេត្ត និងមន្ត្រីត្រួតពិនិត្យក្រុម ដើម្បីតាមដានវឌ្ឍនភាពនៃការចុះបញ្ជីគ្រួសារនិងការសម្ភាសគ្រួសារកសិកម្មសម្រាប់ជំរឿនកសិកម្មកម្ពុជាឱ្យបានត្រឹមត្រូវ និងសម្របសម្រួលជួយដោះស្រាយបញ្ហាដែលកើតមានក្នុងដំណើរការចុះប្រមូលទិន្នន័យ។

## ១.១០- ដំណើរការប្រព្រឹត្តិកម្មទិន្នន័យ

បន្ទាប់ពីមន្ត្រីសម្ភាសន៍បានបញ្ចប់ការសម្ភាសពេញលេញនៅក្នុងភូមិដែលខ្លួនទទួលខុសត្រូវរួចមកនោះ មន្ត្រីសម្ភាសន៍បានបំពេញតារាងសង្ខេបភូមិ រួចបញ្ជូនមកមន្ត្រីមន្ត្រីត្រួតពិនិត្យ។ ក្រោយពីពិនិត្យមើលភាពត្រឹមត្រូវ មន្ត្រីត្រួតពិនិត្យបានបំពេញតារាងសង្ខេប ឃុំ/ស្រុក រួចបញ្ជូនតាមលំដាប់ទៅកាន់ស្នាក់ការខេត្តនៅរៀងរាល់ចុងសប្តាហ៍។ មន្ត្រីដែលពាក់ព័ន្ធនៅស្នាក់ការរាជធានី ខេត្ត បានត្រួតពិនិត្យតារាងបញ្ជីសំណួរដែលបំពេញហើយម្តងទៀត ហើយនិងចុងក្រោយបញ្ជូនទម្រង់ទាំងអស់ទៅស្នាក់ការកណ្តាលថ្នាក់ជាតិ សម្រាប់ការបញ្ចូលទិន្នន័យ និងការបញ្ជាក់ពីភាពត្រឹមត្រូវ។ នៅវិទ្យាស្ថានជាតិស្ថិតិដែលជាទីស្នាក់ការកណ្តាល កម្រងបញ្ជីសំណួរដែលបានបញ្ចប់ត្រូវបានទទួលលើកដំបូងដោយការិយាល័យគ្រប់គ្រងឯកសារ ដែលជាកន្លែងត្រួតពិនិត្យជាអប្បរមាមួយនិងធ្វើទៅបានមុនពេលដែលកម្រងសំណួរត្រូវបានដាក់បញ្ជូន សម្រាប់ការបញ្ចូលទិន្នន័យ និងដំណើរការប្រព្រឹត្តកម្មទិន្នន័យផ្សេងៗបន្ថែមទៀត។

ដំណើរការប្រព្រឹត្តកម្មទិន្នន័យ ត្រូវបានធ្វើឡើងដោយប្រើប្រាស់កម្មវិធី CSPro 7.6 ដែលបានរៀបចំទុកជាស្រេច។ សុពលភាពទិន្នន័យបានចាប់ផ្តើមនៅដំណាក់កាលឯកសារ និងបន្តពេញមួយដំណាក់កាលនៃការបញ្ចូលទិន្នន័យ និងដំណើរការដោយកញ្ចប់បញ្ចូលទិន្នន័យត្រូវបានបង្កប់ជាមួយនឹងការត្រួតពិនិត្យភាពស៊ីសង្វាក់គ្នា។ ដំណើរការផ្ទៀងផ្ទាត់នេះត្រូវបានបំពេញបន្ថែមដោយការត្រួតពិនិត្យដោយដៃ និងចុងក្រោយគឺការកែសម្រួលដោយកម្មវិធីកុំព្យូទ័រ។

# ជំពូកទី២

# ភូមិសាស្ត្រ និង ហេដ្ឋារចនាសម្ព័ន្ធនៃប្រទេសកម្ពុជា

ប្រទេសកម្ពុជាមានព្រំប្រទល់ភាគខាងលិចជាប់ប្រទេសថៃ ខាងជើងជាប់ប្រទេសឡាវ និងភាគខាងកើតជាប់ប្រទេសវៀតណាម ហើយបានចែកសណ្ឋានដីជាបួនធំៗ គឺតំបន់វាលទំនាប តំបន់បឹងទន្លេសាប តំបន់ឆ្នេរសមុទ្រ (ជាប់ឈូងសមុទ្រ) និងតំបន់ភ្នំនិងខ្ពង់រាប។ នៅក្នុងតំបន់ទាំងនេះ មានទីតាំងភូមិសាស្ត្រ និងសណ្ឋានដីច្រើនប្រភេទផ្សេងៗគ្នាដែលជាកត្តាសំខាន់ក្នុងការកំណត់ប្រភេទដំណាំសមស្របដែលអាចដាំដុះនៅក្នុងភូមិនៃប្រទេសកម្ពុជា។ ចំនួនប្រជាជនបានរស់នៅពាសពេញទូទាំង ២៥រាជធានី ខេត្ត ហើយអង្គភាពរដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន ខេត្ត ក្រុង/ស្រុក/ខណ្ឌ ឃុំ/សង្កាត់ និងភូមិជាអង្គភាពរដ្ឋបាលតូចជាងគេ។

ប្រទេសកម្ពុជាមានចំនួន ១៤ ៥៧៧ ភូមិ ហើយចំនួនប្រធានភូមិដែលបានសម្ភាសន៍មានចំនួនសរុប ១៤ ០២១ នាក់។ វិសាលភាពនៃជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២៣ បានគ្របដណ្តប់នៅទូទាំង ២៥ រាជធានី ខេត្ត ប៉ុន្តែត្រូវបានដកចេញនូវភូមិមួយចំនួននៅតំបន់ទីប្រជុំជននៃរាជធានីភ្នំពេញ ដោយផ្អែកតាមការពិនិត្យចំនួនគ្រួសារកសិកម្មមានតិចជាងប្រាំគ្រួសារក្នុងមួយភូមិ។

## ២.១- សណ្ឋានដី

តំបន់បឹងទន្លេសាបមានខេត្តចំនួនប្រាំបី គឺខេត្តបន្ទាយមានជ័យ បាត់ដំបង ប៉ៃលិន សៀមរាប ឧត្តរមានជ័យ កំពង់ធំ កំពង់ឆ្នាំង និងខេត្តពោធិ៍សាត់។ តំបន់នេះមានភូមិសាស្ត្រជាប់ភ្នំនិងខ្ពង់រាប។ ដោយឡែក ខេត្តប៉ៃលិន និងខេត្តឧត្តរមានជ័យ មិនមានភូមិណាមួយស្ថិតនៅជាប់នឹងបឹងទន្លេសាបនោះទេ។ ទោះយ៉ាងណានេះក្តី តាមហេតុផលប្រវត្តិសាស្ត្រ និងរដ្ឋបាលខេត្តទាំងពីរនៅតែត្រូវបានចាត់ទុកថាជាខេត្តដែលស្ថិតនៅជុំវិញតំបន់បឹងទន្លេសាប ដែលពីមុនខេត្តទាំងពីរខាងលើជាផ្នែកមួយនៃខេត្តបាត់ដំបង និងសៀមរាប។

តំបន់វាលទំនាបមានខេត្តចំនួនប្រាំពីរ គឺខេត្តកំពង់ចាម កណ្តាល ភ្នំពេញ ព្រៃវែង ស្វាយរៀង តាកែវ និងខេត្តត្បូងឃ្មុំ។

តំបន់ភ្នំនិងខ្ពង់រាបមានចំនួនប្រាំមួយ គឺខេត្តកំពង់ស្ពឺ ព្រះវិហារ រតនគិរី មណ្ឌលគិរី ក្រចេះ និងខេត្តស្ទឹងត្រែង។

តំបន់ឆ្នេរសមុទ្រមានខេត្តចំនួនបួន គឺខេត្តកំពត កោះកុង ព្រះសីហនុ និងខេត្តកែប។

## ២.២- ប្រភេទដី

ដីភាគច្រើននៅប្រទេសកម្ពុជា គឺជាប្រភេទដីភក់ ដីល្បាយខ្សាច់ និងដីល្បាប់។ ភូមិច្រើនជាង ៥០ភាគរយ នៃប្រទេសកម្ពុជាស្ថិតនៅតំបន់ដែលមានប្រភេទដីភក់ និងប្រមាណជិត ៥០ភាគរយ មានទីតាំងស្ថិតនៅតំបន់ដែលមានប្រភេទដីល្បាយខ្សាច់។ ប្រមាណ ៤៥ភាគរយ នៃភូមិទាំងអស់ត្រូវបានរកឃើញថាមានដីប្រភេទដីល្បាប់ ប្រមាណ ៣០ភាគរយ ជាភូមិដែលមានដីឥដ្ឋ និងប្រមាណជា ២៥ភាគរយ គឺជាមានប្រភេទដីស្ថិតឬដីគ្រួស។ ភូមិដែលមានប្រភេទដីក្រហម និងប្រភេទដីផ្សេងទៀតមានតិចជាង ១៥ភាគរយ ហើយប្រភេទដីភក់ ដីខ្សាច់ និងដីល្បាប់ មានភាគច្រើននៅតំបន់ឆ្នេរសមុទ្រនិងតំបន់ភ្នំនិងខ្ពង់រាប។

ដីភក់ ត្រូវបានរកឃើញភាគច្រើននៅក្នុងភូមិនៃខេត្តកំពត ព្រះវិហារ សៀមរាប ពោធិ៍សាត់ ព្រៃវែង កោះកុង ក្រចេះ តាកែវ និងខេត្តស្ទឹងត្រែង។ ដូចគ្នានេះដែរ ដីខ្សាច់ ភាគច្រើនមាននៅក្នុងភូមិនៃខេត្តស្វាយរៀង ឧត្តរមានជ័យ ព្រះវិហារ កំពង់ឆ្នាំង ព្រៃវែង និងខេត្តកែប។ ខេត្តដែលមានភាគរយខ្ពស់នៃភូមិដែលមានដីល្បាប់ រួមមានខេត្តកែប ព្រះវិហារ ពោធិ៍សាត់ ស្ទឹងត្រែង ក្រចេះ កំពង់ឆ្នាំង និងខេត្តកំពត។ ដីសម្បូរទៅដោយគ្រួស មានច្រើននៅក្នុងភូមិនៃតំបន់ភ្នំនិងខ្ពង់រាប និងតំបន់ឆ្នេរសមុទ្រ លើកលែងតែខេត្តកំពង់ស្ពឺនិងខេត្តកំពត។ ដូចគ្នានេះដែរ ភូមិភាគច្រើនក្នុងខេត្តប៉ៃលិននិងខេត្តឧត្តរមានជ័យ ក៏មានដីសម្បូរគ្រួសដែរ។

ម្យ៉ាងវិញទៀត ខេត្តចំនួនប្រាំ រួមមានខេត្តរតនគិរី កោះកុង ព្រះសីហនុ ប៉ៃលិន និងខេត្តមណ្ឌលគិរី គឺមានភូមិលើសពី ៥០ភាគរយ មានដីក្រហម។ បន្ថែមពីលើនេះ ដីឥដ្ឋដែលសម្បូរទៅដោយសារធាតុរ៉ែ ត្រូវបានរកឃើញក្នុងសមាមាត្រខ្ពស់ជាងនៅក្នុងភូមិនៃខេត្តចំនួនពីរ គឺខេត្តព្រះវិហារ និងខេត្តបន្ទាយមានជ័យ។ ប្រភេទដីល្បាយខ្សាច់ ដីល្បាប់ និងដីឥដ្ឋ ត្រូវបានរកឃើញថាប្រមាណជា ៥៥ភាគរយនៃភូមិ គឺមានតែនៅក្នុងខេត្តកោះកុង តែប៉ុណ្ណោះ។

## ២.៣- តំបន់ងាយរងសម្ពាធទាប

ប្រទេសកម្ពុជាគឺជាប្រទេសដែលងាយនឹងមានភ្លៀងធ្លាក់ច្រើន គ្រោះទឹកជំនន់ក្នុងរដូវវស្សា និងគ្រោះរាំងស្ងួតនៅរដូវប្រាំង។ ក្នុងរយៈពេល៥ឆ្នាំមុនថ្ងៃធ្វើជំរឿនកសិកម្ម មានភូមិប្រមាណ ៣៩ភាគរយនៃប្រទេសកម្ពុជា ធ្លាប់បានជួបប្រទះគ្រោះទឹកជំនន់ ហើយប្រមាណ ៤៨ភាគរយ បានជួបប្រទះគ្រោះរាំងស្ងួត និងអសន្តិសុខស្បៀង ដែលអាចនឹងប្រឈមមុខនឹងការកង្វះស្បៀងអាហារ។ គ្រោះទឹកជំនន់ក្នុងរដូវវស្សាបានរងផលប៉ះពាល់ធ្ងន់ធ្ងរបំផុត គឺភូមិនានាក្នុងតំបន់បឹងទន្លេសាប។ ជាក់ស្តែងមានប្រហែល ៧៩ ភាគរយ នៃភូមិនៅភាគពាយ័ព្យ

ខេត្តបន្ទាយមានជ័យ ៧៥ ភាគរយ នៅខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ ៦៩ ភាគរយ នៅខេត្តសៀមរាប និង ៦៨ ភាគរយនៅខេត្តកំពង់ធំ រងផលប៉ះពាល់ភាគច្រើន។ ទឹកជំនន់បានក្លាយជាការកើតឡើងប្រចាំឆ្នាំនៅផ្នែកខ្លះនៃខេត្តជាប់ព្រំដែនប្រទេសថៃ។ លើសពីនេះទៀត ៦៥ ភាគរយនៃភូមិក្នុងខេត្តព្រះវិហារបានរងគ្រោះដោយទឹកជំនន់ ហើយប្រហែល ៥៦ ភាគរយនៃភូមិក្នុងខេត្តស្ទឹងត្រែងបានជួបប្រទះស្ថានភាពស្រដៀងគ្នានេះក្នុងអំឡុងពេល៥ឆ្នាំមុនមុនពេលធ្វើជំរឿន។

ដូចគ្នានឹងគ្រោះទឹកជំនន់ដែរ ភូមិក្នុងតំបន់បឹងទន្លេសាប ក៏រងផលប៉ះពាល់យ៉ាងខ្លាំងពីគ្រោះរាំងស្ងួតក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ។ ប្រហែល ៩០ ភាគរយនៃភូមិក្នុងខេត្តប៉ៃលិនរងផលប៉ះពាល់យ៉ាងខ្លាំងពីគ្រោះរាំងស្ងួត ខណៈដែលភូមិនានាក្នុងខេត្តផ្សេងទៀតនៅក្នុងតំបន់បឹងទន្លេសាបបានជួបប្រទះគ្រោះរាំងស្ងួតក្នុងអត្រាចាប់ពី ៦១ ទៅ ៧៧ ភាគរយ។ ទោះយ៉ាងណាក៏ដោយ លក្ខខណ្ឌគ្រោះរាំងស្ងួតមិនស្ថិតនៅក្នុងតំបន់បឹងទេ។ ភូមិនានាក្នុងខេត្តក្រចេះ ព្រះវិហារ ព្រៃវែង និងខេត្តស្វាយរៀង ក៏ជួបប្រទះនឹងបញ្ហាគ្រោះរាំងស្ងួតធ្ងន់ធ្ងរផងដែរ ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ។

នៅទូទាំងប្រទេស ៤៣ ភាគរយនៃភូមិបានរងផលប៉ះពាល់ពីខ្យល់ព្យុះ ឬខ្យល់កន្ត្រាក់ ដោយខេត្តកែបបានរាយការណ៍មានតួលេខខ្ពស់ជាងគេគឺ ៨៣ ភាគរយ។ ចំណែកភូមិនានាទូទាំងខេត្តស្ថិតនៅតំបន់បឹងទន្លេសាបមានប្រហែល ៥៤ ទៅ ៧៤ ភាគរយ បានរងឥទ្ធិពលនៃខ្យល់ព្យុះនិងខ្យល់កន្ត្រាក់។ ផ្ទុយទៅវិញ គ្រោះហានិភ័យនៃការបាក់ច្រាំង/ដីនៅប្រទេសកម្ពុជាមានការថយចុះគួរឱ្យកត់សម្គាល់បើធៀបនឹងគ្រោះមហន្តរាយធម្មជាតិផ្សេងទៀតដូចជាទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ និងខ្យល់កន្ត្រាក់ ។ ការបាក់ច្រាំង/ដីកើតមានច្រើនជាងគេនៅក្នុងខេត្តពោធិ៍សាត់ ដែលប៉ះពាល់ប្រហែល ៦០ ភាគរយនៃភូមិ ខណៈដែល ១៨ ភាគរយឬតិចជាងនៃភូមិនៅក្នុងខេត្តផ្សេងទៀតត្រូវបានរងផលប៉ះពាល់ដោយការបាក់ច្រាំង/ដីក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយមុនពេលធ្វើជំរឿន។

បន្ថែមពីលើនេះបញ្ហាជំងឺធម្មជាតិក៏រងផលប៉ះពាល់ផងដែរ មានកសិករជាច្រើននៅតំបន់ជនបទបានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីសត្វល្អិត និងជំងឺដែលប៉ះពាល់ដល់ដំណាំ និងសត្វក៏ដូចជាជំងឺរាតត្បាតកូវីដ-១៩ ក្នុងរយៈពេលប្រាំឆ្នាំមុនការធ្វើជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣។ នៅទូទាំងប្រទេសផលប៉ះពាល់នៃកូវីដ-១៩ គឺមានសារៈសំខាន់បំផុត ដោយភូមិជាង ៧០ ភាគរយបានរាយការណ៍ពីផលប៉ះពាល់របស់វា។ នេះត្រូវបានបន្តដោយ ៦៦ ភាគរយនៃភូមិដែលរងផលប៉ះពាល់ដោយជំងឺសត្វ ៥៣ ភាគរយដោយសត្វល្អិត និង ៥១ ភាគរយដោយជំងឺដំណាំ។

ផលប៉ះពាល់អវិជ្ជមាននៃមេរោគកូវីដ-១៩ សត្វល្អិត និងជំងឺមានច្រើនជាងគេនៅក្នុងភូមិជុំវិញតំបន់បឹងទន្លេសាប បន្ទាប់មកគឺតំបន់ឆ្នេរសមុទ្រ និងតំបន់វាលទំនាប។ ផ្ទុយទៅវិញ ភូមិនៅតំបន់ភ្នំនិងខ្ពង់រាប ជួបប្រទះផលប៉ះពាល់តិចតួចពីកូវីដ-១៩ និងជំងឺ និងសត្វល្អិតដែលពាក់ព័ន្ធក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ ដែលទំនងជាដោយសារតែអាកាសធាតុត្រជាក់នៅក្នុងតំបន់នោះ។

គួររម្លឹកដែរថា មានភូមិជិត ១០០ ភាគរយក្នុងខេត្តកែប បានរងផលប៉ះពាល់យ៉ាងខ្លាំងពីជំងឺកូវីដ១៩។ ផលប៉ះពាល់ក៏មានកម្រិតខ្ពស់ផងដែរ នៅក្នុងខេត្តមួយចំនួនទៀត ដោយភូមិជាង ៨០ ភាគរយក្នុងខេត្តកំពង់ចាម កណ្ដាល ស្វាយរៀង និងពោធិ៍សាត់ ទទួលរងឥទ្ធិពលស្រដៀងគ្នានេះ។ ប្រហែល ៨០ ភាគរយ ឬច្រើនជាងនេះនៃភូមិក្នុងខេត្តព្រះវិហារ ប៉ៃលិន រតនគិរី កែប និងខេត្តបាត់ដំបង ត្រូវបានរងផលប៉ះពាល់ដោយជំងឺសត្វ។ លើសពីនេះ សត្វល្អិតនិងជំងឺដំណាំត្រូវបានកត់សម្គាល់ឃើញនៅក្នុងភូមិចំនួន ៧០ ភាគរយ ឬច្រើនជាងនេះ នៅក្នុងខេត្តបាត់ដំបង ពោធិ៍សាត់ ប៉ៃលិន និងខេត្តព្រះវិហារ។ មានភូមិជាង ៧០ ភាគរយនៃភូមិក្នុងខេត្តស្វាយរៀង និងខេត្តឧត្តរមានជ័យ ក៏បានរងគ្រោះពីសត្វល្អិត និងជំងឺដំណាំក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះផងដែរ។

## ២.៤- គ្រោះហានិភ័យ និងគ្រោះមហន្តរាយ

បើនិយាយពីគ្រោះធម្មជាតិ និងគ្រោះហានិភ័យក្នុងរយៈពេល៥ឆ្នាំចុងក្រោយមុនពេលធ្វើជំរឿននេះ គឺមានគ្រោះរាំងស្ងួតបានកើតឡើងញឹកញាប់បំផុតដែលមានសរុបចំនួន ៦ ៧៥៣ ករណី។ បន្ទាប់មកគឺខ្យល់ព្យុះនិងខ្យល់កន្ត្រាក់ ចំនួន ៦ ១៣៥ ករណី គ្រោះទឹកជំនន់ ៥ ៥៧២ ករណី និងការបាក់ដី/ច្រាំង ចំនួន ១ ៤២២ ករណីបានកើតឡើង។ ទោះបីជាចំនួនសរុបនៃគ្រោះមហន្តរាយដែលបានកើតឡើង ១ដង គឺខ្ពស់ជាងគេក៏ដោយ ភាពញឹកញាប់នៃគ្រោះមហន្តរាយកើតឡើងពី ២ ទៅ ៥ ដង ឬច្រើនជាង ៥ ដងក៏ត្រូវបានគេសង្កេតឃើញយ៉ាងខ្ពស់ផងដែរក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ។ ភូមិក្នុងតំបន់បឹងទន្លេសាប ងាយរងគ្រោះដោយគ្រោះធម្មជាតិ បន្ទាប់មកភូមិនៅតំបន់វាលទំនាប តំបន់ឆ្នេរសមុទ្រ និងតំបន់ភ្នំនិងខ្ពង់រាប។

ភូមិដែលរងផលប៉ះពាល់ដោយខ្យល់ព្យុះឬខ្យល់កន្ត្រាក់ជាញឹកញាប់ គឺជាភូមិដែលមានទីតាំងនៅក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ និងខេត្តសៀមរាប (ក្នុងតំបន់បឹងទន្លេសាប) ខេត្តព្រៃវែង និងស្វាយរៀង (ក្នុងតំបន់វាលទំនាប) ខេត្តកំពត (ក្នុងតំបន់ឆ្នេរសមុទ្រ) និងខេត្តកំពង់ស្ពឺ (ក្នុងតំបន់ភ្នំនិងខ្ពង់រាប)។ ភាពញឹកញាប់នៃគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ក៏ដូចគ្នាទៅនឹងខេត្តដែលរងផលប៉ះពាល់ដោយព្យុះឬខ្យល់កន្ត្រាក់ដែរ។ ផ្ទុយទៅវិញ ចំនួននៃការបាក់ដីឬបាក់

ច្រាំងក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ គឺទាបជាងគ្រោះមហន្តរាយដទៃទៀត។ តំបន់ដែលរងផលប៉ះពាល់ដោយការបាក់ដីឬបាក់ច្រាំងជាញឹកញាប់ រួមមានភូមិក្នុងខេត្តកំពង់ចាម និងខេត្តកណ្តាល (ក្នុងតំបន់វាលទំនាប) ខេត្តបាត់ដំបង និងពោធិ៍សាត់ (ក្នុងតំបន់បឹងទន្លេសាប) ខេត្តកំពត (ក្នុងតំបន់ឆ្នេរសមុទ្រ) និងខេត្តកំពង់ស្ពឺ (ក្នុងតំបន់ភ្នំនិងខ្ពង់រាប)។

ស្រដៀងនឹងគ្រោះធម្មជាតិដែរ ភាពញឹកញាប់នៃជំងឺ សត្វល្អិត និងផលប៉ះពាល់នៃកូវីដ-១៩ មានកម្រិតខ្ពស់ជាងនៅក្នុងភូមិនៃតំបន់បឹងទន្លេសាប និងតំបន់វាលទំនាប។ ខេត្តដែលរងផលប៉ះពាល់ខ្លាំងជាងគេដោយជំងឺកើតឡើងដដែលៗ ការវាយប្រហារពីសត្វល្អិត និងផលប៉ះពាល់នៃជំងឺកូវីដ-១៩ ក៏ដូចគ្នាទៅនឹងខេត្តដែលរងគ្រោះពីគ្រោះធម្មជាតិដែរ។ នៅថ្នាក់ជាតិ ការកើតមានជំងឺកូវីដ-១៩ ត្រូវបានរាយការណ៍ចំនួន ១០ ០១៧ ដង បន្ទាប់មកជំងឺសត្វមាន ៩ ៣២៦ ដង ឬការវាយប្រហារពីសត្វល្អិត ៧ ៥២២ ដង និងជំងឺដំណាំមាន ៧ ២៧០ ដងក្នុង រយៈពេល ៥ ឆ្នាំកន្លងមក។ តំបន់ដែលរងផលប៉ះពាល់ខ្លាំងបំផុតទាក់ទងនឹងចំនួនការកើតឡើង នៃជំងឺកូវីដ-១៩ គឺខេត្តកំពង់ចាម កណ្តាល ព្រៃវែង និងខេត្តតាកែវ នៃតំបន់វាលទំនាប។ ខេត្តបាត់ដំបង និងពោធិ៍សាត់ នៃតំបន់បឹងទន្លេសាប ខេត្តកំពង់ស្ពឺ នៃតំបន់ភ្នំនិងខ្ពង់រាប និងខេត្តកំពត នៃតំបន់ឆ្នេរសមុទ្រ។

គួរជម្រាបថា ខេត្តពោធិ៍សាត់មានគ្រោះមហន្តរាយកើតឡើងច្រើនជាងគេគឺ ៥ ដង និងច្រើនជាងគេរួមទាំងជំងឺកូវីដ១៩ សត្វល្អិត និងជំងឺ បើទោះជាចំនួនគ្រោះហានិភ័យ និងគ្រោះមហន្តរាយសរុបមានចំនួនតិចជាងខេត្តដទៃទៀតក៏ដោយ។

## ២.៥- សកម្មភាពសេដ្ឋកិច្ច

កម្ពុជាជាប្រទេសមួយដែលចាត់ទុកវិស័យកសិកម្មគឺជាវិស័យអាទិភាព។ ការរីកចម្រើននៃសេដ្ឋកិច្ចត្រូវបានពឹងផ្អែកលើការដាំដុះដំណាំ ការចិញ្ចឹមសត្វមាន់ សត្វទា សត្វសមុទ្រ និងការនេសាទតាមដងទន្លេ ជលផល និងការប្រមូលផលិតផលព្រៃឈើ។ នៅថ្នាក់ជាតិ កសិករនៅក្នុងភូមិជាង ៩០ ភាគរយបានចូលរួមក្នុងការដាំដុះដំណាំ និងការចិញ្ចឹមបសុសត្វ បសុបក្សីដែលជាសកម្មភាពចម្បងរបស់គ្រួសារកសិកម្ម។ ជារួមមានភូមិប្រមាណ ២០ភាគរយ បានចូលរួមក្នុងសកម្មភាពនេសាទ និងវារីវប្បកម្ម។ ទោះជាយ៉ាងនេះក្តី នៅកម្រិតថ្នាក់ខេត្ត តំបន់ឆ្នេរសមុទ្រនៃខេត្តកោះកុង បានកត់សម្គាល់ឃើញថាមានការចូលរួមសកម្មភាពនេសាទច្រើនជាងគេរហូតដល់ប្រមាណ ៧៧ភាគរយ នៃភូមិសរុបទាំងអស់ដែលមានក្នុងខេត្តនេះ។ ដូចគ្នានេះដែរ មានភូមិប្រមាណ ៤០ភាគរយ នៅក្នុងខេត្តមណ្ឌលគិរី ព្រៃវែង និងខេត្តស្វាយរៀង ដែលបានចូលរួមធ្វើសកម្មភាពវារីវប្បកម្ម។

នៅទូទាំងប្រទេស មានភូមិប្រមាណ ១១ ភាគរយ ដែលចូលរួមប្រមូលអនុផលព្រៃឈើ។ ទោះយ៉ាងណាក៏ដោយនៅតំបន់ភ្នំនិងខ្ពង់រាប នៃខេត្តមណ្ឌលគិរី មានភូមិប្រមាណ ៦៣ ភាគរយ នៅតែប្រមូលផលធម្មជាតិពីព្រៃឈើក្នុងស្រុក។ សកម្មភាពសេដ្ឋកិច្ចរបស់ប្រជាជននៅក្នុងភូមិ ក៏មានធ្វើការនៅក្នុងវិស័យឧស្សាហកម្ម និងវិស័យផ្សេងៗទៀតផងដែរ ដើម្បីទទួលបានប្រាក់ចំណូលបន្ថែមនៅពេលចាំបាច់។ នៅថ្នាក់ជាតិមានភូមិប្រមាណ ១៤ ភាគរយ នៃភូមិដែលបាន ចូលរួមចំណែកក្នុងប្រភពចំណូលជំនួស។ ចំណែកតួលេខនេះសម្រាប់នៅខេត្តកែប គឺកើនឡើង ដល់៥០ភាគរយ។

## ២.៦- ប្រព័ន្ធដាំដុះដំណាំ

នៅក្នុងប្រទេសកម្ពុជាអនុវត្តធ្វើកសិកម្មមានលក្ខណៈទូទៅ គឺការដាំដុះដំណាំមានតែមួយដង(លើក)។ នៅទូទាំងប្រទេសមានប្រមាណ ៦៣ភាគរយ នៃភូមិដាំដុះដំណាំតែមួយដង ឬមួយលើកក្នុងមួយឆ្នាំ។ ភូមិដែលផលិតដំណាំពីរដងក្នុងមួយឆ្នាំមានប្រមាណ ៣០ភាគរយ នៅខណៈដែលមានភូមិប្រមាណ ៦ភាគរយ ប៉ុណ្ណោះដែលបានដាំដំណាំបី ឬច្រើនដងជាងនេះ ក្នុងមួយឆ្នាំ។ ភូមិជាច្រើននៅតំបន់ភ្នំនិងខ្ពង់រាប មានការដាំដំណាំតែមួយដង ទំនងប្រហែលជាបានរងឥទ្ធិពលដោយលក្ខខណ្ឌអាកាសធាតុមិនអំណោយផល។ មានភូមិជាង ៩៥ភាគរយ នៃភូមិក្នុងខេត្តស្ទឹងត្រែងនៃតំបន់ភ្នំ និងមានភូមិប្រមាណ ៩០ភាគរយ នៃភូមិនៅក្នុងរាជធានីភ្នំពេញនៃតំបន់វាលទំនាប ដែលបានពឹងផ្អែកលើការដាំដុះដំណាំតែមួយដងប៉ុណ្ណោះក្នុងមួយឆ្នាំ។

ផ្ទុយទៅវិញ ភូមិចំនួនច្រើនជាងគេ គឺនៅក្នុងតំបន់បឹងទន្លេសាបមានការដាំដុះដំណាំពីរដងជាក់ស្តែងមានប្រមាណ ៦២ភាគរយ នៃភូមិក្នុងខេត្តពោធិ៍សាត់ ហើយមានភូមិប្រមាណ ៤៩ភាគរយ នៅខេត្តប៉ៃលិន និងមាន ៤៨ ភាគរយនៅខេត្តបាត់ដំបងបានដាំដំណាំពីរក្នុងមួយឆ្នាំ។ លើសពីនេះមាន៤៩ ភាគរយនៃភូមិក្នុងខេត្តព្រៃវែង ដែលមកពីតំបន់វាលទំនាប ក៏បានធ្វើការដាំដុះដំណាំពីរដងផងដែរ។ ម្យ៉ាងវិញទៀត ៣៥ ភាគរយនៃភូមិក្នុងខេត្តពោធិ៍សាត់ និង ១៦ ភាគរយនៅក្នុងខេត្តព្រៃវែងគឺបានចូលរួមធ្វើស្រែប្រាំងជារៀងរាល់ឆ្នាំ។ ទោះជាយ៉ាងណាក៏ដោយ ក៏ភាគរយនៃភូមិដែលដាំដំណាំលើសពីបីដងក្នុងមួយឆ្នាំ គឺនៅតែមានតួលេខទាបជាងកម្រិតថ្នាក់ជាតិ ហើយនិន្នាការនេះគឺស្របគ្នានៅថ្នាក់ខេត្តផងដែរ។

រូបទី២.១ ភាគរយភូមិដែលបានរាយការណ៍ពីវដ្តដំណាំក្នុងមួយឆ្នាំ បែងចែកតាមតំបន់




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

## ២.៧- ការកែច្នៃកសិផល និង ហេដ្ឋារចនាសម្ព័ន្ធជនបទ

ភាពអាចរកបាន និងការទទួលបានឧបករណ៍ និងបរិក្ខារកែច្នៃកសិផល គឺជាធាតុផ្សំដ៏សំខាន់នៃវដ្តផលិតកម្មសម្រាប់គ្រួសារនៅជនបទ ជាពិសេសសម្រាប់អ្នកដែលពឹងផ្អែកលើកសិកម្មនៃសាទ និងផលិតផលព្រៃឈើ។

ម៉ាស៊ីនបោកស្រូវ និងម៉ាស៊ីនច្រូតកាត់ គឺជាប្រភេទឧបករណ៍ដែលអាចប្រើបានច្រើនបំផុតសម្រាប់គ្រួសារនៅតាមជនបទ ខណៈដែលម៉ាស៊ីនកិនស្រូវគឺជាឧបករណ៍ដែលពេញនិយមបំផុតដែលមាននៅក្នុងភូមិ។ នៅទូទាំងប្រទេស ភូមិប្រហែល ៥៨ ភាគរយបានរាយការណ៍ថាមានម៉ាស៊ីនកិនស្រូវ ចំណែកម៉ាស៊ីនបោកស្រូវ និងម៉ាស៊ីនច្រូតកាត់មាននៅក្នុងភូមិមានប្រហែល ៣៥ ភាគរយ។ នេះសបញ្ជាក់ឱ្យឃើញថា ម៉ាស៊ីនបោកស្រូវ ម៉ាស៊ីនច្រូតកាត់ និងម៉ាស៊ីនកិនស្រូវ គឺជាឧបករណ៍កែច្នៃកសិផលទូទៅបំផុតនៅក្នុងប្រទេសកម្ពុជា។ ទោះយ៉ាងណាក៏ដោយបើនិយាយពីចំនួនវិញម៉ាស៊ីនកិនស្រូវជិត ៣ ដង (៣០ ៣៩២) នៃម៉ាស៊ីនបោកស្រូវ និងម៉ាស៊ីនច្រូតកាត់មាន (១០ ៦៨៦) នៅក្នុងភូមិទូទាំងប្រទេស។ ខេត្តព្រៃវែងមានចំនួនច្រើនជាងគេ ដោយមានម៉ាស៊ីនកិនស្រូវតាមគ្រួសារមានចំនួន ៤ ១៣៣ ម៉ាស៊ីន និងម៉ាស៊ីនបោកស្រូវ និងម៉ាស៊ីនច្រូតកាត់ចំនួន ១ ៦៩០ គ្រឿង។ ខណៈដែលរោងចក្រកែច្នៃកសិផលផ្សេងទៀត ដូចជាម៉ាស៊ីនផលិតស្ករ

រោងម៉ាស៊ីនកិនស្រូវធំៗ ម៉ាស៊ីនប្រលេះដំណាំ និងម៉ាស៊ីនសម្ងួតដំណាំក៏ត្រូវបានរាយការណ៍នៅតាមភូមិនានាដែលមានចំនួនអត្រាប្រេវ៉ាឡង់ របស់វាទាបជាងគួរឱ្យកត់សម្គាល់បើធៀបនឹងម៉ាស៊ីនបោកស្រូវ និងម៉ាស៊ីនកិនស្រូវ។

ប្រព័ន្ធធារាសាស្ត្រមានសារៈសំខាន់ណាស់ សម្រាប់ការផ្គត់ផ្គង់ទឹកដល់ដីកសិកម្មបន្ថែមពីលើការពឹងផ្អែកតែលើទឹកភ្លៀងប៉ុណ្ណោះដែលជួយលើកកម្ពស់ផលិតកម្មដំណាំ និងការលូតលាស់វាលស្មៅ។ ក្រៅពីនេះប្រព័ន្ធធារាសាស្ត្រក៏ត្រូវបានប្រើប្រាស់ជាមធ្យោបាយដឹកជញ្ជូនផលិតផលកសិកម្មពីតំបន់មួយទៅតំបន់មួយទៀតផងដែរ។ ប្រព័ន្ធទាំងនេះជាធម្មតាត្រូវបង្កើតជាហេដ្ឋារចនាសម្ព័ន្ធ និងឧបករណ៍ដូចជា ប្រឡាយទឹក ប្រព័ន្ធបូម ប្រព័ន្ធបាញ់ទឹក ឬប្រព័ន្ធទឹកដែលបានធ្វើមូលដ្ឋានីយកម្ម។ ការស្រោចស្រពដោយដៃ ការស្រោចស្រពដោយប្រើធុងទឹក ការស្រោចស្រពដោយប្រើប៉ុងទឹក ឬឧបករណ៍ផ្សេងទៀតក៏ជាផ្នែកនៃការអនុវត្តប្រព័ន្ធធារាសាស្ត្រផងដែរ។ នៅទូទាំងប្រទេសប្រព័ន្ធធារាសាស្ត្របានរាយការណ៍ថា មាននៅក្នុងភូមិត្រឹមតែ ២០ភាគរយប៉ុណ្ណោះ។ ទោះជាយ៉ាងណា នៅតំបន់មួយចំនួនក្នុងខេត្តប៉ៃលិន ឧត្តរមានជ័យ ព្រះវិហារ រតនគិរី ស្ទឹងត្រែង ព្រះសីហនុ និងរាជធានីភ្នំពេញ បានរាយការណ៍ថាមានលទ្ធភាពប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រតិចតួចបំផុតក្រោមអត្រា ៦ភាគរយ នៃចំនួនភូមិស្ថិតិនៅក្នុងតំបន់ទាំងនេះ។ ស្រដៀងគ្នាទៅនឹងអត្រាភាគរយទាបនៃភូមិដែលមានប្រព័ន្ធធារាសាស្ត្រនោះ ចំនួនប្រព័ន្ធធារាសាស្ត្រដែលមាននៅក្នុងខេត្តទាំងនោះ គឺមានតិចតួចស្ទើរតែដល់អត្រាសូន្យ ឬមិនមាន។

## ២.៨- មធ្យោបាយដឹកជញ្ជូន

ផ្លូវថ្នល់ ទីផ្សារ និងមធ្យោបាយដឹកជញ្ជូន គឺចាំបាច់ណាស់សម្រាប់គ្រួសារកសិកម្មក្នុងការទិញនូវធាតុចូលផលិតកម្មដូចជា ពូជ ជី និងថ្នាំកសិកម្ម និងដឹកយកផលដំណាំដែលផលិតបានរបស់ពួកគេសម្រាប់ លក់នៅលើទីផ្សារ។ នៅក្នុងប្រទេសកម្ពុជា មធ្យោបាយដឹកជញ្ជូនទូទៅក្នុងវិស័យកសិកម្មរួមមាន រថយន្ត ត្រាក់ទ័រ/គោយន្ត ម៉ូតូ កង់បី/រ៉ឺម៉ក ទូក និងរទេះសេះ/រទេះគោ។ ទិន្នន័យបានបង្ហាញថា ម៉ូតូគឺជាមធ្យោបាយដឹកជញ្ជូនដែលនិយមប្រើជាទូទៅបំផុតនៅតំបន់ជនបទ។ នៅទូទាំងប្រទេសមាន ៩១ ភាគរយ នៃភូមិដែលបានរាយការណ៍ពីភាពអាចរកបាននៃម៉ូតូ បន្ទាប់មកគឺត្រាក់ទ័រ/គោយន្តមាន ៨៨ ភាគរយ និងរថយន្តមាន ៧៦ ភាគរយ។

ភូមិមានប្រមាណ ៦២ ភាគរយ នៃភូមិដែលបានរាយការណ៍ថាបានប្រើម៉ូតូកង់បី/រ៉ឺម៉ក ជាមធ្យោបាយដឹកជញ្ជូនចម្បងសម្រាប់ការដោះដូរកសិផលរវាងកសិដ្ឋាន ទីផ្សារ និងអ្នកបរិភោគ។ ម៉ូតូកង់បី/រ៉ឺម៉កគឺមានប្រើប្រាស់ខ្ពស់ក្នុងតំបន់វាលទំនាប និងឆ្នេរសមុទ្រ។ ខេត្តកែប (៨៣ ភាគរយ) កំពត (៨០ ភាគរយ) កំពង់ចាម (៨០ ភាគរយ) កណ្ដាល (៧៧ ភាគរយ) និងតាកែវ (៧២

ភាគរយ) មានភាគរយខ្ពស់ នៃភូមិដែលប្រើប្រាស់មធ្យោបាយដឹកជញ្ជូនទាំងនេះ។

ទូក រទេះសេះ និងរទេះគោ គឺជាមធ្យោបាយធ្វើដំណើរបែបប្រពៃណីនៅតំបន់ជនបទ។ ទោះបីជាការប្រើប្រាស់របស់ពួកគេមានការថយចុះក៏ដោយ ក៏ទូកនៅតែត្រូវបានប្រើប្រាស់នៅក្នុងភូមិចំនួន ២១ ភាគរយ ខណៈដែលរទេះសេះ/រទេះគោ ត្រូវបានប្រើប្រាស់នៅក្នុងភូមិចំនួន ១៣ ភាគរយ។ នៅក្នុងខេត្តជាប់ឆ្នេរសមុទ្រ និងតំបន់បឹងទន្លេសាប ទូក គឺជាមធ្យោបាយដឹកជញ្ជូនដ៏ពេញនិយមដែរ ដោយអត្រាភូមិបានប្រើប្រាស់ទូកមាន ៧៥ ភាគរយ នៅខេត្តកោះកុង ៦៣ ភាគរយ ខេត្តស្ទឹងត្រែង និង ៦១ ភាគរយ ខេត្តកែប។ ផ្ទុយទៅវិញ ៣២ ភាគរយនៃភូមិក្នុងខេត្តកំពង់ចាម និង ២៦ ភាគរយ នៃភូមិក្នុងខេត្តកំពង់ធំ មានការប្រើប្រាស់រទេះសេះ/រទេះគោខ្ពស់ផងដែរ។

## ២.៩- ផ្លូវជាតិ និង ទីផ្សារ

មធ្យោបាយធ្វើដំណើរតាមដងផ្លូវ ជាពិសេសតាមរយៈផ្លូវដែលយានយន្តអាចបើកបរបាន គឺមានសារៈសំខាន់សម្រាប់គ្រួសារកសិកម្មក្នុងការទទួលបានទីផ្សារ និងការធ្វើដំណើរ។ លទ្ធផលពីការធ្វើជំរឿនបង្ហាញថាទូទាំងប្រទេសមានភូមិ ៦១ភាគរយ ស្ថិតនៅចម្ងាយ ០-៤ គីឡូម៉ែត្រពីផ្លូវជាតិដែលនៅជិតបំផុត។ លើសពីនេះទៀត ១៤ ភាគរយនៃភូមិ ស្ថិតនៅចន្លោះពី ៥-៩គីឡូម៉ែត្រ ខណៈ ២៥ភាគរយ មានចម្ងាយឆ្ងាយជាង ១០គីឡូម៉ែត្រ ឬលើសពីនេះពីផ្លូវជាតិដែលនៅជិតបំផុត។

ខេត្តចំនួនប្រាំ គឺខេត្តព្រះសីហនុ ខេត្តកែប ខេត្តប៉ៃលិន រាជធានីភ្នំពេញ និងខេត្តកណ្តាល មានភូមិជាង ៧៥ ភាគរយ នៅជិតផ្លូវជាតិ។ ផ្ទុយទៅវិញ ខេត្តស្ទឹងត្រែង ខេត្តព្រៃវែង ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តកោះកុង និងខេត្តព្រះវិហារ យ៉ាងហោចណាស់មាន ៣០ភាគរយ នៃភូមិរបស់ពួកគេស្ថិតនៅចម្ងាយផ្លូវជាង ១០គីឡូម៉ែត្រឡើងទៅពីផ្លូវជាតិ។

ផ្លូវជាតិមានសារៈសំខាន់សម្រាប់សហគមន៍ជនបទ ងាយស្រួលទៅកាន់ទីផ្សារក្នុងការទិញនូវធាតុចូលផលិតកម្មដូចជា ពូជ ជី និងថ្នាំកសិកម្ម និងលក់ផលិតផលកសិកម្មរបស់ពួកគេទាន់ពេលវេលា។ ទិន្នន័យបានបង្ហាញថា មានតែភូមិ ៩ ភាគរយ ប៉ុណ្ណោះដែលមានផ្សារសាធារណៈនៅទូទាំងប្រទេស។ ខេត្តពោធិ៍សាត់ (៣ភាគរយ) ខេត្តស្វាយរៀង (៤,៦ភាគរយ) និងខេត្តស្ទឹងត្រែង (៥ភាគរយ) ប្រើប្រាស់ផ្សារសាធារណៈតិចតួចបំផុត។

រូបទី២.២ ភាគរយភូមិដែលរាយការណ៍ពីចម្ងាយពីភូមិទៅផ្លូវជាតិដែលនៅជិតបំផុត បែងចែកតាមតំបន់




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣*

## ២.១០- មធ្យោបាយទំនាក់ទំនង

ប្រព័ន្ធទូរសព្ទដៃ និងអ៊ីនធឺណិត គឺជាមធ្យោបាយសំខាន់សម្រាប់ទំនាក់ទំនងដ៏ពេញនិយមក្នុងពិភពលោកនាពេលបច្ចុប្បន្ន។ ប្រទេសនានាកំពុងរីកចម្រើនយ៉ាងឆាប់រហ័សក្នុងការប្រើប្រាស់បច្ចេកវិទ្យាវៃឆ្លាតសម្រាប់មធ្យោបាយទំនាក់ទំនង។ ការទទួលបានព័ត៌មានកសិកម្មទាន់ពេលវេលា គឺមានសារៈសំខាន់សម្រាប់ការបង្កើនផលិតភាពដំណាំ និងការធ្វើពាណិជ្ជកម្មលើដំណាំកសិកម្ម និងកសិដ្ឋានចិញ្ចឹមសត្វ។

ទិន្នន័យដែលប្រមូលបានពីការធ្វើជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣ លើមធ្យោបាយសម្រាប់ទំនាក់ទំនងបង្ហាញថា ទូរសព្ទដៃត្រូវបានប្រើប្រាស់នៅក្នុងភូមិចំនួន ៩២ភាគរយ នៅទូទាំងប្រទេសខណៈដែលការប្រើប្រាស់អ៊ីនធឺណិតមាននៅក្នុងភូមិចំនួន ៣០ភាគរយ។ អត្រាប្រើប្រាស់ទូរសព្ទដៃបានកើនឡើងយ៉ាងខ្លាំង ហើយជាង ៩០ភាគរយ នៃភូមិទាំងអស់មានទូរសព្ទដៃប្រើប្រាស់។ ផ្ទុយទៅវិញ ការប្រើប្រាស់អ៊ីនធឺណែតមានការខុសគ្នាខ្លាំង។ ខេត្តចំនួនបី គឺខេត្តកែប ៧២ភាគរយ រាជធានីភ្នំពេញ ៦៩ភាគរយ និងខេត្តព្រះសីហនុ ៦០ភាគរយ ភូមិដែលមានអ៊ីនធឺណិតប្រើប្រាស់។ ចំណែកខេត្តផ្សេងទៀតការប្រើប្រាស់ទាបជាង ៤០ភាគរយ ខេត្តស្វាយរៀង មានអត្រាទាបត្រឹម ១៨ភាគរយ តែប៉ុណ្ណោះ។

ទិន្នន័យបង្ហាញពីការធ្លាក់ចុះ  នៃការប្រើប្រាស់មធ្យោបាយទំនាក់ទំនងបែបប្រពៃណី ដូចជាប៉ុស្តិ៍ប្រៃសណីយ៍ (កន្លែងផ្ញើសំបុត្រ)។ នៅទូទាំងប្រទេសមានភូមិប្រហែល ២ ភាគរយ ប៉ុណ្ណោះដែលប្រើប្រាស់សេវាប្រៃសណីយ៍កម្ពុជា។ គួរកត់សម្គាល់ថាខេត្តប៉ៃលិនមិនមានភូមិណាមួយបានរាយការណ៍អំពីការប្រើប្រាស់សេវាប្រៃសណីយ៍ទេ ហើយមានតែភូមិមួយក្នុងខេត្តកែប ប៉ុណ្ណោះដែលរាយការណ៍ថាមានប្រើប្រាស់សេវានេះ។ ផ្ទុយទៅវិញ ភូមិប្រមាណ ៩ភាគរយ មានសេវាឯកជន (កន្លែងផ្ញើ ឯកសារ និងទំនិញ)។ ខេត្តព្រះសីហនុមានភាគរយខ្ពស់ជាងគេ ភូមិចំនួន ៤៣ភាគរយ ប្រើប្រាស់សេវាឯកជន (កន្លែងផ្ញើឯកសារ និងទំនិញ) ខណៈដែលនៅខេត្តស្វាយរៀង មានអត្រាភាគរយត្រឹម ៣ភាគរយ តែប៉ុណ្ណោះ។

## ២.១១- សេវាសុខាភិបាល និង ការអប់រំ

ប៉ុស្តិ៍សុខភាព ឬមណ្ឌលសុខភាព និងមន្ទីរពេទ្យរដ្ឋ គឺជាស្ថាប័នចម្បងដែលផ្តល់សេវាសុខភាពជាមូលដ្ឋាននៅក្នុងប្រទេស។ ប្រជាជននៅតាមជនបទភាគច្រើន គឺពឹងផ្អែកលើប៉ុស្តិ៍សុខភាព និងមណ្ឌលសុខភាព ដើម្បីព្យាបាលបញ្ហាសុខភាពទាន់ពេលវេលា។ ទោះយ៉ាងណាក៏ដោយ ការបែងចែកសេវាសុខភាពទាំងនេះនៅមិនគ្រប់គ្រាន់ទេ ដោយភូមិភាគច្រើនខ្វះកន្លែងផ្តល់សេវាថែទាំសុខភាព។  ក្នុងចំណោមភូមិដែលឆ្លើយថាមានប្រើប្រាស់កន្លែងផ្តល់សេវាសុខភាពនៅទូទាំងប្រទេស ក្នុងនោះមានអត្រា ១១ ភាគរយ ដែលរាយការណ៍ថាការប្រើប្រាស់សេវាមណ្ឌលសុខភាពមាន៤ភាគរយ ប៉ុស្តិ៍សុខភាព និងមានត្រឹមតែ ២ ភាគរយដែលប្រើសេវាមន្ទីរពេទ្យជាតិ/មន្ទីរពេទ្យបង្អែក។ ផ្ទុយទៅវិញ គ្លីនិកឯកជនមាននៅក្នុងភូមិមានប្រមាណ ១៨ ភាគរយ ហើយមន្ទីរពេទ្យឯកជន ត្រូវបានបង្ហាញមានប្រមាណ ៦ភាគរយ។

មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព មានទំនោរប្រមូលផ្តុំនៅតំបន់ឆ្នេរសមុទ្រ តំបន់ភ្នំ និងខ្ពង់រាប ក្នុងនោះមន្ទីរពេទ្យឯកជន គ្លីនិកឯកជន និងគ្លីនិករបស់អង្គការមិនមែនរដ្ឋាភិបាល ភាគច្រើនមានទីតាំងនៅក្នុងរាជធានីភ្នំពេញ និង ខេត្តព្រះសីហនុ។

## រូបទី២.៣ ចំនួនភូមិដែលមានកន្លែងផ្តល់សេវាសុខភាពនៅប្រទេសកម្ពុជា




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣*

សាលារៀនសរុបមានចំនួន ១៧ ៤១៥ ទីតាំង នៅគ្រប់កម្រិតសិក្សាទាំងអស់ចាប់ពីសាលាមត្តេយ្យសិក្សាដល់មហាវិទ្យាល័យ/សាកលវិទ្យាល័យ ដែលចំនួនទាំងនេះត្រូវបានរាយការណ៍ពីភូមិនៅទូទាំងប្រទេស។ ប្រភេទសាលាត្រូវបានរាប់បញ្ចូលគ្នាផងដែរទាំងសាលារដ្ឋ និងសាលាឯកជន។ ក្នុងចំណោមសាលារៀននោះ មានប្រមាណ ៦ ៨៨៣ បានរាយការណ៍ថាជាសាលាមត្តេយ្យសិក្សា (៤០ ភាគរយ) ហើយប្រមាណ ៧ ៩៩៥ ជាសាលាបឋមសិក្សា (៤៤ ភាគរយ) ប្រមាណ ១ ៩០៨ ជាអនុវិទ្យាល័យ (១១ ភាគរយ) ប្រមាណ ៦២២ ជាវិទ្យាល័យ (៤ ភាគរយ) ប្រមាណ ១០០ ជាមហាវិទ្យាល័យ/សាកលវិទ្យាល័យ (១ ភាគរយ) និងមានចំនួនប្រមាណ ៣០៧ (២ ភាគរយ) ត្រូវបានរាយការណ៍ថាជាសាលាផ្សេងទៀត។

បើនិយាយពីភូមិដែលមានគ្រឹះស្ថានសិក្សា គឺមាន ៤៥ ភាគរយ នៃភូមិសរុបទាំងអស់នៅទូទាំងប្រទេសកម្ពុជា ក្នុងនោះមានមត្តេយ្យសិក្សា ៥០ ភាគរយ បឋមសិក្សា ១៣ ភាគរយ មធ្យមសិក្សា ៤ ភាគរយ និងមានប្រមាណជា ២ ភាគរយ ត្រូវបានរាយការណ៍ថាជាគ្រឹះស្ថានសិក្សាផ្សេងទៀត។

ក្នុងចំណោមសាលាបឋមសិក្សាចំនួន ៧ ៩៩៥ មាន ៣ ០៦៤ ស្ថិតក្នុងភូមិដែលនៅជុំវិញតំបន់បឹងទន្លេសាប។ មានប្រហែល (៩១ ភាគរយ) នៃភូមិក្នុងខេត្តស្ទឹងត្រែងមានសាលាបឋម

សិក្សាដែលធ្វើឱ្យខេត្តនេះជាខេត្តដែលមានសាលាបឋមសិក្សាខ្ពស់ជាងគេ។ ផ្ទុយទៅវិញ ខេត្តកំពង់ស្ពឺ មានសាលាបឋមសិក្សាតិចជាងគេមានតែ (២៥ ភាគរយ) ភូមិមានសាលារៀនមួយ។

ដូចគ្នានេះដែរ ភូមិនៅតំបន់វាលទំនាបមានអនុវិទ្យាល័យខ្ពស់ជាងគេ ជាមួយនឹងខេត្តកណ្ដាល មានចំនួន១៥៧ គ្រឹះស្ថានសិក្សា។ ដូចគ្នាដែរ ចំនួនវិទ្យាល័យច្រើនជាងគេត្រូវបានបង្ហាញនៅក្នុងតំបន់វាលទំនាប គឺខេត្តតាកែវ មានវិទ្យាល័យចំនួន ៥៥ រាជធានីភ្នំពេញ ៥៤ និងខេត្តកំពង់ចាម ចំនួន ៥១។ មានភូមិចំនួន ៩២ ដែលបានរាយការណ៍ថាមានមហាវិទ្យាល័យ/សាកលវិទ្យាល័យសរុបចំនួន ១០០។ មហាវិទ្យាល័យ/សាកលវិទ្យាល័យមានទីតាំងជាចម្បងនៅក្នុងតំបន់ទីក្រុង ដូចជារាជធានីភ្នំពេញ និងខេត្តបាត់ដំបង។

រូបទី២.៤ ភូមិដែលបានរាយការណ៍ពីចំនួនគ្រឹះស្ថានសិក្សា បែងចែកតាមកម្រិតសិក្សា នៅប្រទេសកម្ពុជា




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣*

## ២.១២- ប្រភពទឹកប្រើប្រាស់

ការទាញយកប្រភពទឹកពីធម្មជាតិសម្រាប់យកមកធ្វើពាណិជ្ជកម្មរួមមាន ទឹកបណ្ដាញ អណ្ដូងស្នប់/អណ្ដូងខួង អណ្ដូងជីកមានលូការពារ(គម្របការពារ) និងអណ្ដូងជីកគ្មានលូការពារ (គ្មានគម្រប) ទន្លេ ស្រះ ជ្រោះ ព្រែក ស្ទឹង និងទឹកភ្លៀង។ ទិន្នន័យជំរឿនកសិកម្មកម្ពុជានៅឆ្នាំ២០២៣ បានបង្ហាញថា អណ្ដូងស្នប់/អណ្ដូងខួង គឺជាប្រភពទឹកចម្បងនៅក្នុងប្រទេស ដែលមានប្រមាណ ៦៨ ភាគរយ នៃចំនួនភូមិដែលបានរាយការណ៍ថាពួកគេមានប្រភពទឹកសម្រាប់

ទទួលទានពីអណ្តូងស្នប់/អណ្តូងខួង បន្ទាប់ ៤៨ ភាគរយ ទឹកបណ្តាញ ៣៨ ភាគរយ ទឹកទន្លេ ស្រះ ជ្រោះ ព្រែក ស្ទឹង។ ភូមិមានប្រមាណ ៣២ ភាគរយពីអណ្តូងជីកមានលូការពារ (គម្រប ការពារ) និង មានអត្រា ១៩ ភាគរយ ពីអណ្តូងជីកគ្មានលូការពារ (គ្មានគម្រប)។

ភូមិមួយអាចមានប្រភពទឹកស្អាតសម្រាប់ទទួលទានពីប្រភពផ្សេងៗ ៦៦ ភាគរយ នៅតែ បន្តការប្រើប្រាស់ទឹកភ្លៀងសម្រាប់ទទួលទានរបស់ពួកគេ។ ដោយឡែកទឹកបណ្តាញត្រូវបាន គេចាត់ទុកថាជាប្រភពទឹកស្អាតដែរបើធៀបនឹងប្រភពធម្មជាតិផ្សេងទៀត។ តំបន់ឆ្នេរសមុទ្រមាន ការប្រើប្រាស់ទឹកបណ្តាញទាបប៉ុន្តែការប្រើប្រាស់ទឹកខ្ពស់នៅប្រភពផ្សេងទៀតរួមមានអណ្តូង ជីកមានលូការពារ (គម្របការពារ) អណ្តូងជីកគ្មានលូការពារ (គ្មានគម្រប) និងទឹកដប/ទឹកទិញ។

ទោះបីទឹកដប/ទឹកទិញមិនមែនជាប្រភពទឹកសំខាន់សម្រាប់គ្រួសារកសិកម្មក៏ដោយ វាមាន នៅស្ទើរតែគ្រប់ភូមិទាំងអស់។ ប្រហែល ៨៥ ភាគរយភូមិបានរាយការណ៍ថាមានការប្រើប្រាស់ ទឹកដប/ទឹកទិញមានជាង ៩២ ភាគរយនៅតំបន់ឆ្នេរសមុទ្របានប្រើប្រាស់ទឹកដប/ទឹកទិញសម្រាប់ ទទួលទានរបស់ពួកគេ។

## ២.១៣- អង្គការ/សមាគម

អង្គការ/សមាគមរួមបញ្ចូលទាំងវត្តមានបុគ្គលិកអង្គការ/សមាគម និងសមាគមកសិករ ដើរតួនាទីយ៉ាងសំខាន់ក្នុងការតំណាងផលប្រយោជន៍របស់សមាគមកសិករក្នុងស្រុកនៅតំបន់ ជនបទ។ ក្រុមទាំងនេះមានអង្គការដើម្បីស្ត្រី សមាគមកសិករ សមាគមអ្នកនេសាទ និងសហករណ៍ កសិករ/ចិញ្ចឹមសត្វ/នេសាទដើម្បីជួយលើកកម្ពស់កសិករជាមួយរដ្ឋាភិបាល និងការសម្របសម្រួល ការផ្លាស់ប្តូរជំនាញបទពិសោធដើម្បីអនុវត្តលើវិស័យកសិកម្ម។

នៅក្នុងប្រទេសកម្ពុជាចំនួនភូមិសរុបមាន ១៤ ០២១ ក្នុងនោះមានចំនួន ៥ ២៣៥ ភូមិ (៣៧ភាគរយ) បានរាយការណ៍អំពីវត្តមានបុគ្គលិករបស់អង្គការ/សមាគម។ អង្គការដើម្បីស្ត្រី មានចំនួនខ្ពស់ជាងគេគឺមាន ៦,៨ ភាគរយ បន្ទាប់មកសមាគមកសិកររកឃើញនៅក្នុងភូមិមាន ៦,៧ ភាគរយសមាគមកសិករប្រើប្រាស់ទឹក ៥,៤ ភាគរយ សមាគមអ្នកចិញ្ចឹមសត្វមាន ៤,៦ ភាគរយ សមាគមអ្នកនេសាទមាន ២,៤ ភាគរយ សហករណ៍កសិករ/ចិញ្ចឹមសត្វ/នេសាទ មាន ២ ភាគរយ។

ខេត្តបាត់ដំបង មានភូមិចំនួន ១៥០ ដែលបានរាយការណ៍ថាមានវត្តមានបុគ្គលិករបស់ អង្គការដើម្បីស្ត្រីខ្ពស់ជាងគេ ចំណែកខេត្តកែប មិនមានភូមិណាមួយដែលមានអង្គការដើម្បីស្ត្រី នេះទេ។ លើសពីនេះ នៅខេត្តបាត់ដំបង មានចំនួនភូមិច្រើនកាន់តែមានការប្រមូលផ្តុំវត្តមាន

បុគ្គលិកអង្គការ/សមាគម និងសមាគមកសិករគ្រប់ប្រភេទរួមទាំងអង្គការដើម្បីស្ត្រីដែរ។ ទន្ទឹមនឹងនេះ អង្គការ/សមាគមកសិករទាំងនេះ មានភូមិប្រមាណ ៦ ភាគរយ បានរាយការណ៍អំពីវត្តមានបុគ្គលិករបស់អង្គការខាងវិស័យឯកជន ៣ ភាគរយ មានវត្តមានសមាគម សហគមន៍ផ្សេងទៀត។

រូប២.៥ ចំនួនភូមិដែលបានរាយការណ៍ពីវត្តមានបុគ្គលិកអង្គការ បែងចែកតាមតំបន់




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

# ជំពូកទី៣

# ការកាន់កាប់កសិកម្ម និង ការកាន់កាប់ដី

ជំរឿនកសិកម្មនៅប្រទេសកម្ពុជាឆ្នាំ២០២៣ បានឱ្យអត្ថន័យនៃការកាន់កាប់កសិកម្មថា គឺជាអង្គភាពសេដ្ឋកិច្ចមួយស្ថិតក្រោមការគ្រប់គ្រងដែលយ៉ាងហោចណាស់មានមួយក្នុងចំណោមចរិតលក្ខណៈដូចខាងក្រោម៖

- មានទំហំផ្ទៃដីយ៉ាងតិច ៣០០ ម៉ែត្រការ៉េ ( ឬ ០,០៣ ហិកតា) ដែលបានប្រើប្រាស់ផ្ទៃដីទាំងស្រុង ឬក៏មួយផ្នែកណាមួយសម្រាប់ផលិតកម្មកសិកម្ម និង/ឬ
- មានបសុសត្វប្រភេទធំចំនួន ២ និង/ឬ
- មានបសុសត្វប្រភេទតូចចំនួន ៣ និង/ឬ
- មានបសុបក្សីចំនួន ២៥។

ការកាន់កាប់កសិកម្មទាំងនេះ អាចមានតែការដាំដំណាំ ឬអាចមានតែការចិញ្ចឹមបសុសត្វ ឬអាចមានតែការចិញ្ចឹមបសុបក្សី។ លើសពីនេះទៅទៀតក៏អាចមានការកាន់កាប់រួមបញ្ចូលគ្នាទាំងការដាំដំណាំ និងបសុសត្វប្រភេទធំ ឬបសុសត្វប្រភេទតូច ឬបសុបក្សី។

ជំរឿនកសិកម្មនៅប្រទេសកម្ពុជាឆ្នាំ២០២៣ ត្រូវបានចែកចេញជាពីរប្រភេទគឺ៖

១. ការកាន់កាប់កសិកម្មគ្រួសារ គឺជាការគ្រប់គ្រងដោយគ្រួសារផ្ទាល់ខ្លួននីមួយៗ
២. ការកាន់កាប់កសិកម្មគតិយុត្តិ គឺជាការគ្រប់គ្រងដោយសហគ្រាសកសិកម្មខ្នាតធំដែលបានគ្រប់គ្រងដោយរដ្ឋ ឬឯកជន មានដូចជា សហករណ៍ ដៃគូសហករណ៍ស្ថាប័នឯកជន ស្ថាប័នរដ្ឋជាដើម។

ចំណាត់ថ្នាក់នេះផ្តល់នូវទិដ្ឋភាពទូលំទូលាយ នៃទិដ្ឋភាពកសិកម្មរបស់ប្រទេសកម្ពុជា ដែលឆ្លុះបញ្ចាំងទាំងប្រតិបត្តិការគ្រួសារខ្នាតតូច និងសហគ្រាសកសិកម្មខ្នាតធំៗ។

## ៣.១- គ្រួសារកាន់កាប់កសិកម្ម

លំនៅឋានរបស់គ្រួសារកាន់កាប់កសិកម្ម ត្រូវបានឱ្យដឹងថាមានផ្ទៃដីនៅជុំវិញបរិវេណលំនៅឋានជាចម្បង។ សកម្មភាពនៃការកាន់កាប់របស់គ្រួសារកសិកម្មនៅកម្ពុជានេះ ត្រូវបានចែកចេញជាបីប្រភេទគឺ ក)-សកម្មភាពកសិកម្មនៅក្នុងបរិវេណជុំវិញលំនៅឋានតែប៉ុណ្ណោះ ខ)-សកម្មភាពកសិកម្មនៅលើដីដែលបានចែកដាច់ដោយឡែកពីបរិវេណជុំវិញលំនៅឋាន

គ)-សកម្មភាពកសិកម្មនៅក្នុងបរិវេណជុំវិញលំនៅឋានរួមជាមួយនឹងការធ្វើកសិកម្មនៅលើក្បាលដីដាច់ដោយឡែក។

ជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ បានបង្ហាញថាមានចំនួនគ្រួសារកសិកម្មប្រមាណ ១ ៨៤៩ ៨០៤ គ្រួសារ បានធ្វើប្រតិបត្តិការលើផ្ទៃដីកសិកម្មសរុបប្រមាណ ៣ ១៨១ ៩០៦ ហិកតា ដែលជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៣ មានការកាន់កាប់កសិកម្មចំនួន ២ ១២៩ ១៤៩ ធ្វើប្រតិបត្តិការលើផ្ទៃដីកសិកម្មសរុប ៣ ៣០៤ ៧៣៨ ហិកតា។ នេះបានឆ្លុះបញ្ចាំងពីការធ្លាក់ចុះនៃគ្រួសារកសិកម្មចំនួន ២៧៩ ៣៤៥ គ្រួសារ និងផ្ទៃដីកសិកម្មថយចុះចំនួន ១២២ ៨៣២ ហិកតា ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ។

រូប៣.១ ចំនួននិងផ្ទៃដីកាន់កាប់នៃគ្រួសារកសិកម្មនៅប្រទេសកម្ពុជា




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣*

ក្នុងចំណោមគ្រួសារកសិកម្មមានចំនួន១,៨ លានគ្រួសារ មានគ្រួសារប្រមាណ១,៧ លានគ្រួសារ (៩០ភាគរយ) ដែលបានរាយការណ៍ថា មានដីកសិកម្មដាច់ដោយឡែកពីបរិវេណជុំវិញលំនៅឋានរបស់គាត់ (៥៦៨ ៥៤០ គ្រួសារ) ឬនៅជុំវិញលំនៅឋាន(១ ០៩៤ ៩៤២ គ្រួសារ) លើផ្ទៃដីសរុបចំនួន ៣,១៧ លានហិកតា ត្រូវបានប្រើប្រាស់សម្រាប់ដាំដំណាំ។ ដែលមាន ៩៩ ភាគរយ នៃផ្ទៃដីសរុប (៣,១៨ លានហិកតា) ដែលបានធ្វើសកម្មភាពកសិកម្មនៅទូទាំងប្រទេស។ ផ្ទុយទៅវិញគ្រួសារកាន់កាប់កសិកម្មចំនួន ១៥៤ ១០២ គ្រួសារ (៨ ភាគរយ) បានធ្វើសកម្មភាព

កសិកម្មតែនៅលើដីជុំវិញលំនៅឋានរបស់គាត់តែប៉ុណ្ណោះ ដោយមិនមានក្បាលដីដាច់ដោយឡែកនោះទេ។ ផ្ទៃដីកសិកម្មសរុបនៃគ្រួសារទាំងនោះមាន ១៦ ១០១ ហិកតា។

**តារាង៣.១ ចំនួនផ្ទៃដីនិងគ្រួសារកាន់កាប់កសិកម្ម**

| ប្រភេទទិន្នន័យ | ចំនួនគ្រួសារ | ផ្ទៃដី (ហិកតា) |
|---|---|---|
| គ្រួសារកាន់កាប់កសិកម្មសរុប | ១ ៨៤៩ ៨០៤ | ៣ ១៨១ ៩០៦ |
| គ្រួសារកសិកម្មមានក្បាលដី និងដីជុំវិញលំនៅឋាន | ១ ០៩៤ ៩៤២ | ២ ០០៥ ៣៨៣ |
| គ្រួសារកសិកម្មដែលមានតែក្បាលដី | ៥៦៨ ៥៤០ | ១ ១៦០ ៤២២ |
| គ្រួសារកសិកម្មដែលមានតែដីជុំវិញលំនៅឋាន | ១៥៤ ១០២ | ១៦ ១០១ |
| គ្រួសារគ្មានដីកសិកម្ម | ៣២ ២២០ | ០ |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

## ៣.២- ទំហំនៃការកាន់កាប់កសិកម្ម

ក្នុងចំណោមគ្រួសារកសិកម្ម ១,៨ លាននៅទូទាំងប្រទេសមានគ្រួសារកសិកម្មប្រមាណ ៤៨ ភាគរយ មានផ្ទៃដីតិចជាង ១ ហិកតា ប្រមាណ ២៣ ភាគរយ មានផ្ទៃដីចន្លោះពី ១ ទៅ ១,៩ ហិកតា ហើយប្រមាណ ២២ ភាគរយ មានផ្ទៃដីចន្លោះពី ២ ទៅ ៤,៩ ហិកតា ៦ភាគរយ មានផ្ទៃដីចន្លោះពី ៥ ទៅ ៩,៩ ហិកតា និងប្រមាណ ២ ភាគរយ មានទំហំផ្ទៃដីចាប់ពី ១០ ហិកតាឡើងទៅ។ ជារួមមានគ្រួសារកាន់កាប់កសិកម្មប្រមាណ ៧១ ភាគរយ បានធ្វើសកម្មភាពកសិកម្មលើទំហំផ្ទៃដីតិចជាង ២ ហិកតានៅក្នុងប្រទេសកម្ពុជា។

បើយើងពិនិត្យមើលកម្រិតទំហំដីតាមបណ្តារាជធានី ខេត្ត ឃើញថា រាជធានីភ្នំពេញមានទំហំដីតិចជាង ១ ហិកតា សមាមាត្រគ្រួសារច្រើនជាងគេរហូតដល់ទៅ (៨៨ ភាគរយ) ចំពោះខេត្តពោធិ៍សាត់វិញមានទំហំដីចន្លោះពី ១ ទៅ ១,៩ ហិកតា ភាគរយគ្រួសារច្រើនជាងគេ (៣០ ភាគរយ) ចំណែកឯខេត្តព្រះវិហារនាំមុខក្នុងសមាមាត្រ (៥៤ ភាគរយ) នៃគ្រួសារមានទំហំដីចន្លោះពី ២ទៅ ៤,៩៩ ហិកតា។ ខេត្តព្រះវិហារ រតនគិរី និងឧត្តរមានជ័យ មានការកាន់កាប់ដីកសិកម្មចាប់ពី ៥ ហិកតាឡើងទៅ (៣០ ភាគរយ) ដែលនេះជាចំនួនខ្ពស់ជាងគេបើប្រៀបធៀបគ្នានៅទូទាំងប្រទេស។

រូបទី៣.២ ភាគរយនៃគ្រួសារកសិកម្មដោយបែងចែកតាមទំហំដី នៅប្រទេសកម្ពុជា




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

បើពិនិត្យមើលលើការបែងចែកតាមប្រភេទដីនៃគ្រួសារកាន់កាប់កសិកម្មវិញ ឃើញថាមាននិន្នាការស្រដៀងគ្នានៅកម្រិតថ្នាក់ជាតិ។ ក្នុងចំណោមគ្រួសារកាន់កាប់កសិកម្មដែលមានក្បាលដីផង និងដីជុំវិញលំនៅឋានផងប្រមាណ ៤៣ ភាគរយ មានផ្ទៃដីតិចជាង ១ ហិកតា ប្រមាណ ៤៦ភាគរយ មានផ្ទៃដីចន្លោះពី ១ ទៅ ៣,៩៩ហិកតា ប្រមាណ ៩ភាគរយ មានផ្ទៃដីចន្លោះពី ៤ ទៅ ៩,៩៩ ហិកតា និងប្រមាណជា ២ភាគរយទៀត គឺមានផ្ទៃដីចាប់ពី ១០ ហិកតាឡើង។ ទន្ទឹមគ្នានេះដែរ ក្នុងចំណោមគ្រួសារកាប់កសិកម្មដែលមានតែក្បាលដីប្រមាណ ៤១ភាគរយ មានផ្ទៃដីតិចជាង ១ហិកតា ៤៥ភាគរយ មានផ្ទៃដីចន្លោះពី ១ ទៅ ៣,៩ហិកតា ១២ភាគរយ មានផ្ទៃដីចន្លោះពី ៤ ទៅ ៩,៩ហិកតា និង ២ ភាគរយមានផ្ទៃដីចាប់ពី ១០ហិកតាឡើងទៅ។ ចំពោះគ្រួសារកាន់កាប់គ្រួសារកសិកម្មដែលមានតែនៅលើដីជុំវិញលំនៅឋាន ស្ទើរតែទាំងអស់ (៩៩,៨ ភាគរយ) គឺមានផ្ទៃដីតិចជាង ១ហិកតា។




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

នៅប្រទេសកម្ពុជាមានគ្រួសារកាន់កាប់កសិកម្មចំនួន ១ ៨៤៩ ៨០៤ គ្រួសារដែលកំពុងបានធ្វើប្រតិបត្តិការលើផ្ទៃដីកសិកម្មសរុបចំនួន ៣ ១៨១ ៩០៦ ហិកតា ហើយមានទំហំដីជាមធ្យម ១,៧២ ហិកតា ក្នុងមួយគ្រួសារកាន់កាប់។ គ្រួសារកាន់កាប់កសិកម្មនៅតំបន់ភ្នំ និងខ្ពង់រាប និងតំបន់បឹងទន្លេសាបមានទំហំដីជាមធ្យមលើសពីកម្រិតថ្នាក់ជាតិ ខណៈដែលនៅតំបន់វាលទំនាប និងតំបន់ឆ្នេរសមុទ្រមានទំហំដីជាមធ្យមតូចជាងកម្រិតថ្នាក់ជាតិ។ ក្នុងចំណោមរាជធានី ខេត្តទាំង២៥ ខេត្តព្រះវិហារគឺជាខេត្តដែលមានទំហំដីជាមធ្យមធំជាងគេ ៤,៣ ហិកតា ក្នុងមួយគ្រួសារ ខុសពីខេត្តកោះកុងដែលមានទំហំដីជាមធ្យមតូចជាងគេគឺ ០,៦ ហិកតា ក្នុងមួយគ្រួសារកាន់កាប់កសិកម្ម។

តាមប្រភេទនៃការកាន់កាប់ដី គ្រួសារកសិកម្មដែលមានដីទាំងពីរគឺក្បាលដី និងដីជុំវិញលំនៅឋានមានទំហំដីជាមធ្យម ១,៨ ហិកតាក្នុងមួយគ្រួសារកាន់កាប់។ សម្រាប់គ្រួសារដែល

មានតែក្បាលដីប៉ុណ្ណោះគឺមានទំហំដីជាមធ្យមធំជាងគេគឺ ២ ហិកតាក្នុងមួយគ្រួសារកាន់កាប់ប៉ុន្តែបើគ្រួសារកសិកម្មមានតែដីជុំវិញលំនៅឋានតែប៉ុណ្ណោះមានទំហំដីជាមធ្យមតូចជាងគេគឺ ០,១ ហិកតាក្នុងមួយគ្រួសារកាន់កាប់។

នៅកម្រិតថ្នាក់ខេត្ត ខេត្តឧត្តរមានជ័យគឺជាខេត្តដែលមានទំហំដីជាមធ្យមខ្ពស់ជាងគេ (៤,៦ហិកតា) ក្នុងមួយគ្រួសារកាន់កាប់កសិកម្ម ខណៈដែលខេត្តកែបមានទំហំដីជាមធ្យមតូចជាងគេ (០,៨ហិកតា) សម្រាប់គ្រួសារដែលមានដីទាំងក្បាលដីនិងដីជុំវិញលំនៅឋាន។ បើយើងពិនិត្យលើគ្រួសារដែលមានតែក្បាលដីវិញ គឺខេត្តប៉ៃលិនមានទំហំដីជាមធ្យមខ្ពស់ជាងគេ ៤,៥ ហិកតាក្នុងមួយគ្រួសារ ខណៈដែលខេត្តកំពង់ស្ពឺមានទំហំដីជាមធ្យមតូចជាងគេ ០,៧ ហិកតាក្នុងមួយគ្រួសារកាន់កាប់កសិកម្ម។

## ៣.៣- គ្រួសារកាន់កាប់ដីកសិកម្ម ក្បាលដី និងដីជុំវិញលំនៅឋាន

ការកាន់កាប់កសិកម្មនៅក្នុងប្រទេសកម្ពុជាជាទូទៅ ត្រូវបានបង្កើតឡើងជាច្រើនចំណែកនៃផ្ទៃដីហៅថា "ក្បាលដី" ត្រូវបានកំណត់និយមន័យថា គឺជាចំណែកដីទាំងឡាយណាដែលស្ថិតនៅក្រោមការកាន់កាប់មួយប្រភេទ ពោលគឺសិទ្ធិក្នុងការប្រើប្រាស់ដីសម្រាប់គោលបំណងកសិកម្មដែលហ៊ុមព័ទ្ធទាំងស្រុងដោយដីអ្នកផ្សេងទៀត ឬទឹក ឬផ្លូវ ឬព្រៃឈើ ឬលក្ខណៈពិសេសផ្សេងទៀតមិនបានបង្កើតជាផ្នែកមួយនៃការកាន់កាប់នោះទេ អាចជាវាល ឬដីមួយឬច្រើន ដែលនៅជាប់ៗគ្នា។

រូប៣.៤ ភាគរយនៃគ្រួសារកាន់កាប់ផ្ទៃដីកសិកម្ម បែងចែកតាមចំនួនក្បាលដី នៅប្រទេសកម្ពុជា




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

ចំនួន ៩៧ ភាគរយ នៃគ្រួសារកាន់កាប់កសិកម្មនៅប្រទេសកម្ពុជា បានរាយការណ៍ថា ធ្វើកសិកម្មនៅក្នុងក្បាលដីចន្លោះពី ១ ក្បាលដី ទៅ ៣ ក្បាលដី។ គ្រួសារប្រមាណ ១,៧ លាន គ្រួសារបានចែកដីកសិកម្មដោយឡែកពីគ្នាមានរហូតដល់ទៅ ២,៤ លានក្បាលដី។ ចំនួនក្បាលដី សរុបឡើងដល់ទៅ ៣,៦ លានក្បាលដីនៅពេលដែលដីជុំវិញលំនៅឋានត្រូវបានរាប់បញ្ចូល ជាមួយនឹងក្បាលដីដាច់ដោយឡែកពីគ្នា។ មានប្រមាណ ៣៥ ភាគរយនៃក្បាលដីទាំងអស់ គឺ មានទីតាំងនៅជាមួយដីជុំវិញលំនៅឋានរបស់គ្រួសារកាន់កាប់កសិកម្ម។ ជាទូទៅទំហំក្បាលដី ជាមធ្យម មិនរាប់បញ្ចូលជាមួយដីជុំវិញលំនៅឋានគឺ ១,៣ ហិកតា ក្នុងមួយក្បាលដី ប៉ុន្តែបើ បញ្ចូលជាមួយដីជុំវិញលំនៅឋានផង គឺថយចុះ ០,៨៨ ហិកតា ក្នុងមួយក្បាលដី។

## ៣.៤- ការប្រើប្រាស់ក្បាលដីជាចម្បង

ការប្រើប្រាស់ក្បាលដីជាចម្បងគឺ សម្រាប់ការដាំដុះដំណាំបណ្ដោះអាសន្នដែលមានវដ្ត នៃការលូតលាស់តិចជាង ១ឆ្នាំ ហើយមានភាគរយតិចជាងសម្រាប់ការដាំដុះដំណាំរយៈពេលវែង ដែលមានវដ្តនៃការលូតលាស់ច្រើនជាង១ឆ្នាំ។ ក្នុងចំណោម ៣,៦ លាន ក្បាលដីមាន ២,៣ លាន (៦៥ ភាគរយ) បានប្រើប្រាស់សម្រាប់ការដាំដុះដំណាំ។ លើសពីនេះការដាំដុះដំណាំជាញឹកញាប់ បានដាំដុះក្នុងដីជុំវិញលំនៅឋានរួមជាមួយនឹងសកម្មភាពកសិកម្មផ្សេងទៀតដូចជា ការចិញ្ចឹម

បសុសត្វ បសុបក្សីជាដើម។ មានប្រមាណ ៥៩ ភាគរយនៃក្បាលដីរបស់គ្រួសារកសិកម្មត្រូវបាន ដាំដុះដំណាំបណ្ដោះអាសន្ន ខណៈដែលមាន ៦ ភាគរយបាន ដាំដុះដំណាំរយៈពេលវែង។ មានប្រមាណ ៣៥ ភាគរយនៃក្បាលដីបានប្រើប្រាស់ជាចម្បងជាមួយលំនៅឋានរបស់គ្រួសារ ទោះបីជាគាត់មានដីជុំវិញលំនៅឋានការប្រើប្រាស់ផ្នែកខ្លះសម្រាប់ការដាំដុះដំណាំ ការចិញ្ចឹមបសុសត្វ បសុបក្សីក៏ដោយ។ មានបរិមាណតិចតួចបំផុតសម្រាប់ក្បាលដីដែលបានប្រើប្រាស់ធ្វើសកម្មភាពកសិកម្មផ្សេងទៀតដូចជា៖ ការដាំដុះវាលស្មៅបណ្ដោះអាសន្ន ឬការចិញ្ចឹមបសុសត្វ បសុបក្សី។

រូប៣.៥ ភាគរយនៃក្បាលដីប្រើប្រាស់ជាចម្បង (រួមទាំងដីជុំវិញលំនៅឋាន) នៅប្រទេសកម្ពុជា




** ការប្រើប្រាស់ដីផ្សេងទៀតរួមមាន ក្បាលដីដែលមានការជួល/ចំណែកដី ក្បាលដីទុកបណ្ដោះអាសន្ន ដីចិញ្ចឹមបសុសត្វ សត្វបក្សី និងដីប្រើប្រាស់ផ្សេងទៀត។ ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

នៅក្នុងការកាន់កាប់កសិកម្មដែលមានក្បាលដីដាច់ដោយឡែក មានប្រមាណ ៩០ ភាគរយនៃក្បាលដីត្រូវបានប្រើប្រាស់សម្រាប់ការដាំដុះដំណាំបណ្ដោះអាសន្ន ខណៈដែលមាន ៨ ភាគរយត្រូវបានបែងចែកសម្រាប់ដំណាំរយៈពេលវែង។ នៅសល់ ២ ភាគរយទៀតត្រូវបានប្រើប្រាស់សម្រាប់គោលបំណងផ្សេងទៀតដូចជា ដីទុកចោលបណ្ដោះអាសន្ន ដីសង់អគារកសិកម្ម និងដីចំការ ដីប្រើសម្រាប់ការចិញ្ចឹមបសុសត្វ និងបសុបក្សី ព្រៃឈើ និងដីព្រៃផ្សេងទៀត។ ទំហំក្បាលដីជាមធ្យមសម្រាប់ដំណាំបណ្ដោះអាសន្នគឺ ១,២ ហិកតា ដែលតូចជាងទំហំមធ្យម ២,៥ ហិកតាសម្រាប់ដំណាំរយៈពេលវែង។ ភាពខុសគ្នានេះគឺដោយសារតែចំនួនក្បាលដីយ៉ាងច្រើនត្រូវបានប្រើប្រាស់ដាំដំណាំបណ្ដោះអាសន្ន។ សម្រាប់ក្បាលដីដែលប្រើជាអគារកសិកម្ម

និងសំយាបក្នុងគ្រួសារកសិកម្មមានក្បាលដីដាច់ដោយឡែកមានទំហំជាមធ្យម ០,៥ ហិកតា។ យ៉ាងណាមិញ ទំហំក្បាលដីជាមធ្យមគឺ ០,១ ហិកតាសម្រាប់ដីជុំវិញលំនៅឋានប្រើប្រាស់ដោយផ្នែកសម្រាប់សកម្មភាពកសិកម្ម។

រូបទី៣.៦ ទំហំក្បាលដីជាមធ្យម (ហិកតា) សម្រាប់ការប្រើប្រាស់ដីជាចម្បងក្នុងគ្រួសារដែលមានដីដាច់ដោយឡែក នៅប្រទេសកម្ពុជា




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

## ៣.៥- សិទ្ធិនៃការកាន់កាប់ក្បាលដី

ក្បាលដីភាគច្រើនរបស់គ្រួសារកសិកម្មបានធ្វើសកម្មភាពកសិកម្មក្រោមកាគ្រប់គ្រងជាម្ចាស់កម្មសិទ្ធិផ្ទាល់ខ្លួនរបស់ពួកគេ។ ក្នុងចំណោមក្បាលដីចំនួន ២ ៣៧១ ៣៦០ នៃគ្រួសារកសិកម្មដែលមានក្បាលដីដាច់ដោយឡែកគឺមាន ៩៩ភាគរយបានរាយការណ៍ថា កាន់កាប់ជាកម្មសិទ្ធិ ឬគ្រប់គ្រងដូចកម្មសិទ្ធិ (កាន់កាប់ដោយស្របច្បាប់ ៩៨ភាគរយ និងមិនស្របច្បាប់១ភាគរយ)។ មានប្រមាណតែ ១ភាគរយ នៃក្បាលដីប៉ុណ្ណោះត្រូវបានជួលពីអ្នកដទៃ ខណៈដែលមានតិចតួចបំផុតប្រមាណ ០,២ភាគរយ ជាប្រភេទកម្មសិទ្ធិដីផ្សេងទៀត។

ដូចគ្នានេះដែរ បើនិយាយពីទំហំផ្ទៃដីវិញមានផ្ទៃដីប្រមាណ ២,៩៨ លានហិកតា ក្នុងចំណោមផ្ទៃដី ៣,០៥ លានហិកតា របស់គ្រួសារកសិកម្មដែលមានក្បាលដីដាច់ដោយឡែកពីគ្នាបានប្រើប្រាស់ជាកម្មសិទ្ធិផ្ទាល់ខ្លួន ឬកម្មសិទ្ធិដូចកម្មសិទ្ធិមិនគិតពីស្របច្បាប់ ឬក្រៅផ្លូវការ។ ការបែងចែកក្បាលដី និងទំហំផ្ទៃដីគឺវាស្របគ្នាទៅនឹងមធ្យមភាគថ្នាក់ជាតិ នៅទូទាំងខេត្ត

ភាគច្រើនលើកលែងតែខេត្តប៉ៃលិន។ ខេត្តប៉ៃលិនគ្រួសារកាន់កាប់កសិកម្ម មានភាគរយនៃក្បាលដីជាប្រភេទកម្មសិទ្ធិផ្ទាល់ខ្លួនតិចតួចជាងគេ (៨៧ ភាគរយ) ខណៈដែលភាគរយនៃការជួលក្បាលដីមានអាត្រាខ្ពស់ជាងគេគឺ (១២ ភាគរយ) និងសល់ ១ ភាគរយទៀតជាប្រភេទកម្មសិទ្ធិដីផ្សេងទៀត។ ការបែងចែកដីតាមប្រភេទកម្មសិទ្ធិក្នុងខេត្តប៉ៃលិនអនុវត្តតាមលំនាំដែលបានសង្កេតជាលេខក្បាលដី។

ផ្ទៃដីជាមធ្យមក្នុងមួយក្បាលដី ត្រូវបានប៉ាន់ប្រមាណថាមានចំនួន ១,២៩ ហិកតា។ ក្បាលដីដែលជួលពីអ្នកផ្សេងមានផ្ទៃដីជាមធ្យមធំជាងគេគឺ ២,១២ ហិកតាបន្ទាប់មកក្បាលដីក្រោមប្រភេទកម្មសិទ្ធិដីផ្សេងទៀតដែលជាមធ្យម ២,០២ ហិកតា។ នៅតំបន់បឹងទន្លេសាបនិងតំបន់ភ្នំនិងខ្ពង់រាបមានទំហំមធ្យមនៃក្បាលដីជាកម្មសិទ្ធិលើសពីមធ្យមភាគថ្នាក់ជាតិ។ តំបន់ទាំងពីរនេះក៏បានរាយការណ៍ផងដែរអំពីទំហំក្បាលដីធំជាងមធ្យមភាគថ្នាក់ជាតិលើប្រភេទដីកាន់កាប់ផ្សេងទៀត។ ទោះយ៉ាងណាក៏ដោយ មានតែតំបន់បឹងទន្លេសាបទេដែលមានទំហំក្បាលដីជាមធ្យមដែលបានជួលក្បាលដីមានលើសពីមធ្យមភាគថ្នាក់ជាតិ។




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

## ៣.៦- ការប្រើប្រាស់ដីជុំវិញលំនៅឋានសម្រាប់ធ្វើសកម្មភាពកសិកម្ម

ជាសរុប គ្រួសារកសិកម្មចំនួន ១ ២៤៩ ០៤៤ បានប្រើប្រាស់ផ្នែកខ្លះនៃដីជុំវិញលំនៅឋានរបស់ពួកគេសម្រាប់ការដាំដុះដំណាំ និង/ឬ សម្រាប់ការចិញ្ចឹមបសុសត្វ បសុបក្សី។ ក្នុងចំណោមនោះ គ្រួសារកសិកម្មចំនួន ១ ០៩៤ ៩៤២ គ្រួសារបានធ្វើកសិកម្មទាំងលើក្បាលដី និងដីជុំវិញលំនៅឋាន ចំណែកគ្រួសារកសិកម្មចំនួន ១៥៤ ១០២ គ្រួសារគឺបានធ្វើសកម្មភាពកសិកម្មតែនៅលើដីជុំវិញលំនៅឋានរបស់ពួកគាត់ប៉ុណ្ណោះ។ ផ្ទៃដីសរុបទាំង ១,២លានគ្រួសារនេះគឺ មានទំហំដី ១២៩ ៦២២ ហិកតាដែលជាទំហំមធ្យម ០,១០៤ ហិកតាក្នុងមួយគ្រួសារ។ ក្នុងនោះផ្ទៃដីសម្រាប់ដាំដំណាំមានចំនួន ៤៤ ៥៩៧ ហិកតា ដែលស្មើនឹង ៣៤,៤ ភាគរយនៃផ្ទៃដីសរុបនៃដីជុំវិញលំនៅឋាន។ ទំហំមធ្យមនៃដីជុំវិញលំនៅឋានដែលបានធ្វើការដាំដុះដំណាំគឺ ០,០៤ ហិកតាក្នុងមួយគ្រួសារ។




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

តាមភូមិសាស្ត្រនៃប្រទេសកម្ពុជា គ្រួសាររស់នៅតាមតំបន់ឆ្នេរសមុទ្រមានការបែងចែកដីធំជាងគេ (៦០ ភាគរយ) នៃដីជុំវិញលំនៅឋានរបស់ពួកគេសម្រាប់ធ្វើការដាំដុះដំណាំ បន្ទាប់មក ៣៦ ភាគរយ នៅតំបន់ភ្នំនិងខ្ពង់រាប ៣១ ភាគរយ នៅតំបន់វាលទំនាប និង ៣០ ភាគរយនៅតំបន់បឹងទន្លេសាប។ ក្នុងចំណោមខេត្តនានា គ្រួសារកសិកម្មក្នុងខេត្តរតនគិរីប្រើប្រាស់ភាគរយ

ខ្ពស់បំផុតនៃដីស្រែចម្ការរបស់ពួកគេ (៦៣ ភាគរយ) សម្រាប់ការដាំដុះ ខណៈរាជធានីភ្នំពេញមានភាគរយទាបបំផុត ១៦ ភាគរយ។ ដូចគ្នាដែរ ទំហំមធ្យមនៃដីជុំវិញលំនៅឋានដែលប្រើសម្រាប់ដាំដុះ គឺធំជាងគេនៅក្នុងខេត្តរតនគិរី ០.០៩៥ ហិកតា និងតូចជាងគេនៅរាជធានីភ្នំពេញ មានចំនួន ០.០១២ ហិកតា។

## ៣.៧- អង្គភាព(សហគ្រាស)កសិកម្មខ្នាតធំ

សហគ្រាសកសិកម្មខ្នាតធំ គឺជាអង្គភាពដែលគ្រប់គ្រង និងដំណើរការដោយសហគ្រាសឯកជន ឬរដ្ឋ រួមទាំងសាជីវកម្ម ភាពជាដៃគូ សហករណ៍ ស្ថាប័នឯកជន ស្ថាប័នរដ្ឋាភិបាល ។ល។ ក្នុងកំលុងធ្វើជំរឿនសហគ្រាសកសិកម្មខ្នាតធំ មានចំនួន ២៩១ សហគ្រាស ដែលត្រូវបានសម្ភាសន៍នៅក្នុងជំរឿនកសិកម្មឆ្នាំ២០២៣ រួមមានផ្នែកការដាំដុះដំណាំ ការចិញ្ចឹមបសុសត្វបសុបក្សី និងវារីវប្បកម្ម។ ចំនួនសហគ្រាសកសិកម្មខ្នាតធំដែលបានរាយការណ៍ គឺមានចំនួនតិចតួច ហើយការគ្របដណ្តប់នៃសហគ្រាសកសិកម្មខ្នាតធំនេះត្រូវបានធ្វើឡើងក្នុងកំលុងជំរឿនកសិកម្មគ្រួសារនៅក្នុងភូមិជាក់ស្តែង។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តល់បញ្ជីឈ្មោះសហគ្រាសកសិកម្មខ្នាតធំ ជាមួយនឹងអាសយដ្ឋាន និងព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនង។ មន្ត្រីសម្ភាសន៍ជំរឿនកសិកម្មបានព្យាយាមធ្វើការទាក់ទងទៅអ្នកគ្រប់គ្រង ឬតំណាងសហគ្រាសកសិកម្មខ្នាតធំ ដែលមានរាយក្នុងបញ្ជីទាំងអស់ទៅតាមមូលដ្ឋានទីតាំងនៅតាមរាជធានី ខេត្ត ជាមួយអាសយដ្ឋានដែលបានចុះឈ្មោះក្នុងរាជធានីភ្នំពេញរៀងៗខ្លួន។ ក្នុងករណីខ្លះការព្យាយាមទាក់ទងអ្នកគ្រប់គ្រង ឬតំណាងម្ចាស់សហគ្រាសនោះមិនបានជោគជ័យ ហើយមានករណីខ្លះទៀតសហគ្រាសកសិកម្មខ្នាតធំនោះមិនមានធ្វើសកម្មភាពកសិកម្មនៅក្នុងកំលុងពេលប្រតិបត្តិការធ្វើជំរឿននោះទេ។

សហគ្រាសកសិកម្មខ្នាតធំមានប្រមាណ ២៧ ភាគរយ នៃសហគ្រាសកសិកម្មខ្នាតធំសរុបត្រូវបានឆ្លើយតបថា ជាសហគ្រាស ឬក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត ដែលបានចុះបញ្ជីស្របច្បាប់ (២៤ ភាគរយ ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និង ៣ ភាគរយជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត)។ សហគ្រាសកសិកម្មខ្នាតធំដែលនៅសេសសល់ត្រូវបានចុះបញ្ជីជាកម្មសិទ្ធិរបស់កម្មសិទ្ធិករផ្តាច់មុខ ភាពជាដៃគូ និងសាខារបស់ក្រុមហ៊ុនបរទេស។ ប្រភេទនៃសហគ្រាសកសិកម្មខ្នាតធំផ្សេងទៀត ដែលអាចរាប់បញ្ចូលទាំងអង្គការរដ្ឋ ឬក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់គេជាដើម។ ផ្ទៃដីសរុបដែលបានប្រើប្រាស់ដោយការសហគ្រាសកសិកម្មខ្នាតធំចំនួន ២៩១ មូលដ្ឋានទីតាំង មានផ្ទៃដីប្រមាណ ៥៩៣ ៩៧០ ហិកតា ឬជាមធ្យម ១ ៧៦៣ ហិកតាក្នុងមួយសហគ្រាស។ ចំនួនសរុបនៃក្បាលដីដែលបានរាយការណ៍ មានប្រមាណ ៣៣៧ ក្បាលដី ដោយគិតជាមធ្យមក្នុងមួយសហគ្រាសខ្នាតធំមានចំនួន ១,៩ ក្បាលដី។

**រូបទី៣.៩ ភាគរយនៃការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ បែងចែកតាមភាពជាម្ចាស់កម្មសិទ្ធិនៅប្រទេសកម្ពុជា**




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

សហគ្រាសកសិកម្មខ្នាតធំ ភាគច្រើនត្រូវបានបង្ហាញថាជាមានការធ្វើសកម្មភាពកសិកម្មតែមួយប្រភេទប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ សហគ្រាសកសិកម្មខ្នាតធំមួយចំនួនក៏មានសកម្មភាពកសិកម្មជាច្រើនប្រភេទផងដែរ ដូចជាការដាំដុះដំណាំរយៈពេលខ្លី (បណ្ដោះអាសន្ន) និងដំណាំអចិន្ត្រៃយ៍ ឬការធ្វើកសិកម្មដោយដាំដំណាំចម្រុះរួមជាមួយនិងការចិញ្ចឹមសត្វ។ ការអនុវត្តកសិកម្មចម្រុះ ឬច្រើនប្រភេទនៅក្នុងអំឡុងរយៈពេលយោងមានអត្រាភាគច្រើន (៥២ ភាគរយ) គឺការដាំដុះដំណាំអចិន្ត្រៃយ៍ ដូចជាការដាំដំណាំផ្លែឈើហូបផ្លែ និងមាន៣០ ភាគរយ គឺចិញ្ចឹមបសុសត្វ ការចិញ្ចឹមបសុបក្សីមាន ២១ ភាគរយ និងការធ្វើវារីវប្បកម្ម (១៣ ភាគរយ)។ លើសពីនេះ សហគ្រាសកសិកម្មខ្នាតធំមានប្រមាណ ១៥ ភាគរយ ត្រូវបានចូលរួមនៅក្នុងការដាំដុះដំណាំបណ្ដោះអាសន្ន ជាពិសេសការដាំដុះបន្លែ។

រូប៣.១០ ភាគរយនៃការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ បែងចែកតាមសកម្មភាពកសិកម្ម




* អ្នកតបការសម្ភាសអាចជ្រើសរើសបានច្រើនជាង១សកម្មភាពកសិកម្ម ប៉ុន្តែភាគរយមិនអាចច្រើនជាង ១00%។

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

# ជំពូកទី៤

# ការដាំដុះដំណាំ

គ្រួសារប្រកបរបបកសិកម្មនៅក្នុងប្រទេសកម្ពុជា គឺជាចម្បងបានធ្វើការដាំដុះ និងការប្រមូលផលដំណាំរយៈពេលខ្លី និងដំណាំរយៈពេលវែង។ ដំណាំរយៈពេលខ្លី គឺជាប្រភេទដំណាំដែលមានវដ្តនៃការលូតលាស់តិចជាងមួយឆ្នាំ បន្ទាប់ពីការប្រមូលផលហើយគឺមានការដាំដុះឡើងវិញមានដូចជា សាបព្រោះបណ្ដុះដាំសម្រាប់វដ្តផលិតកម្មផ្សេងទៀត ។ ដំណាំរយៈពេលខ្លីដែលបានបង្ហាញនៅក្នុងការធ្វើជំរឿននេះ គឺជាដំណាំដាំដុះតាមរដូវកាលនៅក្នុងកាលបរិច្ឆេទយោងនៃជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣ ហើយបានធ្វើការចាត់ថ្នាក់ប្រភេទដំណាំសំខាន់ៗចំនួន១៣មុខ រួមមានដំណាំគ្រាប់ធញ្ញជាតិ មើម ឫស និងគ្រាប់ធញ្ញជាតិ រុក្ខជាតិគ្រាប់គ្រាប់ធញ្ញជាតិ ដំណាំគ្រាប់ពូជប្រេង គ្រឿងទេស គ្រឿងក្រអូប និងរុក្ខជាតិឱសថ ដំណាំឧស្សាហកម្ម ដំណាំសរសៃ ដំណាំបន្លែ និងដំណាំសាកវប្បកម្ម។ ផ្ទៃដីដាំដំណាំរយៈពេលខ្លីសរុបមានប្រមាណ ២,៧ លាន ហិកតា។

ប្រភេទដំណាំទាំងពីរប្រភេទខាងលើ បានបង្ហាញអំពីផ្ទៃដីដុះ និងផ្ទៃដីប្រមូលផល។ ផ្ទៃដីដាំដុះសំដៅទៅលើទំហំផ្ទៃដីដែលបានប្រើប្រាស់សម្រាប់ប្រតិបត្តិការកសិកម្ម បានគណនាជាចំនួនដងការដាំដំណាំដូចគ្នា ឬក៏ដំណាំផ្សេងៗគ្នាបានដាំដុះក្នុងរយៈពេលកាលបរិច្ឆេទយោង។ ការប្រមូលផលសំដៅលើទំហំផ្ទៃដីដែលបានច្រូតកាត់ប្រមូលផលទាំងស្រុង ឬដោយផ្នែក មិនរាប់បញ្ចូលផ្ទៃដីដាំដុះហើយមិនបានប្រមូលផលដោយសារការបរាជ័យ ការខូចខាត ឬការប្រមូលផលកើតឡើងនៅក្រៅរយៈពេលយោងនៃជំរឿន។

ដំណាំរយៈពេលវែង គឺជាប្រភេទដំណាំមានវដ្តនៃការលូតលាស់លើសពីមួយឆ្នាំហើយត្រូវបានបង្ហាញថា ជាមុខដំណាំសំខាន់ និងមានផលិតភាពក្នុងអង្គភាពកសិកម្ម។ ចំណាត់ថ្នាក់ដំណាំសំខាន់ៗចំនួន ១០មុខ ត្រូវបានប្រើប្រាស់នៅក្នុងការកំណត់អត្តសញ្ញាណនៃដំណាំរយៈពេលវែងសំខាន់ខុសៗគ្នា ការដាំដុះដំណាំផ្លែឈើហូបផ្លែ ដំណាំគ្រាប់អាចបរិភោគបានដំណាំភេសជ្ជៈដំណាំប្រេង ដំណាំគ្រឿងទេស និងគ្រឿងក្រអូម ដំណាំកៅស៊ូ និងប្រភេទដំណាំដែលមិនមែនជាអាហារផ្សេងទៀត។

ដើម្បីសម្រួលដល់អ្នកឆ្លើយតបសម្ភាសន៍ទិន្នន័យសម្រាប់ដំណាំរយៈពេលវែងត្រូវបានប្រមូលដោយគិតជាហិកតាសម្រាប់ការដាំដុះមានលក្ខណៈបច្ចេកទេស និងគិតជាចំនួនដើម

សម្រាប់ការដាំដុះជាលក្ខណៈរាយប៉ាយ។ ហេតុដូច្នេះទិន្នន័យដែលបានរាយកាណ៍អំពីចំនួនដើមត្រូវបានបម្លែងទៅជាហិកតា ដោយផ្អែកតាមស្តង់ដារដែលបានផ្តល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយទាំងនេះអាចរកបាននៅក្នុងឧបសម្ព័ន្ធ។

## ៤.១- ដំណាំធញ្ញជាតិ និង ធញ្ញជាតិយកគ្រាប់

នៅក្នុងប្រទេសកម្ពុជាក្នុងចំណោមដំណាំរយៈពេលខ្លី គឺប្រភេទដំណាំធញ្ញជាតិ និងដំណាំធញ្ញជាតិយកគ្រាប់មានការដាំដុះច្រើនជាងគេបំផុត ទាំងចំនួននៃការកាន់កាប់ និងផ្ទៃដីដាំដុះ។ ដំណាំទាំងនេះមានប្រមាណ ៨៣ ភាគរយ នៃផ្ទៃដីដំណាំបណ្តោះអាសន្នសរុប ដែលបានដាំដុះលើផ្ទៃដីប្រមាណ ២ ២០៨ ៩៧៩ ហិកតា។

ដំណាំសំខាន់ៗដែលបានដាំដុះច្រើនជាងគេ គឺដំណាំស្រូវ និងពោត។ ដំណាំស្រូវមានបីប្រភេទ ត្រូវបានដាំដុះ គឺស្រូវធម្មតា ស្រូវក្រអូប ស្រូវដំណើប។ ដំណាំពោតត្រូវបានចែកជាពីរក្រុម គឺស្នៀតពោត/ពោតខ្ចី និងពោតស/ពោតលឿង/ពោតស្វាយ។ ចំពោះស្រូវទាំងបីប្រភេទ ស្រូវធម្មតា គឺជាប្រភេទស្រូវដែលបានដាំដុះច្រើនជាងគេបំផុត ដែលបានដាំលើផ្ទៃដីសរុបប្រមាណ ១ ៦៥០ ០០០ ហិកតា និងមានគ្រួសារកសិកម្មដែលបានដាំដុះស្រូវធម្មតាមានចំនួន ១ ១៥៤ ០០០ គ្រួសារ។ ស្រូវក្រអូបត្រូវបានដាំដុះលើផ្ទៃដីសរុបប្រមាន ៤៦៥ ០០០ ហិកតា និងស្រូវដំណើបបានដាំដុះលើផ្ទៃដីប្រមាណ ៣ ០០០ ហិកតា។ ចំណែកដំណាំពោតស/ពោតលឿង/ពោតស្វាយវិញ ត្រូវបានដាំដុះលើផ្ទៃដីសរុបប្រមាណ ៩០ ០០០ហិកតា។ រីឯស្នៀតពោត/ពោតខ្ចីត្រូវបានដាំដុះលើផ្ទៃដីប្រមាណ ២១៣ ហិកតា។ ខណៈដែលដំណាំស្ពៃយត្រូវបានដាំដុះលើផ្ទៃដីប្រមាណ ៨៣ ហិកតា និងធញ្ញជាតិយកគ្រាប់ផ្សេងទៀត បានដាំដុះលើផ្ទៃដីប្រមាណ ៦៤ ហិកតា។

**តារាង៤.១ ចំនួនគ្រួសារកសិកម្ម និងផ្ទៃដីដាំដំណាំធញ្ញជាតិ និងដំណាំធញ្ញជាតិយកគ្រាប់**

| ដំណាំធញ្ញជាតិនិង ធញ្ញជាតិយកគ្រាប់ | ចំនួនគ្រួសារ | ផ្ទៃដីដាំដុះ (ហិកតា) | ផ្ទៃដីប្រមូលផល (ហិកតា) | បរិមាណផល (តោន) | ទិន្នផល (តោន/ហិកតា) |
|---|---|---|---|---|---|
| ស្រូវធម្មតា | ១ ១៥៤ ៣៩៧ | ១ ៦៥០ ២៣៧ | ១ ៦៤០ ៧៥៨ | ៥ ៥៧៤ ៦៣២ | ៣,៤ |
| ស្រូវក្រអូប | ៣០៧ ៨៨៦ | ៤៦៤ ៥៤៩ | ៤៦២ ៣៤៩ | ១ ៣៦៥ ៩៦៣ | ៣,០ |
| ស្រូវដំណើប | ៤ ២១៦ | ៣ ៤៣៥ | ៣ ៤៣១ | ៩ ៥៥៤ | ២,៨ |
| ពោតស/ពោតលឿង/ពោតស្វាយ | ៣១ ៩៣២ | ៩០ ៣៩៧ | ៨៩ ៩៩៨ | ៥៩៥ ៣៣៣ | ៦,៦ |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

នៅតំបន់វាលទំនាបមានចំនួនគ្រួសារកាន់កាប់ច្រើនជាងគេ ដែលរាយការណ៍ពីការដាំដុះស្រូវធម្មតាដែលមានគ្រួសារកសិកម្មសរុបចំនួន ៤៩៤ ០០០ ធៀបនឹង ៤០៩ ០០០ នៅតំបន់បឹងទន្លេសាបមានគ្រួសារកសិកម្មចំនួន ១៦១ ០០០ នៅតំបន់ភ្នំនិងខ្ពង់រាប និងចំនួន ៩០ ០០០ គ្រួសារកសិកម្មនៅតំបន់ឆ្នេរសមុទ្រ។ ខេត្តចំនួន ៤ ក្នុងចំណោមខេត្តចំនួន ១០ ដែលមានការដាំដុះស្រូវធម្មតាច្រើនជាងគេ គឺមកពីតំបន់វាលទំនាប មានខេត្តតាកែវ ព្រៃវែង ស្វាយរៀង និងខេត្តកំពង់ចាម។



រូប៤.១ ចំនួនគ្រួសារកសិកម្មបានដាំដុះស្រូវធម្មតា បែងចែកតាមខេត្ត (ចំនួន១០ ខេត្តដែលមានលំដាប់ថ្នាក់ខ្ពស់ជាងគេ)

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

ទោះជាយ៉ាងណាក៏ដោយ នៅតំបន់បឹងទន្លេសាបមានផ្ទៃដីដាំដុះ និងផ្ទៃដីប្រមូលផលស្រូវធម្មតាច្រើនជាងគេដែលមានផ្ទៃដីដាំដុះសរុបចំនួន ៨២៤ ០០០ ហិកតា ហើយមានផ្ទៃដីប្រមូលផលចំនួន ៨១៨ ០០០ ហិកតា។ បើប្រៀបធៀបទៅនឹងតំបន់វាលទំនាបមានផ្ទៃដីដាំដុះចំនួន ៥៧៩ ២៧៧ ហិកតា ហើយនិងមានផ្ទៃដីប្រមូលផលចំនួន ៥៧៦ ០០០ ហិកតា។ តំបន់ភ្នំនិងខ្ពង់រាបមានផ្ទៃដីដាំដុះចំនួន ១៨៤ ០០០ ហិកតា ហើយនិងផ្ទៃដីប្រមូលផលមានចំនួន ១៨៣ ០០០ ហិកតា។ នៅតំបន់ឆ្នេរសមុទ្រមានផ្ទៃដីដាំដុះ និងផ្ទៃដីប្រមូលផលមានចំនួន ៦៣ ០០០ ហិកតា។

ក្នុងចំណោមខេត្តទាំង១០ ផ្ទៃដីប្រមូលផលស្រូវធម្មតាដែលមានច្រើនជាងគេ គឺមានខេត្តចំនួន ៦ ស្ថិតក្នុងតំបន់បឹងទន្លេសាប (សៀមរាប បន្ទាយមានជ័យ បាត់ដំបង កំពង់ធំ កំពង់ឆ្នាំង និង

ពោធិ៍សាត់)។ មានខេត្តចំនួន ៦ តែប៉ុណ្ណោះដែលប្រមូលផលស្រូវធម្មតាមានតិចជាង ១០ ០០០ ហិកតា រួមមានខេត្តរតនគិរី (៩ ០០០ ហិកតា) ខេត្តព្រះសីហនុ (៣ ០០០ ហិកតា) ខេត្តកោះកុង ខេត្តកែប និងរាជធានីភ្នំពេញ (២ ០០០ ហិកតា) និងខេត្តប៉ៃលិន (៦០០ ហិកតា)។ នៅទូទាំងប្រទេសមានទិន្នផលស្រូវធម្មតាគិតជាមធ្យមចំនួន ៣,៤ តោន ក្នុងមួយហិកតា។

រូប៤.២ ផ្ទៃដីបានប្រមូលផលស្រូវធម្មតាគិតជាហិកតាចែកតាមខេត្ត (ចំនួន១០ ខេត្តដែលមានលំដាប់ថ្នាក់ខ្ពស់ជាងគេ)




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

គ្រួសារកាន់កាប់កសិកម្មនៅគ្រប់ខេត្តទាំងអស់ ក៏បានរាយការណ៍អំពីការប្រមូលផលស្រូវក្រអូបផងដែរ ក្នុងនោះមានចំនួន ១១ខេត្ត បានដាំស្រូវក្រអូបដែលមានផ្ទៃដីច្រើនជាង ១០ ០០០ ហិកតា រួមមានខេត្តបន្ទាយមានជ័យ បាត់ដំបង ព្រៃវែង ពោធិ៍សាត់ សៀមរាប កំពង់ធំ ព្រះវិហារ ក្រចេះ ស្វាយរៀង ឧត្តរមានជ័យ និងខេត្តកំពង់ស្ពឺ។ មានខេត្តចំនួន ៤ ដែលបានដាំដុះដំណាំស្រូវក្រអូបលើផ្ទៃដីមានតិចជាង ១ ០០០ ហិកតា រួមមានខេត្តកោះកុង កែប រាជធានីភ្នំពេញ និងខេត្តព្រះសីហនុ។ ទិន្នផលស្រូវក្រអូបជាមធ្យមនៅទូទាំងប្រទេសគឺ ៣,០ តោន ក្នុងមួយហិកតា។




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

សម្រាប់ពូជស្រូវដំណើបមិនត្រូវបានគេដាំច្រើនដូចស្រូវធម្មតាទេ ទោះយ៉ាងណាក៏ដោយ នៅគ្រប់ខេត្តទាំងអស់លើកលែងតែខេត្តព្រះសីហនុចេញ បានរាយការណ៍ថាយ៉ាងហោចណាស់មានខេត្តមួយចំនួនបានដាំស្រូវដំណើបផងដែរ។ ខេត្តចំនួន៨បានរាយការណ៍ថាបានប្រមូលផលស្រូវដំណើបដែលមានផ្ទៃដីជាង ១០០ ហិកតា មិនមានខេត្តណាមួយបានរាយការណ៍លើសពី ១ ០០០ ហិកតានោះទេ។ ខេត្តដែលឈានមុខគេសម្រាប់ការដាំដុះស្រូវដំណើបមានខេត្តស្វាយរៀង (ប្រមូលផល ៨៩៧ ហិកតា) ខេត្តព្រះវិហារ (ប្រមូលផល ៧៤៨ ហិកតា) ខេត្តស្ទឹងត្រែង (ប្រមូលផល ៣១៩ ហិកតា) និងខេត្តរតនគិរី (ប្រមូលផល ២៤២ ហិកតា) ។ ទិន្នផលស្រូវដំណើបជាមធ្យមមានចំនួន ២,៨ តោន ក្នុងមួយហិកតា។




រូប៤.៥ ខេត្តចំនួន១០មានផ្ទៃដីប្រមូលផលស្រូវដំណើបច្រើនជាងគេ

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

ខេត្តទាំង២៥ បានរាយការណ៍ពីការដាំដុះដំណាំ និងប្រមូលផលពោតមួយចំនួន (ពោតស/លឿង/ស្វាយ)។ ក្នុងចំណោមខេត្តទាំងនេះ គឺខេត្តបាត់ដំបងមានផ្ទៃដីប្រមូលផលពោតប្រមាណ ៥២ ០០០ ហិកតា ខេត្តប៉ៃលិនប្រមូលផល ១១ ០០០ ហិកតា និងខេត្តកណ្ដាលប្រមូលផល ៨ ០០០ ហិកតា។ ទិន្នផលពោតគិតជាមធ្យមនៅទូទាំងប្រទេស គឺមាន៦,៦ តោន ក្នុងមួយហិកតា។




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

## ៤.២- ដំណាំយកឫស និង មើម

ដំណាំយកឫស និងមើម ត្រូវបានចាត់ទុកជាដំណាំរយៈពេលខ្លីដែលនិយមដាំដុះទីពីររបស់គ្រួសារកាន់កាប់កសិកម្មមានផ្ទៃដីប្រមាណ ១៦ ភាគរយ នៃផ្ទៃដីដាំដុះដំណាំរយៈពេលខ្លីសរុបស្មើនឹង ៤២៦ ៤៥៤ ហិកតា។

ដាំដំណាំយកឫស និងមើមរួមបញ្ចូល ដំឡូងមី ដំឡូងជ្វា ត្រាវ និងមើមក្រអៅឈូក។ ដំឡូងមីត្រូវបានដាំដុះច្រើនជាងគេក្នុងចំណោមដាំដំណាំយកមើមទាំងអស់ ដែលមានផ្ទៃដីដាំដុះប្រមាណ ៤២១ ៣៤៦ ហិកតា ហើយនិងមានផ្ទៃដីប្រមូលផល ៤២០ ៧៣៤ ហិកតា ដែលធ្វើឱ្យកម្ពុជាផលិតបានផលដំឡូងមីប្រមាណ ៣,៤ លានតោន ហើយនិងទិន្នផលគិតជាមធ្យមគឺមាន ៨,០ តោន ក្នុង១ហិកតា។

តំបន់ដែលដាំដុះដំណាំ និងផលិតដំឡូងមីធំជាងគេ គឺតំបន់ទន្លេបឹងទន្លេសាប ដែលមានផ្ទៃដីដាំដុះប្រមាណ ៥៤ ភាគរយ នៃផ្ទៃដីដាំដុះសរុប ហើយតំបន់នៅលំដាប់បន្ទាប់គឺតំបន់ភ្នំនិងខ្ពង់រាប (ប្រមាណ ៣៩ ភាគរយ)។ តំបន់ឆ្នេរសមុទ្រមានផ្ទៃដីដាំដុះតូចជាងគេមានតិចជាង ០,០១ ភាគរយ នៃផ្ទៃដីដាំដុះសរុប ឬស្មើនឹងប្រមាណ ២៥ ហិកតា។ មានតែខេត្តព្រះវិហារដែលលេចធ្លោជាងគេក្នុងការដាំដុះដំឡូងមីដែលមានផ្ទៃដីដាំដុះជាង ៧២ ០០០ ហិកតា។ ផ្ទៃដីដាំដុះដំឡូងមីមានចន្លោះពី ៣០ ០០០ ហិកតា ទៅ ៥០ ០០០ ហិកតា មានស្ថិតនៅក្នុងខេត្តសៀមរាប ឧត្តរមានជ័យ បាត់ដំបង ពោធិ៍សាត់ និងកំពង់ធំ នៅខណៈដែលខេត្តស្ទឹងត្រែង រតនគិរី ក្រចេះ និងបន្ទាយមានជ័យ មានផ្ទៃដីដាំដុះដំណាំនៅចន្លោះពី ២០ ០០០ ហិកតា ទៅ ៣០ ០០០ ហិកតា។




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

## ៤.៣- វុក្ខជាតិពពួកសណ្ដែក (គ្រាប់ធញ្ញជាតិ)

វុក្ខជាតិពពួកសណ្ដែក (គ្រាប់ធញ្ញជាតិ) គឺជាប្រភេទដំណាំគ្រាប់ធញ្ញជាតិដ៏ចម្បងដែលសម្បូរទៅដោយជាតិប្រូតេអ៊ីន។ ធញ្ញជាតិពពួកសណ្ដែកទាំងនេះ ត្រូវបានកំណត់ជាប្រភេទមានជាតិប្រូតេអ៊ីនដ៏សំខាន់របស់ប្រជាពលរដ្ឋ។ ផ្ទៃដីដាំដុះជារួមមានចំនួនប្រមាណ ៨ ៧៧៥ ហិកតានៃពពួកសណ្ដែក ហើយសណ្ដែកបាយ គឺជាដំណាំដែលនិយមដាំច្រើនជាងគេ (ផ្ទៃដីដាំដុះប្រមាណ ៨ ៣៨៣ ហិកតា)។ ក្នុងនោះផ្ទៃដីដាំសណ្ដែកបាយមានប្រមាណ ៨ ៣៦៧ ហិចតា ត្រូវបានរាយការណ៍ថាមានផ្ទៃដីប្រមូលផលបាន ១២ ៤៦៩ តោន ខណៈទិន្នផលជាមធ្យមមាន ១,៥ តោន ក្នុងមួយហិចតា។

គ្រួសារកសិកម្មនៅតំបន់បឹងទន្លេសាប គឺជាអ្នកដាំសណ្ដែកបាយច្រើនជាងគេដែលមានផ្ទៃដីដាំដុះជិតអត្រា ៨៨ ភាគរយ នៃផ្ទៃដីដាំដុះដំណាំសរុប។ ខេត្តកំពង់ឆ្នាំងជាខេត្តដែលបានដាំដុះដំណាំសណ្ដែកបាយច្រើនបំផុតដោយសារគ្រួសារកសិកម្ម ដែលមានផ្ទៃដីដាំដុះ ៦ ២៥៣ ហិកតា ឬស្មើនឹង ៧៥ ភាគរយ នៃផ្ទៃដីដាំដុះសរុបដោយគ្រួសារកសិកម្មនៅទូទាំងប្រទេស។ ខេត្តមណ្ឌលគិរី ជាខេត្តដែលដាំដុះដំណាំសណ្ដែកបាយធំទីពីរ ដែលមានផ្ទៃដីដាំដុះប្រមាណ ៧០០ ហិកតា ខណៈដែលនៅខេត្តបាត់ដំបង សៀមរាប និងខេត្តពោធិ៍សាត់ មានផ្ទៃដីដាំដុះប្រមាណ ៣០០ ហិកតា សម្រាប់ខេត្តនីមួយៗ។

រូប៤.៩ ខេត្តចំនួន១០ មានផ្ទៃដីដាំសណ្តែកបាយច្រើនជាងគេ




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

## ៤.៤- ដំណាំធញ្ញជាតិប្រេង

ដំណាំធញ្ញជាតិប្រេង ដូចជាសណ្តែកដី ល្ង សណ្តែកសៀង ល្ហុងប្រេង និងផ្កាឈូករ័ត្ន ត្រូវបានដាំលើផ្ទៃដីសរុប ៦ ៣២៧ ហិកតា ហើយនិងផ្ទៃដីប្រមូលផល ៦ ៣២១ ហិកតា។ ដំណាំសណ្តែកសៀង ត្រូវបានដាំដុះច្រើនជាងគេមានប្រមាណ ៦០ ភាគរយ នៃផ្ទៃដីដំណាំធញ្ញជាតិប្រេងសរុប ឬស្មើនឹង ៣ ៧៧៦ ហិកតា។

ដំណាំសណ្តែកសៀង ត្រូវបានដាំដុះច្រើនបំផុតពេញនិយមនៅតំបន់ភ្នំនិងខ្ពង់រាប មានប្រមាណ ៨៥ ភាគរយ នៃផ្ទៃដីសរុប ខណៈដែលតំបន់វាលទំនាប និងតំបន់ឆ្នេរសមុទ្រមានចំនួនគ្រួសារកាន់កាប់កសិកម្មតិចតួចដែលបានដាំដុះដំណាំសណ្តែកសៀង។

មានខេត្តចំនួន៣ ដែលបានដាំដុះដំណាំសណ្តែកសៀងច្រើនជាងគេ គឺនៅខេត្តរតនគិរី ព្រះវិហារ និងបាត់ដំបង។ ខេត្តរតនគិរី ជាខេត្តដែលមានផ្ទៃដីដាំដុះដំណាំសណ្តែកសៀងច្រើនបំផុតមានប្រមាណ ២ ៥០០ ហិកតា ខណៈដែលខេត្តព្រះវិហារ និងបាត់ដំបង មានផ្ទៃដីដាំដុះសណ្តែកសៀងមានត្រឹមតែប្រមាណ ៥០០ហិកតា សម្រាប់នៅក្នុងខេត្តនីមួយៗ។

រូប៤.១០ ខេត្តចំនួន១០ មានផ្ទៃដីដាំដុះដំណាំសណ្តែកសៀងច្រើនជាងគេ




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

## ៤.៥- គ្រឿងទេស គ្រឿងក្រអូប និងរុក្ខជាតិឱសថ

គ្រឿងទេស គ្រឿងក្រអូប និងរុក្ខជាតិឱសថ (រម្មៀត ស្លឹកគ្រៃ ជីរអង្កាម ជីរវ៉ាន់ស៊ុយ ម្អមម្លូរ ស្លឹកគូឆាយ និងជីរនាងវង ត្រូវបានចាត់ទុកជាដំណាំរយៈពេលខ្លី) ដែលមានផ្ទៃដីដាំដុះសរុបចំនួន ១ ៩១៣ ហិកតា ហើយនិងមានដំណាំល្មៀតមានផ្ទៃដីដាំដុះច្រើនជាងគេ ចំនួន ៧០៨ ហិកតា បន្ទាប់មកដំណាំស្លឹកគ្រៃមានផ្ទៃដីដាំដុះចំនួន ៥៣២ ហិកតា និងជីរមានផ្ទៃដីដាំដុះចំនួន ២៥៨ ហិកតា។ ក្នុងចំណោមផ្ទៃដីដាំដុះដំណាំគ្រឿងទេស គ្រឿងក្រអូប និងរុក្ខជាតិឱសថទាំងអស់ គឺមានភាគច្រើនត្រូវបានដាំនៅតំបន់បឹងទន្លេសាប ដែលមានផ្ទៃដីប្រមាណ ៨៨៨ ហិកតា បន្ទាប់មកនៅតំបន់វាលទំនាបមានប្រមាណ ៦៦២ ហិកតា តំបន់ឆ្នេរសមុទ្រ៣០១ ហិកតា និងតំបន់តំបន់ភ្នំនិងខ្ពង់រាប មានប្រមាណ ៦២ ហិកតា។

**រូប៤.១១ ផ្ទៃដីដាំដំណាំគ្រឿងទេស គ្រឿងក្រអូប និងរុក្ខជាតិឱសថ ចែកតាមតំបន់**




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

ខេត្តពោធិ៍សាត់ ជាខេត្តដែលមានផ្ទៃដីដាំដុះដំណាំល្មៀតច្រើនជាងគេចំនួន ៥១២ ហិកតា បន្ទាប់មកនៅខេត្តបាត់ដំបង ដែលមានផ្ទៃដីដាំដុះប្រមាណ ១៧៨ ហិកតា។ ខេត្តកណ្តាល និង ប៉ៃលិនដែលមានផ្ទៃដីដាំដុះដំណាំប្រមាណ ១០ ហិកតា និង ៦ ហិកតា ខណៈដែលខេត្តផ្សេងទៀតមានផ្ទៃដីដាំដុះដំណាំល្មៀតចំនួនត្រឹមតែ ១ ហិកតា ឬតិចជាង ១ ហិកតាប៉ុណ្ណោះ។

**រូប៤.១២ ផ្ទៃដីដាំដុះដំណាំល្មៀត បែងចែកតាមខេត្ត**




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

ខេត្តកំពត មានផ្ទៃដីដាំដុះដំណាំស្លឹកគ្រៃច្រើនជាងគេមានចំនួន ២៨៣ ហិកតា បន្ទាប់មកនៅខេត្តកំពង់ចាមមានផ្ទៃដីដាំដុះដំណាំប្រមាណ ៩២ ហិកតា ខណៈដែលខេត្តផ្សេងទៀតមានផ្ទៃដីដាំដុះតិចជាង ៥០ ហិកតា។ ជីរអង្កាមត្រូវបានដាំលើផ្ទៃដី ២៥៨ ហិកតា ក្នុងនោះមាន ១៤៨ ហិកតា ត្រូវបានដាំនៅខេត្តកណ្ដាល ខណៈដែលនៅខេត្តបាត់ដំបង មានផ្ទៃដីដាំដុះប្រមាណ ២៦ ហិកតា នៅខេត្តត្បូងឃ្មុំមានផ្ទៃដាំដុះ ២២ ហិកតា នៅរាជធានីភ្នំពេញមាន ១៩ ហិកតា និងខេត្តរតនគិរី មានចំនួន ១០ ហិកតា។

រូប៤.១៣ ខេត្តចំនួន១០ មានផ្ទៃដីដាំស្លឹកគ្រៃច្រើនជាងគេ




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

## ៤.៦- ដំណាំឧស្សាហកម្ម

ដំណាំអំពៅ និងថ្នាំជក់ជាដំណាំត្រូវបានដាំដុះដោយគ្រួសារកាន់កាប់កសិកម្ម។ ដំណាំអំពៅត្រូវបានដាំនៅក្នុងតំបន់ទាំងបួន ដែលមានផ្ទៃដីសរុបប្រមាណជាង ២ ២៨០ ហិកតា (ដាំដុះលើក្បាលដីប្រមាណ ២ ៨៧៧ ក្បាលដី) ក្នុងនោះមាន ៧៨ ភាគរយ ត្រូវបានដាំដុះនៅតំបន់វាលទំនាប (ខេត្តព្រៃវែង ១ ២៦៧ ហិកតា ខេត្តកណ្ដាល ២១២ ហិកតា ខេត្តត្បូងឃ្មុំ ១៤៩ ហិកតា ហើយនិងខេត្តកំពង់ចាម តាកែវ ស្វាយរៀង និងរាជធានីភ្នំពេញ សរុបស្មើ ១៣០ ហិកតា)។ នៅតំបន់ជុំវិញបឹងទន្លេសាប មានផ្ទៃដីដាំដុះដំណាំចំនួន ២៥៨ ហិកតា តំបន់ឆ្នេរសមុទ្រ ១៦១ ហិកតា និងតំបន់ភ្នំនិងខ្ពង់រាបមាន ១០៣ ហិកតា។ ការប្រមូលផលលើផ្ទៃដីចំនួន ២ ២៨០ ហិកតា ស្ទើរតែស្មើនឹង ១០០ ភាគរយ។



រូប៤.១៤ ផ្ទៃដីដាំដំណាំអំពៅ បែងចែកតាមតំបន់

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

ដំណាំថ្នាំជក់ត្រូវបានដាំនៅក្នុងតំបន់ពីរ គឺតំបន់វាលទំនាប និង តំបន់ភ្នំនិងខ្ពង់រាប។ តំបន់វាលទំនាបដាំដុះមានប្រមាណជាង ១ ៥០៣ ហិកតា ស្មើនឹង ៦៥ ភាគរយ និង តំបន់ភ្នំនិងខ្ពង់រាប ដាំដុះមានប្រមាណជាង ៨១២ ហិកតា ឬស្មើនឹង ៣៥ ភាគរយ។ នៅតំបន់វាលទំនាប ដំណាំថ្នាំជក់ ត្រូវបានដាំដុះនៅខេត្តត្បូងឃ្មុំ (៨៤៧ ហិកតា) និងខេត្តកំពង់ចាម (៦៥៧ ហិកតា) ខណៈដែលនៅតំបន់ភ្នំនិងខ្ពង់រាប ត្រូវបានដាំដុះនៅខេត្តក្រចេះ (៨១១ ហិកតា)។ ការប្រមូលផលដំណាំថ្នាំជក់លើផ្ទៃដីដាំដុះសរុប ២ ៣១៤ ហិកតា ជិតស្មើនឹង ១០០ ភាគរយ នៃផ្ទៃដីដាំដុះដំណាំសរុប ២ ៣១៥ ហិកតា។



រូប៤.១៥ ផ្ទៃដីដាំដុះដំណាំថ្នាំជក់ ចែកតាមតំបន់

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

## ៤.៧- ដំណាំយកសរសៃ ឬអំបោះ

ដំណាំយកសរសៃ ឬអំបោះ រួមមានដំណាំកប្បាស ក្រចៅ ដំណាំគ និងដំណាំយកសរសៃផ្សេងៗទៀត ត្រូវបានរាយការណ៍ដោយគ្រួសារកាន់កាប់កសិកម្ម។ ដំណាំប្រភេទទាំងនេះដាំដុះគ្របដណ្តប់លើផ្ទៃដីដាំដុះសរុបជាង ១៧២ ហិកតា ខណៈដែលការដាំដុះដំណាំគមានច្រើនជាងគេ ដែលមានផ្ទៃដីប្រមាណជាង ៨០ ហិកតា បន្ទាប់មកគឺដំណាំសំឡីគមាន ៥២ ភាគរយ។

ដំណាំកប្បាស និងក្រចៅ ត្រូវបានដាំដុះតិចតួចបំផុតនៅលើផ្ទៃដីប្រមាណជាង ៦ និង ២ ហិកតា តាមលំដាប់រៀង។ ដំណាំយកសរសៃផ្សេងៗទៀត ត្រូវបានដាំនៅលើផ្ទៃដីប្រមាណជាង ៣២ ហិកតា។ ដំណាំគ និងដំណាំមន គឺជាដំណាំដែលគួរឱ្យកត់សម្គាល់ ខណៈដំណាំមនបានដាំដុះលើផ្ទៃដីប្រមូលផលចំនួន ៨០ ហិកតា និងដំណាំគមានចំនួន ៤៩ ហិកតា។ ផ្ទៃដីសរុបដែលបានរាយការណ៍ថាដាំដំណាំមននៅខេត្តបន្ទាយមានជ័យ ចំណែកដំណាំគស្ទើរតែទាំងអស់ត្រូវបានដាំដុះនៅខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ដែលមានផ្ទៃដីដាំដុះតិចជាង ១ ហិកតា ។

## ៤.៨- ដំណាំបន្លែ

បន្លែច្រើនមុខ ត្រូវបានដាំដុះនៅទូទាំងប្រទេសកម្ពុជា ដូចជាបន្លែស្លឹក ដើម ផ្លែ មើម និងបន្លែបៃតង។ល។ បន្លែស្លឹក ឬដើម រួមមានស្លឹកខ្ទឹម ស្ពៃខ្មៅ ស្ពៃក្រញ៉ាញ់ ស្ពៃស និងត្រកួន។ ការធ្វើជំរឿនកសិកម្មនេះមានព័ត៌មានអំពីដំណាំម្ទេស ត្រសក់ ត្រប់ ននោង ល្ពៅ និងត្រឡាច។ ពពួកបន្លែបៃតង មានដូចជាសណ្តែកកួរ និងបន្លែដទៃទៀត រួមមានផ្កាខាត់ណាខៀវជាដើម។

គ្រួសារកាន់កាប់កសិកម្មមានប្រមាណ ១ ៤៨៩ គ្រួសារ បានរាយការណ៍ថាបានដាំដំណាំត្រកួននៅទូទាំងប្រទេសកម្ពុជា និងមានផ្ទៃដីដាំដុះ និងផ្ទៃដីប្រមូលផលមានប្រមាណ ៦០៣ ហិកតា។ ចំពោះចំនួនគ្រួសារដែលរាយការណ៍ថាបានដាំដំណាំស្ពៃក្រញ៉ាញ់មានប្រមាណ ៨៦១ នៅទូទាំងប្រទេសកម្ពុជា និងមានទំហំផ្ទៃដីដុះ និងផ្ទៃដីប្រមូលផលប្រមាណ ៧៥២ ហិកតា។ បរិមាណផលសរុបនៃស្ពៃក្រញ៉ាញ់មានប្រមាណ ២ ៩០០ តោន។ គ្រួសារកសិកម្មនៅក្នុងប្រទេសកម្ពុជាមានប្រមាណ ៦៣៣ បានរាយការណ៍ថា មានដាំបន្លែខ្ទឹមស្លឹក ហើយទទួលបានទិន្នផលគិតជាមធ្យមចំនួន ១០,៨ តោន ក្នុង១ហិកតា។ គ្រួសារកសិកម្មប្រមាណ ៦១០ គ្រួសារ បានរាយការណ៍ថា បានដាំបន្លែស្ពៃខ្មៅ ដែលមានទិន្នផលគិតជាមធ្យម ១០,៥ តោន ក្នុង១ហិកតា ។ គ្រួសារកសិកម្មបានរាយការណ៍ថា មានប្រមាណ ៣២៥

គ្រួសារ ដែលបានដាំបន្លែស្ពៃសនៅកម្ពុជា ដែលមានផ្ទៃដីដាំដុះ និងផ្ទៃដីប្រមូលផលមានប្រមាណ ៣៣៧ ហិកតា។

រូប៤.១៦ ចំនួនគ្រួសារកសិកម្មដែលដាំដុះតាមប្រភេទបន្លែស្លឹក ឬដើម




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣*

គ្រួសារកាន់កាប់កសិកម្មបានដាំដុះដំណាំបន្លែត្រកួន មានប្រមាណ ១ ៥០០ គ្រួសារ។ ដំណាំត្រកួនត្រូវបានដាំដុះយ៉ាងទូលំទូលាយបំផុតនៅតំបន់វាលទំនាប។ នៅខេត្តកំពង់ចាមជាខេត្តដែលមានផ្ទៃដីដាំដុះត្រកួនច្រើនជាងគេ មានប្រមាណ ២៧ ភាគរយ នៃផ្ទៃដីដុះទូទាំងប្រទេស។ ខេត្តតាកែវមានផ្ទៃដីដាំដុះត្រកួនប្រមាណ ១៥ ភាគរយ នៃផ្ទៃដីទូទាំងប្រទេស និងខេត្តកណ្តាលជាខេត្តទីបីដែលមានផ្ទៃដីដាំដុះប្រមាណ ១៥ ភាគរយ។

**រូប៤.១៧ ផ្ទៃដីដាំត្រកួនទាំង១០ ខេត្ត**




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣*

ត្រសក់ជាបន្លែដែលត្រូវបានរាយការណ៍ដោយគ្រួសារកាន់កាប់កសិកម្ម គឺបានដាំច្រើនជាងគេដែលមានគ្រួសារប្រមាណ ៣ ០០០ គ្រួសារ បានដាំដុះលើផ្ទៃដីប្រមាណ ១ ៤៥៣ ហិកតា និងផ្ទៃដីប្រមូលផលប្រមាណ ១ ៤៥២ ហិកតា។ នៅតំបន់វាលទំនាបមានផ្ទៃដីដាំត្រសក់ច្រើនជាងគេមានប្រមាណ ៨៧៨ ហិកតា។ ទិន្នផលជាមធ្យមមានប្រមាណ ១១,០ តោន ក្នុង១ហិកតា និងមានបរិមាណផលសរុបប្រមាណ ១៦ ០០០ តោន នៅទូទាំងប្រទេសកម្ពុជា។

ដំណាំឪឡឹក ត្រូវបានគ្រួសារកាន់កាប់កសិកម្មដាំដុះមានប្រមាណ ៩៩០ គ្រួសារ សម្រាប់ប្រទេសកម្ពុជា ដែលមានផ្ទៃដីដាំដុះប្រមាណ ១ ០០០ ហិកតា។ ចំពោះនៅតំបន់បឹងទន្លេសាបមានផ្ទៃដីដាំដុះឪឡឹកប្រមាណ ៥៩៨ ហិកតា។ ឪឡឹកមានបរិមាណផលសរុប ប្រមាណ ៧ ១៤០ តោន ទិន្នផលគិតជាមធ្យមមានប្រមាណ ៧,៣ តោន ក្នុង១ហិកតា។ ចំនួនគ្រួសារកាន់កាប់កសិកម្មដែលបានដាំដុះដំណាំម្ទេសមានប្រមាណ ២ ០០០ គ្រួសារសម្រាប់នៅទូទាំងប្រទេសកម្ពុជា។ ផ្ទៃដីដាំដុះដំណាំម្ទេសសរុបមានប្រមាណ ៨៣១ ហិកតា និងមានប្រមាណ ៥៣០ ហិកតា ត្រូវបានដាំដុះនៅតំបន់បឹងទន្លេសាប។ បរិមាណផលសរុបសម្រាប់ដំណាំម្ទេសមានប្រមាណ ៩ ២៧១ តោន និងទិន្នផលជាមធ្យមប្រមាណ ១១,២ តោន ក្នុង១ហិកតា។

ចំនួនគ្រួសារកាន់កាប់កសិកម្មដែលដាំដុះដំណាំត្រប់មានប្រមាណ ១ ១១០ គ្រួសារ សម្រាប់ប្រទេសកម្ពុជា ដែលមានទិន្នផលជាមធ្យម ៤,២ តោន ក្នុង១ហិកតា។ គ្រួសារកសិកម្ម

ដាំដុះដំណាំននោង មានប្រមាណ ៦៤០ គ្រួសារ សម្រាប់ប្រទេសកម្ពុជា និងមានផ្ទៃដីដាំដុះ និងផ្ទៃដីប្រមូលផលមានប្រមាណ ២២៧ ហិកតា។

រូប៤.១៨ ចំនួនគ្រួសារកសិកម្មដាំដុះតាមប្រភេទបន្លែផ្លែ ទាំង១០ដំណាំ




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣*

រូប៤.១៩ ផ្ទៃដីដាំដុះ តាមប្រភេទបន្លែផ្លែ ទាំង១០ដំណាំ




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣*

បន្លែឫស និងបន្លែមើមរួមមាន ដំឡូងជ្វា ប៉ិគ្គក ខ្ញី ខ្ទឹមស ខ្ទឹមក្រហម និងបន្លែឫស សរសៃ និងបន្លែមើមផ្សេងទៀត។ ដំណាំដំឡូងជ្វាបានរួមចំណែកដ៏ធំជាងគេនៃបន្លែយកឫស/មើមបែប នេះមានគ្រួសារកសិកម្មចំនួនប្រមាណ ២៩៩ គ្រួសារ ដែលមានផ្ទៃដីដាំដុះសរុបប្រមាណ ២៦១

ហិកតា។ ទិន្នផលដំណាំឆៃថាវគិតជាមធ្យមមានប្រមាណ ១១,៨ តោន ក្នុង១ហិកតានិងមានបរិមាណផលសរុបប្រមូលបានមានប្រមាណ ៣ ០៩៤ តោន សម្រាប់នៅប្រទេសកម្ពុជា។




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣*

ដំណាំពពួកសណ្តែកបែតង រួមមានសណ្តែកកួរ សណ្តែកបារាំង និងពពួកសណ្តែកបែតងដទៃទៀត។ សណ្តែកកួរត្រូវបានដាំដុះច្រើនជាងគេដោយគ្រួសារកាន់កាប់កសិកម្មមានប្រមាណ ១ ១៨០ គ្រួសារសម្រាប់ប្រទេសកម្ពុជា។ ផ្ទៃដីដាំដុះ និងផ្ទៃដីប្រមូលផលត្រូវបានប៉ាន់ប្រមាណថាមានប្រមាណ ៥៨៥ ហិកតា។ បរិមាណផលសរុបមានចំនួនប្រមាណ ២ ២១៩ តោន និងមានទិន្នផលជាមធ្យម ៣,៨ តោន ក្នុង១ហិកតា។ តំបន់វាលទំនាបត្រូវបានរាយការណ៍ថាមានការដាំដុះដំណាំនេះច្រើនជាងគេ ដែលមានផ្ទៃដីដាំដុះចំនួន ៣១៦ ហិកតា នៅតំបន់បឹងទន្លេសាបមានចំនួន ២០៨ ហិកតា ដែលបានដាំដុះដំណាំសណ្តែកកួរនៅប្រទេសកម្ពុជា។ សណ្តែកបារាំងមានចំនួន ២៥១ គ្រួសារ ដែលមានផ្ទៃដីដាំដុះប្រមាណ ២៥៥ ហិកតា។




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣*

ប្រភេទបន្លែផ្សេងទៀតដែលគ្របដណ្តប់ក្នុងជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣ រួមមាន ផ្កាខាត់ណា ផ្កាខាត់ណាខៀវ ផ្កាកំប្លោក ទំពាំងបារាំង និងត្រយូងចេក។ ផ្កាខាត់ណា គឺជាបន្លែដ៏ពេញនិយមជាងគេដែលមានគ្រួសារកសិកម្មចំនួនប្រមាណ ៧៣០ គ្រួសារ ដែលបានរាយការណ៍ថាកំពុងដាំដុះដំណាំផ្កាខាត់ណា។ ផ្ទៃដីដាំដុះដំណាំផ្កាខាត់ណា និងផ្ទៃដីប្រមូលផលត្រូវបានប៉ាន់ប្រមាណមានចំនួន ៣៧៤ ហិកតា។ បរិមាណផលប្រមូលបានប្រមាណ ២ ៩៨១ តោន និងទទួលបានទិន្នផលជាមធ្យម ៨,០ តោន ក្នុងមួយហិកតា។ តំបន់វាលទំនាប គឺជាតំបន់ដាំដុះច្រើនជាងគេនៃដំណាំផ្កាខាត់ណាដែលមានផ្ទៃដីដាំដុះប្រមាណ ៣៣៩ ហិកតា ឬស្មើនឹង ៩១ ភាគរយ នៃផ្ទៃដីដាំដុះដំណាំផ្កាខាត់ណាសរុប។ បន្លែផ្កាដទៃទៀតដែលគ្រួសារកសិកម្មបានដាំច្រើនញឹកញាប់ជាងគេនោះ គឺផ្កាខាត់ណាខៀវ ដែលបានរាយការណ៍ថាមានប្រមាណ ៧៨ គ្រួសារ និងមានផ្ទៃដីដាំដុះប្រមាណ ២៦ ហិកតា។

រូប៤.២២ ចំនួនគ្រួសារកសិកម្មដាំបន្លែផ្កាខាត់ណា តាមតំបន់




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣*

## ៤.៩- ដំណាំរយៈពេលវែង

ដាំដំណាំរយៈពេលវែងមានលក្ខណៈបច្ចេកទេស (ដែលមានវដ្តលូតលាស់លើសពីមួយឆ្នាំ) រួមមានរុក្ខជាតិ ដើមឈើ និងគុម្ពដែលបានដាំក្នុងលក្ខណៈបច្ចេកទេសទៀងទាត់ និងជាប្រព័ន្ធ ដូចជា៖ ចម្ការ រុក្ខជាតិ ដើមឈើ និងគុម្ពដែលបានដាំរាយប៉ាយមិនទៀងទាត់ ប៉ុន្តែក្រាស់ល្មមអាចចាត់ទុកថាជាចំការបាន។ ដូចដែលមានក្នុងកំណត់សម្គាល់ មានការចាត់ថ្នាក់ដំណាំរយៈពេលវែងសំខាន់ៗចំនួន ១០ ដែលត្រូវបានប្រើក្នុងការកំណត់អត្តសញ្ញាណដំណាំរយៈពេលវែងផ្សេងៗគ្នានៅក្នុងប្រទេសកម្ពុជា។ ទោះយ៉ាងណាក៏ដោយមិនមែនដំណាំរយៈពេលវែងទាំងអស់មានច្រើននៅក្នុងប្រទេសនោះទេ។ ដូច្នេះមានតែដំណាំរយៈពេលវែងសំខាន់ៗនៅក្នុងចម្ការតូចតែប៉ុណ្ណោះដែលត្រូវបានយកមកបង្ហាញនៅក្នុងជំរឿនកសិកម្មនេះ។

## ៤.១០- ដំណាំក្រូច

ដំណាំក្រូចត្រូវបានគេរកឃើញដាំដុះយ៉ាងសម្បូរបែប នៅប្រទេសកម្ពុជារួមមានដំណាំក្រូចឆ្មារ/ក្រូចសើច/ក្រូចថ្លុង មានគ្រួសារកសិកម្មប្រមាណ ៤២ ៦០០ គ្រួសារ ហើយដំណាំក្រូចពោធិ៍សាត់បានដាំដុះប្រមាណ ៩ ៤០០ គ្រួសារ ចំណែកគ្រួសារកសិកម្មដាំដំណាំក្រូចថ្លុង

ប្រមាណ ៦ ៧០០ និងគ្រួសារកសិកម្មប្រមាណ ៣ ៤០០ គ្រួសារបានរាយការណ៍ថាបានដាំក្រូចសើចផងដែរសម្រាប់នៅទូទាំងប្រទេសកម្ពុជា។

រូប៤.២៣ ចំនួនគ្រួសារដាំដំណាំក្រូចនៅប្រទេសកម្ពុជា បែងចែកតាមប្រភេទក្រូច




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣*

ដំណាំក្រូចឆ្មារ ត្រូវបានដាំដុះញឹកញាប់នៅដីជុំវិញលំនៅឋានជាងការដាំដុះដំណាំនៅលើក្បាលដី។ ប៉ុន្តែចំពោះដំណាំហូបផ្លែខ្លះ ផ្ទៃដីដែលបានដាំលើក្បាលដីនៅទូទាំងប្រទេសគឺមានទំហំធំជាងដីជុំវិញលំនៅឋាន ដោយសារទំហំក្បាលដីធំជាង។ សរុបទំហំផ្ទៃដីដំណាំក្រូចត្រូវបានដាំដុះលើផ្ទៃដី ១ ៨៣៩ ហិកតា ដែលទទួលបានទិន្នផលជាមធ្យម ៣,០ តោន ក្នុង១ហិកតា ក្រូចឆ្មារត្រូវបានដាំលើផ្ទៃដី ១ ៦៣៧ ហិកតា និងមានទិន្នផលជាមធ្យម ៣,៨ តោន ក្នុង១ហិកតា។ ដំណាំផ្លែក្រូចថ្លុងត្រូវបានដាំដុះមានផ្ទៃដី ៥២២ ហិកតា ដែលមានទិន្នផល ៥,០ តោន ក្នុង១ហិកតា។ ដំណាំក្រូចសើចត្រូវបានគេដាំលើផ្ទៃដី ១៥៧ ហិកតា ដោយទទួលបានទិន្នផលជាមធ្យម ១,២ តោន ក្នុង១ ហិកតា។

រូប៤.២៤ ចំនួនផ្ទៃដីដាំណាំក្រូចនៅប្រទេសកម្ពុជា បែងចែកតាមប្រភេទក្រូច




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣*

## ៤.១១- ដំណាំហូបផ្លែ

ប្រភេទដំណាំហូបផ្លែ ដែលបានដាំដុះច្រើនជាងនៅប្រទេសកម្ពុជា រួមមានស្វាយ ចេក ខ្នុរ ល្ហុង ត្របែក ទៀប ទឹកដោះគោ ទុរេន មៀន និងដំណាំហូបផ្លែផ្សេងទៀត។

**រូប៤.២៥ ចំនួនគ្រួសារដាំដំណាំយកផ្លែ តាមប្រភេទ នៅកម្ពុជា (គិតជាពាន់គ្រួសារ)**




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣*

### *៤.១១.១- ដំណាំស្វាយ*

ក្នុងចំណោមដំណាំផ្លែឈើដែលបានដាំដុះ គឺមានដំណាំស្វាយត្រូវបានដាំច្រើនជាងគេនៅកម្ពុជា។ គ្រួសារកសិកម្មមានប្រមាណ ៤៩៦ ០០០ គ្រួសារដែលបានដាំដុះដំណាំស្វាយ

លើផ្ទៃដីទំហំសរុបប្រមាណ ៧០ ០០០ ហិកតា ហើយនិងមានផ្ទៃដីប្រមូលផលសរុបប្រមាណ ៥៩ ០០០ ហិកតា។ ទិន្នផលដំណាំស្វាយទទួលបានគិតជាមធ្យមមាន ៥,៦ តោន ក្នុង១ហិកតា។ គ្រួសារកសិកម្មដាំដុះដំណាំស្វាយបានច្រើនជាងគេ គឺនៅតំបន់បឹងទន្លេសាប ប៉ុន្តែផ្ទៃដីដាំដុះដំណាំស្វាយច្រើនជាងគេគឺនៅតំបន់វាលទំនាប ដែលមានប្រមាណ ៣០ ៨០០ ហិកតា។

រូប៤.២៦ ចំនួនគ្រួសារកសិកម្មដាំដំណាំស្វាយ តាមតំបន់




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣*

### *៤.១១.២- ដំណាំចេក*

ដំណាំចេក គឺជាដំណាំត្រូវបានដាំច្រើនជាងគេទី២នៅកម្ពុជា មានគ្រួសារកសិកម្មចំនួនប្រមាណ ២៩០ ០០០គ្រួសារ ដែលបានរាយការណ៍ថាដាំដុះដំណាំចេកលើផ្ទៃដីទំហំសរុបប្រមាណ ១០ ៥០០ ហិកតា សម្រាប់នៅប្រទេសកម្ពុជា ហើយនិងមានផ្ទៃដីប្រមូលផលសរុបប្រមាណ ៩ ១០០ ហិកតា។ បរិមាណផលដែលបានប្រមូលមានប្រមាណ ៧២ ៨០០ តោន និងទិន្នផលទទួលបានគិតជាមធ្យមមាន ៧,៤ តោន ក្នុង១ហិកតា សម្រាប់ដំណាំចេក។ តំបន់បឹងទន្លេសាប ត្រូវបានរាយការណ៍ថា បានដាំដុះដំណាំចេកច្រើនជាងគេ មានប្រមាណ ៣ ៧០០ ហិកតា។

រូប៤.២៧ ចំនួនគ្រួសារកសិកម្មដាំដំណាំចេកតាមតំបន់




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣*

### *៤.១១.៣- ដំណាំខ្នុរ*

ចំនួនគ្រួសារកាន់កាប់កសិកម្មដែលដាំដុះដំណាំខ្នុរមានប្រមាណ ៧៧ ០០០ គ្រួសារកសិកម្មនៅប្រទេសកម្ពុជា។ ផ្ទៃដីដាំដុះដំណាំខ្នុរមានប្រមាណ ១ ៨០០ ហិកតា និងផ្ទៃដីប្រមូលផលសរុបប្រមាណ ១ ៧០០ ហិកតា។ បរិមាណផលដំណាំខ្នុរមានប្រមាណ ២ ៥៧៦ តោននៅទូទាំងប្រទេស។ ដំណាំខ្នុរត្រូវបានរាយការណ៍ថាបានដាំដុះច្រើនជាងគេនៅតំបន់វាលទំនាបមានចំនួនប្រមាណ ៣៣ ០០០ គ្រួសារកសិកម្ម។




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣*

## ៤.១២- ដំណាំប្រភេទគ្រាប់អាចបរិភោគបាន (ស្វាយចន្ទី)

នៅក្នុងប្រភេទដំណាំគ្រាប់ដែលអាចបរិភោគបាន ដំណាំស្វាយចន្ទីត្រូវបានដាំដុះដោយគ្រួសារកាន់កាប់កសិកម្ម និងដាំដុះលើផ្ទៃដីភាគចំណែកធំជាងគេ។ មានគ្រួសារកសិកម្មសរុបចំនួន ១៥៣ ៣០០ គ្រួសារ ដែលបានដាំដុះដំណាំស្វាយចន្ទី។ គ្រួសារកសិកម្មមានចំនួនប្រមាណ ៥ ៤០០ គ្រួសារ ដែលបានដាំដុះដំណាំស្លា និងមានគ្រួសារកសិកម្មចំនួន ៣ ៩០០ គ្រួសារ ដែលបានដាំដុះដំណាំឈូក។

ដំណាំស្វាយចន្ទីត្រូវបានដាំដុះយ៉ាងច្រើនលើសលប់នៅតំបន់ភ្នំនិងខ្ពង់រាប ដែលមានប្រមាណ ៥០ ភាគរយ នៃគ្រួសារកាន់កាប់កសិកម្មទាំងអស់ដែលដាំដុះដំណាំនេះនៅក្នុងតំបន់នោះ (៧៦ ៣០០ គ្រួសារដែលបានដាំដុះស្វាយចន្ទីនៅក្នុងតំបន់នេះ បើប្រៀបធៀបទៅនឹង ៧៦ ៩០០ គ្រួសារ ដាំដុះស្វាយចន្ទីនៅក្នុងតំបន់ផ្សេងទៀតទាំងអស់រួមបញ្ចូលគ្នា)។ ខេត្តដែលមានផ្ទៃដីដាំដុះច្រើនជាងគេ គឺនៅខេត្តរតនគិរីមាន ៩២ ០០០ ហិកតា បន្ទាប់មកខេត្តក្រចេះមាន ៦២ ៨០០ ហិកតា និងខេត្តកំពង់ធំមាន ៦០ ៩០០ ហិកតា។ ការដាំដុះស្វាយចន្ទីគួរឱ្យកត់សម្គាល់ក៏ត្រូវបានរាយការណ៍ថានៅខេត្តកំពង់ចាម ស្ទឹងត្រែង ត្បូងឃ្មុំ និងព្រះវិហារ។ គ្រាប់ស្វាយចន្ទីត្រូវបានដាំដុះដោយគ្រួសារកាន់កាប់កសិកម្មដែលដាំដុះលើផ្ទៃដីសរុបចំនួន ៣៧០ ០០០ ហិកតា ហើយនិងបានប្រមូលផលមានផ្ទៃដីសរុបចំនួន ៣៤០ ០០០ ហិកតា

ដោយទទួលបានទិន្នផលជាមធ្យម ២,៩ តោន ក្នុង១ហិកតា។

រូប៤.២៩ ផ្ទៃដីដាំស្វាយចន្ទី (គិតជាហិកតា) ខេត្តចំនួន១០ដែលដាំដុះច្រើនជាងគេ




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

## ៤.១៣- ដំណាំយកប្រេង (ដូង)

ដំណាំយកប្រេងជាចម្បងមានដើមដូង ដើមដូងប្រេង ដើមត្នោត និងដំណាំយកប្រេងផ្សេងៗទៀត។ ការធ្វើជំរឿនបែងចែករវាងដូងប្រេង និងស្ករត្នោត ដោយសារដើមត្នោតត្រូវបានប្រើប្រាស់ក្នុងគោលបំណងជាច្រើន រួមមានការកែច្នៃស្ករត្នោត ប្រេងដែលអាចបរិភោគបាន។ល។ ក្នុងចំណោមគ្រួសារកាន់កាប់កសិកម្ម ដំណាំដូង គឺជាប្រភេទដំណាំយកប្រេងដែលត្រូវបានដាំដុះច្រើនបំផុតដែលមានគ្រួសារដាំដុះរហូតដល់ចំនួន ៣៦០ ៣០០ គ្រួសារ បើធៀបទៅនឹងគ្រួសារដែលបានដាំដុះត្នោតចំនួន ៣ ៥០០គ្រួសារ និងគ្រួសារដែលបានដាំដូងប្រេងចំនួន ៨៨ គ្រួសារ។

សរុបមកដំណាំដូងត្រូវបានដាំដុះលើផ្ទៃដី ១៧ ២០០ ហិកតា នៃគ្រួសារទូទាំងប្រទេសដែលមានការដាំដុះនេះ គឺភាគច្រើនជាងគេនៅតំបន់ឆ្នេរសមុទ្រមានរហូតដល់ចំនួន ៦ ៨០០ ហិកតា បន្ទាប់មកនៅតំបន់បឹងទន្លេសាបមាន ៤ ៨០០ ហិកតា តំបន់វាលទំនាបមាន ៤ ០០០ ហិកតា និងចុងក្រោយគឺនៅតំបន់ភ្នំនិងខ្ពង់រាបមាន ១ ៦០០ ហិកតា។ ដោយមានផ្ទៃដីដាំដុះមាន ៦ ០០០ ហិកតា នៅខេត្តកំពត ឬស្មើនឹងចំនួន ៣៥ ភាគរយ នៃផ្ទៃដីសរុបដែលប្រើ

សម្រាប់ដាំដូងក្នុងប្រទេសកម្ពុជា។ ផ្ទៃដីដាំដុះសរុបចំនួន ១៤ ៨០០ ហិកតា ត្រូវបានប្រមូលផល ហើយនិងមានទិន្នផលសរុប ៨៧ ៦០០ តោន ដែលមានទិន្នផលទទួលបានជាមធ្យមគឺ ១០,៣ តោន ក្នុង១ហិកតា។

រូប៤.៣០ ផ្ទៃដីដាំដូង (គិតជាហិកតា) ខេត្តចំនួន ១០ ដែលដាំដុះច្រើនជាងគេ




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

## ៤.១៤- ដំណាំសម្រាប់គ្រឿងទេស

ដំណាំម្រេចត្រូវបានរាប់បញ្ចូលជាប្រភេទដំណាំគ្រឿងទេស ដែលមានដាំដុះច្រើនជាងគេនៅកម្ពុជា ដែលមានគ្រួសារកសិកម្មសរុបប្រមាណ ៨ ៤០០ គ្រួសារ ដែលមានដាំដុះលើផ្ទៃដីចំនួន ៦ ៩០០ ហិកតា។ បន្ទាប់មកគ្រួសារកាន់កាប់កសិកម្មដាំដុះដំណាំអំពិលមានប្រមាណ ៥ ០០០ គ្រួសារ ដែលដាំដុះលើផ្ទៃដីសរុបប្រមាណ ៣៦៧ ហិកតា។ ដំណាំម្រេចមានការដាំដុះច្រើនជាងគេនៅតំបន់វាលទំនាប ដែលមានប្រមាណ ៤ ៧០០ ហិកតា។ បន្ទាប់មកនៅតំបន់វាលទំនាបដាំម្រេចមាននៅខេត្តត្បូងឃ្មុំ ដែលមានចំនួនប្រមាណ ៤ ៦០០ ហិកតា។

រូប៤.៣១ ចំនួនផ្ទៃដីដាំម្រេច (គិតជាហិកតា) តាមខេត្ត (ខេត្តចំនួន១០សំខាន់ៗ)




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣*

## ៤.១៥- ដំណាំកៅស៊ូ

ដំណាំកៅស៊ូ ត្រូវបានដាំដុះជាចម្បងនៅក្នុងក្រុមហ៊ុនឯកជន ឬសហគ្រាសធំៗមានភាគច្រើនជាងគ្រួសារកាន់កាប់កសិកម្ម។ ដូចនេះ ការប៉ាន់ប្រមាណសម្រាប់ផលិតកម្មកៅស៊ូគ្រួសារនៅក្នុងរបាយការណ៍នេះ មានកម្រិតទាបជាងនៅក្នុងប្រទេសទាំងមូល។ ទោះជាយ៉ាងនេះក្តី កៅស៊ូត្រូវបានរាយការណ៍ថាមានគ្រួសារកាន់កាប់កសិកម្មមានចំនួន ៤២ ៣០០ គ្រួសារនៅក្នុងប្រទេសកម្ពុជា ដែលមានផ្ទៃដីដាំដុះសរុបចំនួន ១១១ ៥០០ ហិកតា ដែលមានផ្ទៃដីប្រមូលផលប្រមាណ ៩៥ ៦០០ ហិកតា និងមានបរិមាណផលសរុបចំនួន ៥១៤ ០០០ តោន។

ផលិតកម្មដំណាំកៅស៊ូ ត្រូវបានបង្ហាញថាមាននៅតំបន់វាលទំនាប និងនៅតំបន់ភ្នំនិងខ្ពង់រាប ដែលមានប្រមាណ ៦៧ ភាគរយ និង ២៧ ភាគរយ នៃផ្ទៃដីដែលប្រមូលផលកៅស៊ូបានមកពីតំបន់ទាំងពីរនេះ តាមលំដាប់រៀង។

ផលិតកម្មដំណាំកៅស៊ូនេះ មានភាគច្រើនមកពីខេត្តចំនួនបី រួមមានខេត្តត្បូងឃ្មុំដែលមានផ្ទៃដីចំនួនប្រមាណ ៥៧ ៥០០ ហិកតា ខេត្តក្រចេះមាន ១០ ៧០០ ហិកតា និងខេត្តរតនគិរី ៨ ៨០០ ហិកតា។

## ៤.១៦- ដំណាំមិនមែនអាហារ

ដំណាំឫស្សីជាដំណាំដែលប្រើប្រាស់សម្រាប់គោលបំណងជាច្រើន រួមមានសម្រាប់ការសាងសង់ផ្ទះ គ្រឿងសង្ហារឹម និងការចម្អិនអាហារ ហើយវាជាដំណាំមិនមែនអាហារនោះទេ។ ដំណាំប្រភេទនេះមានផ្ទៃដីដាំដុះចំនួនប្រមាណ ២៤៣ ហិកតា និងមានផ្ទៃដីប្រមូលផលចំនួនប្រមាណ ១៦៧ ហិកតា ដែលមានគ្រួសារកាន់កាប់កសិកម្មប្រមាណជាង ៤ ០០០ គ្រួសារ ដែលបានរាយការណ៍ថាបានដាំដុះដំណាំឫស្សី។ នៅខេត្តស្វាយរៀងមានដាំដុះដំណាំឫស្សីច្រើនជាងគេមានប្រមាណ ៥៧ ហិកតា។

# ជំពូកទី៥

# ធាតុចូល និងសេវាកម្ម នៃវិស័យកសិកម្ម

## ៥.១- ការប្រើប្រាស់ឧបករណ៍បរិក្ខា និង គ្រឿងម៉ាស៊ីនកសិកម្ម

គ្រួសារកាន់កាប់កសិកម្មនៅកម្ពុជា នៅតែនិយមប្រើប្រាស់ឧបករណ៍បរិក្ខាបុរាណ មានដូចជា ចបកាប់ កណ្តៀវ រនាស់ដៃ និងគោយន្តកន្ត្រៃជាដើម។ គ្រួសារកសិកម្មបាននឹងកំពុងប្រើប្រាស់ចបកាប់មាន ១,៨៩ លានចបកាប់ និងមាន១,៣៥ លានកណ្តៀវ ធុងបាញ់ថ្នាំមាន ៧៩១ ៣០០ ធុង និងមានគោយន្ត ៥១៦ ០០០ សម្រាប់ប្រើប្រាស់ក្នុងវិស័យកសិកម្មរបស់ខ្លួន គិតក្នុងអំឡុងពេលចុះធ្វើជំរឿនកសិកម្មឆ្នាំ២០២៣។

លើសពីនេះ ឧបករណ៍បរិក្ខា និងគ្រឿងម៉ាស៊ីនកសិកម្មបែបទំនើប ក៏ត្រូវបានប្រើប្រាស់ក្នុងសកម្មភាពកសិកម្មផងដែរ ដូចជាមានម៉ូតូ/រ៉ឺម៉កកង់បីមានចំនួន ៩៧៩ ២០០ គ្រឿង ដែលត្រូវបានប្រើប្រាស់ជាមធ្យោបាយដឹកជញ្ជូនក្នុងសកម្មភាពការងារកសិកម្ម មានម៉ាស៊ីន/ម៉ូទ័របូមទឹកចំនួន ៥០៤ ០០០គ្រឿង ម៉ាស៊ីនច្រូតចំនួន ៨៨ ៧០០ គ្រឿង ត្រាក់ទ័រចំនួន ៨៧ ៧០០ គ្រឿង ម៉ាស៊ីនកិនស្រូវចំនួន ២១ ៧០០ គ្រឿង និងម៉ាស៊ីនបោកចំនួន ២០ ៨០០ គ្រឿង។ ក្រៅពីនេះ ក៏មានឧបករណ៍ប្រើប្រាស់ដើរដោយថាមពលពន្លឺព្រះអាទិត្យចំនួន ៣ ៧០០ គ្រឿង ត្រូវបាននឹងកំពុងប្រើប្រាស់ដោយគ្រួសារកសិកម្ម ម៉ាស៊ីនភ្លើងមានប្រមាណ ២ ១០០ គ្រឿង និងម៉ាស៊ីនភ្ញាស់ប្រើប្រាស់សម្រាប់ភ្ញាស់បសុបក្សីមានចំនួន ១ ៣០០ គ្រឿង ក៏កំពុងត្រូវបានប្រើប្រាស់ដោយគ្រួសារកសិកម្មកម្ពុជាផងដែរ។

ក្នុងចំណោមឧបករណ៍បរិក្ខា និងគ្រឿងម៉ាស៊ីនកសិកម្មដែលបានរៀបរាប់ខាងលើ ជាទូទៅបានមកពីការទិញច្រើនជាងការកែច្នៃ/ផលិតដោយខ្លួនឯង។ ចំពោះការខ្ចីពីរដ្ឋាភិបាល ឬការជួលពីវិស័យឯកជន លើកលែងតែម៉ាស៊ីនច្រូតកាត់ដែលជួលច្រើនជាងពីវិស័យឯកជន (៥១ ០០០) តិចជាងវិធីប្រើប្រាស់ផ្សេងទៀត (៣៨ ០០០ ជាម្ចាស់ផ្ទាល់ និង ៤០០ បានខ្ចីគេ)។

រូប៥.១ ចំនួនឧបករណ៍បរិក្ខា និងគ្រឿងម៉ាស៊ីនកសិកម្ម




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

## ៥.២- ការប្រើប្រាស់ប្រព័ន្ធស្រោចស្រព

ដោយសារវត្តមាននៃប្រព័ន្ធធារាសាស្ត្រយ៉ាងទូលំទំលាយនៅទូទាំងប្រទេស គ្រួសារកាន់កាប់កសិកម្មមានប្រមាណ ៣៨០ ០០០ គ្រួសារ ដែលបានប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រក្នុងការស្រោចស្រព លើផ្ទៃដីកសិកម្មប្រមាណ ៤៦៤ ៥០០ ហិកតា។ ផ្អែកតាមសណ្ឋានដីដែលអំណោយផល នៅតំបន់វាលទំនាបមានចំនួនគ្រួសារកសិកម្មច្រើនជាងគេ (២៣១ ៤០០ គ្រួសារកសិកម្ម) និងមានផ្ទៃដីស្រោចស្រព (២៣៥ ១០០ ហិកតា) ស្មើនឹង ៥១ ភាគរយ នៃផ្ទៃដីស្រោចស្រពទាំងអស់នៅក្នុងប្រទេស។ នៅតំបន់បឹងទន្លេសាបមាន ៤៥ ភាគរយ នៃផ្ទៃដីស្រោចស្រពរបស់ប្រទេស (២០៨ ១០០ ហិកតា) ប៉ុន្តែតំបន់នេះបែរជាមានចំនួនគ្រួសារកសិកម្មតិចតួចប៉ុណ្ណោះ (១២៦ ៣០០ គ្រួសារកសិកម្ម)។

រូប៥.២ ភាគរយនៃផ្ទៃដីសរុបបានស្រោចស្រពតាមតំបន់នៅកម្ពុជា




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

ប្រភពនៃប្រព័ន្ធធារាសាស្ត្រនៅកម្ពុជា ត្រូវបានបែងចែកជាប្រភពធារាសាស្ត្ររបស់រដ្ឋាភិបាល ប្រភពផ្សេងទៀត ឬ ប្រភពទាំងពីរនៅក្នុងកម្រងសំណួរ។ ប្រភពផ្សេងទៀតត្រូវបានប្រើញឹកញាប់បំផុតសម្រាប់ប្រព័ន្ធធារាសាស្ត្រក្នុងប្រទេសកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ ប្រភពនេះគឺភាគច្រើនមាននៅតែតំបន់វាលទំនាបប៉ុណ្ណោះដែលប្រភពផ្សេងទៀតរាប់ជាប្រភពនៃប្រព័ន្ធធារាសាស្ត្រសម្រាប់ ១០៧ ០០០ គ្រួសារកសិកម្ម បើប្រៀបធៀបទៅនឹង ៦១ ០០០ គ្រួសារ ដែលបានប្រើប្រាស់ប្រភពធារាសាស្ត្ររបស់រដ្ឋាភិបាល។ ប្រភពផ្សេងទៀតត្រូវបានប្រើប្រាស់ញឹកញាប់ជាងនៅក្នុងតំបន់ឆ្នេរសមុទ្រផងដែរ។ ចំណែកឯនៅតំបន់បឹងទន្លេសាប និងតំបន់ភ្នំនិងខ្ពង់រាប ប្រភពប្រព័ន្ធធារាសាស្ត្ររបស់រដ្ឋាភិបាលគឺត្រូវបានប្រើប្រាស់ញឹកញាប់ជាងប្រភពផ្សេងទៀត។

រូប៥.៣ ចំនួនគ្រួសារបានប្រើប្រាស់ប្រព័ន្ធស្រោចស្រពបែងចែកតាមតំបន់




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

ប្រព័ន្ធធារាសាស្ត្រត្រូវបានអនុវត្តជាធម្មតាក្រោមប្រព័ន្ធធារាសាស្ត្រដែលមានការគ្រប់គ្រងពេញលេញជាជាងប្រព័ន្ធធារាសាស្ត្រដែលគ្រប់គ្រងដោយផ្នែកៗ។ គិតជាមធ្យម ៩៧ ភាគរយនៃដីធារាសាស្ត្រស្ថិតនៅក្រោមប្រព័ន្ធធារាសាស្ត្រដែលត្រូវបានគ្រប់គ្រងពេញលេញ។ នៅតំបន់ឆ្នេរសមុទ្រ បានរាយការណ៍អំពីសមាមាត្រទាបបំផុតនៃប្រព័ន្ធធារាសាស្ត្រ ដែលគ្រប់គ្រងពេញលេញ និងសមាមាត្រខ្ពស់បំផុតនៃប្រព័ន្ធធារាសាស្ត្រដែលគ្រប់គ្រងដោយផ្នែកនៅការបែងចែក ៨៩ ភាគរយ បានគ្រប់គ្រងពេញលេញ និង ១១ ភាគរយ ត្រូវបានគ្រប់គ្រងដោយផ្នែក។

## ៥.៣- ការប្រើប្រាស់ជី

ជីគីមី គឺត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយបំផុតដែលមានប្រមាណ ៧៣ ភាគរយ នៃគ្រួសារកសិកម្មប្រើប្រាស់ជីគីមី។ ជីផ្សេងៗត្រូវបានគេប្រើយ៉ាងទូលំទូលាយផងដែរ ជាមួយនិងជីលាមកសត្វដែលបានរាយការណ៍ថាមានប្រមាណ ៣២ ភាគរយ នៃគ្រួសារកសិកម្ម ជីសរីរាង្គ-គីមីដែលបានពីការលាយបញ្ចូលគ្នានៃសារធាតុសរីរាង្គ និងសារធាតុគីមី ត្រូវបានប្រើប្រាស់ប្រមាណ ១៨ ភាគរយ នៃគ្រួសារកសិកម្ម ការប្រើប្រាស់ជីសរីរាង្គមានកម្រិតទាបនៅឡើយដែលមានប្រមាណ ៧ ភាគរយ វាបានបង្ហាញពីការផ្លាស់ប្តូរមានកម្រិតកំណត់នៅក្នុងការអនុវត្តជីសរីរាង្គ ហើយនិងជីជីវសាស្ត្រក៏ត្រូវបានប្រើប្រាស់ត្រឹម ៤ ភាគរយ តែប៉ុណ្ណោះ។

រូប៥.៤ ចំនួនគ្រួសារកសិកម្មបានប្រើប្រាស់ជីតាមប្រភេទជីកសិកម្ម




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

ការប្រើប្រាស់ជីមានភាពខុសគ្នានៅទូទាំងតំបន់កសិកម្មរបស់ប្រទេសកម្ពុជា។ តំបន់វាលទំនាបបង្ហាញពីការប្រើប្រាស់ជីគីមីខ្ពស់ជាងគេ ខណៈដែលមានការប្រើប្រាស់ជីលាមកសត្វនៅតែកត្តាធាតុចូលដ៏សំខាន់លំដាប់ទីពីរ។ នៅតំបន់បឹងទន្លេសាបបានបង្ហាញពីវិធីសាស្ត្រដែលមានតុល្យភាពជាងមុនដែលទាក់ទងការប្រើប្រាស់ជីសរីរាង្គ-គីមីច្រើនជាងគេ ហើយនិងការប្រើប្រាស់ជីសរីរាង្គខ្ពស់ជាងបន្តិច បើប្រៀបធៀបទៅនឹងតំបន់កសិកម្មផ្សេងទៀត។ នៅតំបន់ឆ្នេរសមុទ្រមានធាតុចូលតាមលក្ខណៈបែបប្រពៃណីដែលបានប្រើប្រាស់ ដោយគ្រួសារកាន់កាប់កសិកម្មមានជិតពាក់កណ្ដាល ដែលពឹងផ្អែកលើជីលាមកសត្វ ហើយនិងការប្រើប្រាស់ជីទំនើបគឺនៅមានកម្រិត ដូចជាជីសរីរាង្គ-គីមី ឬ ជីជីវសាស្ត្រ។ នៅតំបន់ភ្នំនិងខ្ពង់រាបបានបង្ហាញអំពីការប្រើប្រាស់ជីលាយគ្នា នៃវិធីសាស្ត្រតាមបែបប្រពៃណី និងចម្រុះជាមួយនឹងកាប្រើប្រាស់ជីគីមីទាបជាង បើប្រៀបធៀបទៅនឹងតំបន់ផ្សេងទៀត។ ប៉ុន្តែការប្រើប្រាស់ជីជីវសាស្ត្រ និងជីសរីរាង្គនៅមានកម្រិតខ្ពស់ជាង។

រូប៥.៥ ភាគរយនៃគ្រួសារកសិកម្មទាំងអស់ប្រើប្រាស់ជីនីមួយៗតាមប្រភេទ បែងចែកតាមតំបន់




* អ្នកតបការសម្ភាសអាចជ្រើសរើសជីបានច្រើនជាង១ ប៉ុន្តែភាគរយមិនអាចច្រើនជាង ១០០%។

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

## ៥.៤- ការប្រើប្រាស់ថ្នាំកសិកម្ម

ទិន្នន័យនៃការប្រើប្រាស់ថ្នាំកសិកម្ម បានបង្ហាញអំពីការចែកចាយ និងការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតចង្រៃនៅទូទាំងតំបន់ផ្សេងៗនៅក្នុងប្រទេសកម្ពុជាសម្រាប់ដំណាំដែលបានដាំក្នុងរយៈពេល ១២ ខែកន្លងមកនេះ។ ថ្នាំសម្លាប់ស្មៅ គឺជាប្រភេទថ្នាំដែលប្រើប្រាស់ច្រើនជាងគេបំផុតមានចំនួនប្រមាណ ១ ២២០ ៧០០ គ្រួសារ ដែលបានប្រើប្រាស់ថ្នាំសម្លាប់ស្មៅ ហើយបន្ទាប់គឺការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតចង្រៃមានប្រមាណ ១ ០១៥ ២០០ គ្រួសារ។ ការប្រើប្រាស់ថ្នាំសម្លាប់ផ្សិត ថ្នាំសម្លាប់សត្វកកេរ និងប្រភេទថ្នាំសម្លាប់សត្វល្អិតដទៃទៀត គឺនៅមានកម្រិតទាបជាងគួរឱ្យកត់សម្គាល់ ដែលបានបង្ហាញអំពីតម្រូវការជាក់លាក់ដោយផ្អែកលើតម្រូវការដាំដុះដំណាំ និងសត្វចង្រៃទូទៅ។




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

នៅតំបន់វាលទំនាប និងតំបន់បឹងទន្លេសាប បានបង្ហាញអំពីការប្រើប្រាស់ថ្នាំកសិកម្ម មានកម្រិតខ្ពស់ជាងគេបំផុត។ គ្រួសារដែលបានប្រើប្រាស់ថ្នាំសម្លាប់ស្មៅមានប្រមាណ ៦៩ ភាគរយ នៃគ្រួសារកសិកម្មនៅក្នុងតំបន់វាលទំនាប និងមាន ៦៧ ភាគរយ នៅតំបន់បឹងទន្លេសាប។ ដូចគ្នានេះដែរ គ្រួសារដែលបានប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតចង្រៃ មានប្រមាណ ៦៥ ភាគរយ នៃគ្រួសារកសិកម្មនៅក្នុងតំបន់វាលទំនាប និងមានប្រមាណ ៥៣ ភាគរយ នៅក្នុងតំបន់បឹងទន្លេសាប។ នៅតំបន់ឆ្នេរសមុទ្រ និងតំបន់ភ្នំនិងខ្ពង់រាប តំបន់ទាំងពីរតំណាងឱ្យចំនួនគ្រួសារកសិកម្មសរុបនៅក្នុងប្រទេសកម្ពុជា ដែលមានភាគរយនៃគ្រួសារកសិកម្មប្រើប្រាស់ថ្នាំកសិកម្មនៅមានកម្រិតភាគរយទាបជាងគេ។

**រូប៥.៧ ភាគរយនៃគ្រួសារកសិកម្មប្រើប្រាស់ថ្នាំសម្លាប់ស្មៅ និងថ្នាំសម្លាប់សត្វចង្រៃ បែងចែកតាមតំបន់**




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

## ៥.៥- ភាពអាចទទួលបានឥណទាន និង ប្រាក់កម្ចី

គ្រួសារកសិកម្មចំនួន ៣០៨ ៣០០ ឬស្មើនឹង ១៧ ភាគរយនៃគ្រួសារកាន់កាប់កសិកម្មសរុបដែលបានទទួលឥណទាន និងប្រាក់កម្ចីសម្រាប់គាំទ្រដល់សកម្មភាពកសិកម្ម។ ក្នុងនោះមានគ្រួសារកាន់កាប់កសិកម្មកសិកម្មប្រមាណ ១៧៤ ០០០ គ្រួសារ ឬស្មើនឹង ៩ ភាគរយនៃគ្រួសារសរុបដែលបានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ នៅខណៈដែលមានគ្រួសារចំនួនប្រមាណ ៤ ភាគរយ ដែលបានទទួលឥណទាន និងប្រាក់កម្ចីពីធនាគារ និងមានអត្រា ២ ភាគរយ ដែលបានខ្ចីប្រាក់ពីមិត្តភក្តិ ឬសាច់ញាតិ។

រូប៥.៨ ចំនួនគ្រួសារកសិកម្មដែលបានទទួលឥណទាន/ប្រាក់កម្ចី តាមប្រភពនៃកម្ចី




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

សមាមាត្រនៃគ្រួសារកាន់កាប់កសិកម្មដែលទទួលបានឥណទាន ប្រាក់កម្ចីពីមីក្រូហិរញ្ញវត្ថុ និងធនាគារ គឺមានទំហំខ្ពស់ជាងនៅតំបន់ភ្នំនិងខ្ពង់រាប និងតំបន់បឹងទន្លេសាប។ នៅតំបន់ភ្នំនិងខ្ពង់រាប មានគ្រួសារកសិកម្មប្រមាណ ១៦ ភាគរយ ដែលទទួលបានឥណទាន និងប្រាក់កម្ចីពីមីក្រូហិរញ្ញវត្ថុ និងមាន ៧ ភាគរយ ដែលទទួលបានឥណទាន និងប្រាក់កម្ចីពីធនាគារ នៅខណៈដែលតំបន់បឹងទន្លេសាប មានតែ ១២ ភាគរយ ដែលទទួលបានពីមីក្រូហិរញ្ញវត្ថុ និងមាន ៥ ភាគរយ ដែលទទួលបានពីធនាគារ។

## ៥.៦- បង្កើតបណ្តាញទីផ្សារលក់ផលិតផលកសិកម្ម

ឈ្មួញកណ្តាល គឺជាបណ្តាញទីផ្សារលក់ផលិតផលកសិកម្មដ៏សំខាន់ របស់គ្រួសារកសិកម្ម។ គ្រួសារកសិកម្មមានប្រមាណ ៩៦៨ ៥០០ គ្រួសារ ដែលបានលក់ផលិតផលកសិកម្មរបស់គេដល់ឈ្មួញកណ្តាល។ បណ្តាញទីផ្សារក្នុងស្រុក គឺជាជម្រើសទីពីរក្នុងការលក់ផលិតផលកសិកម្មមានចំនួនប្រមាណ ៧៧៧ ៩០០គ្រួសារ ខណៈពេលដែលគ្រួសារកសិកម្មមានប្រមាណ ៥៣៧ ៧០០ គ្រួសារ ដែលបានលក់ផលិតផលកសិកម្មរបស់គេនៅកសិដ្ឋានផ្ទាល់។ មានចំនួនគ្រួសារកសិកម្មតិចតួច ដែលបានរាយការណ៍ថាបានលក់ផលិតផលកសិកម្មរបស់គេតាមរយៈក្រុមហ៊ុនឯកជន (កិច្ចសន្យា) (២១ ៤០០គ្រួសារ) និងសហគមន៍កសិករ (៣

៩០០គ្រួសារ)។




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

## ៥.៧- ការចំណាយរបស់គ្រួសារកាន់កាប់កសិកម្ម

### *៥.៧.១- ការចំណាយសម្រាប់ផលិតកម្មដំណាំ*

គ្រួសារកម្ពុជាផលិតដំណាំមានប្រមាណ ១,៧៤ លានគ្រួសារ នៅក្នុងចំណោមគ្រួសារកាន់កាប់កសិកម្មសរុបចំនួន ១,៨៥ លានគ្រួសារ។ គ្រួសារកាន់កាប់កសិកម្មបានចំណាយលើធាតុចូល ដូចជា ជី ថ្នាំសម្លាប់ស្មៅ (រឹង និង រាវ) ច្រើនជាងការចំណាយផ្សេងៗទៀត។ ចំណាយធាតុចូលគិតជាមធ្យមមានចំនួន ៩៨០ ០០០ រៀល (ប្រមាណ ២៤៥ ដុល្លារ) ក្នុងមួយឆ្នាំ។ ការចំណាយបន្ទាប់មានកម្រិតខ្ពស់ជាងគេ គឺកិច្ចសន្យាខ្នាតតូច (៥៤១ ០០០រៀល - ស្មើប្រមាណ ១៣៥ដុល្លារ) និងគ្រាប់ពូជដំណាំ (៤៨២ ០០០រៀល - ស្មើប្រមាណ ១២០ ដុល្លារ) ។




រូប៥.១០ ការចំណាយជាមធ្យមលើការដាំដុះដំណាំក្នុងរយៈពេល១២ខែចុងក្រោយ នៅប្រទេសកម្ពុជា

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

### *៥.៧.២- ផលិតកម្មបសុសត្វ និង បសុបក្សី*

ការចំណាយលើការចិញ្ចឹមបសុសត្វ និងបសុបក្សីមានកម្រិតទាបសម្រាប់គ្រួសារកសិកម្ម។ គ្រួសារកសិកម្មភាគច្រើនបានរាយការណ៍ថាការចំណាយតិចតួចណាស់ដោយសត្វត្រូវបានគេបង្កាត់ជាជាងទិញមកចិញ្ចឹម។ សត្វចិញ្ចឹមត្រូវបានឱ្យចំណីពីសំណល់ផ្សេងៗជាជាងចំណី និងធាតុចូលផ្សេងទៀតមានតិចតួច។ ការចំណាយប្រចាំឆ្នាំជាមធ្យមក្នុងការចិញ្ចឹមបសុសត្វ ឬបសុបក្សីបូកបញ្ចូលគ្នាលើការចំណាយគ្រប់ប្រភេទ (ធាតុចូល ចំណី ការទិញសត្វ កម្លាំងពលកម្ម និងការដឹកជញ្ជូន និងផ្សេងៗទៀត) គឺ ១៣២ ៨០៧ រៀលខ្មែរ (ស្មើប្រមាណ ៣៣,២០ដុល្លារ)។

រូប៥.១១ ការចំណាយជាមធ្យមលើការចិញ្ចឹមបសុសត្វនិងបសុបក្សី ក្នុងរយៈពេល១២ខែចុងក្រោយ នៅប្រទេសកម្ពុជា




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

# ជំពូកទី៦

# ការចិញ្ចឹមបសុសត្វ និង បសុបក្សី

## ៦.១- បសុសត្វ និង បសុបក្សី

ការចិញ្ចឹមសត្វនៅក្នុងប្រទេសកម្ពុជា គឺជាសកម្មភាពកសិកម្មដ៏សំខាន់មួយដែលត្រូវបានធ្វើឡើងដោយគ្រួសារកសិកម្ម និងមានតួនាទីជាចម្បងក្នុងការផ្គត់ផ្គង់ជីវភាពរស់នៅ រួមទាំងផ្តល់ប្រាក់ចំណូលដល់គ្រួសារនៅតំបន់ជនបទ។

**តារាង៦.១ ចំនួនគ្រួសារកសិកម្មដែលមានសកម្មភាពចិញ្ចឹមបសុសត្វ ឬបសុបក្សី ឬសត្វល្អិត**

| ប្រទេសកម្ពុជា (ចំនួនគ្រួសារកាន់កាប់កសិកម្ម គិតជាពាន់) | | | | |
|---|---|---|---|---|
| សរុប | បសុសត្វធំ | បសុសត្វតូច | បសុបក្សី | សត្វល្អិត |
| ១ ០៨៣ | ៦៩០ | ៩៥ | ៧២៧ | ២ |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

នៅពេលធ្វើជំរឿននេះ មានគ្រួសារប្រមាណជា ៥៩ ភាគរយ (១,១លានគ្រួសារ) នៃគ្រួសារកាន់កាប់កសិកម្មនៅទូទាំងប្រទេសកម្ពុជាបានចិញ្ចឹមបសុសត្វនិង/ឬបសុបក្សី។ បសុសត្វ និងបសុបក្សីភាគច្រើនត្រូវបានចិញ្ចឹមដោយគ្រួសារកសិកម្មនៅតំបន់បឹងទន្លេសាប(៤៣០ ២០០ គ្រួសារ) ប៉ុន្តែគ្រួសារដែលចិញ្ចឹមបសុសត្វតែមួយម៉្យាងនោះ គឺមានភាគច្រើននៅតំបន់ឆ្នេរសមុទ្រ ដែលមានចំនួនប្រមាណ ៧៧ ភាគរយ (៩៥ ៤០០គ្រួសារ ក្នុងចំណោម ១២៤ ២០០គ្រួសារកសិកម្ម) នៃគ្រួសារចិញ្ចឹមបសុសត្វ ឬ បសុបក្សីសរុប។

**រូប៦.១ ចំនួនគ្រួសារកសិកម្មដែលមានសកម្មភាពចិញ្ចឹមបសុសត្វ បសុបក្សី និងសត្វល្អិត បែងចែកតាមតំបន់**




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

នៅកម្រិតថ្នាក់ខេត្ត មានតែខេត្តព្រៃវែងទេដែលមានចំនួនគ្រួសារចិញ្ចឹមបសុសត្វ និងបសុបក្សីច្រើនជាងគេបំផុត (១២០ ៧០០ គ្រួសារ ស្មើនឹង ២៩ ភាគរយ នៃគ្រួសារសរុបនៅក្នុងតំបន់វាលទំនាប។ បន្ទាប់ពីខេត្តនេះ គឺមានខេត្តស្វាយរៀង (៩៥ ២០០ គ្រួសារ) និងខេត្តតាកែវ (៨៧ ៨០០ គ្រួសារ) ដែលស្ថិតនៅតំបន់ដូចគ្នា (តំបន់វាលទំនាប)។ ចំណែកឯខេត្តដែលមានភាគរយខ្ពស់បំផុត នៃគ្រួសារកសិកម្មដែលចិញ្ចឹមបសុបក្សី គឺនៅខេត្តឧត្តរមានជ័យ (៨៧ ភាគរយ) និងខេត្តកែប (៨៩ ភាគរយ)។

រូប៦.២ ចំនួនគ្រួសារកសិកម្មដែលចិញ្ចឹមបសុសត្វឬបសុបក្សី បែងចែកតាមខេត្ត




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

តាមលទ្ធផលនៃការធ្វើជំរឿនកសិកម្មនេះ បានបង្ហាញថាមានគ្រួសារកាន់កាប់កសិកម្ម ចំនួនប្រមាណ ៣៨ ភាគរយ នៃគ្រួសារកាន់កាប់កសិកម្មនៅទូទាំងប្រទេសបានចិញ្ចឹមបសុសត្វធំ និងមាន ៣៩ ភាគរយ សម្រាប់ចិញ្ចឹមបសុបក្សី និងមាន ៥ ភាគរយ សម្រាប់ការចិញ្ចឹមបសុសត្វតូច។ មានន័យថាគ្រួសារកសិកម្ម គឺចូលចិត្តចិញ្ចឹមបសុសត្វធំជាងបសុសត្វតូច។ លើសពីនេះ មានគ្រួសារជាច្រើនបានចិញ្ចឹមសត្វរួមគ្នារវាងបសុសត្វធំ និងបសុបក្សីនៅក្នុងពេលតែមួយ។

ការចិញ្ចឹមបសុសត្វ គឺត្រូវបានអនុវត្តដោយវិធីសាស្ត្រជាច្រើន។ គ្រួសារភាគច្រើនបានចិញ្ចឹមសត្វដោយឱ្យស៊ីតាមលក្ខណៈធម្មជាតិ (ប្រព័ន្ធផ្ដល់ចំណីស្មៅ) ដែលមានចំនួន ១ ០១៣ ០០០ គ្រួសារ (៩៣,៥ភាគរយ) និងប្រមាណ ៧០ ០០០ គ្រួសារ (៦,៥ ភាគរយ) បានឱ្យស៊ីតាមលក្ខណៈធម្មជាតិរួមជាមួយនឹងការឱ្យចំណី ហើយមានតែចំនួន ២៦២ គ្រួសារប៉ុណ្ណោះ ដែលបានចិញ្ចឹមសត្វតាមលក្ខណៈទំនើបដោយឱ្យស៊ីតែចំណីសុទ្ធ។

ចំពោះគ្រួសារដែលចិញ្ចឹមបសុសត្វធំ (គោ ក្របី) ប្រមាណជា ៨៣ ភាគរយ ដែលគាត់បានចិញ្ចឹមសត្វចន្លោះពីចំនួន ២ ទៅ ៩ ក្បាល ហើយនិងមាន ៩ ភាគរយ គឺច្រើនជាង ឬស្មើ ១០ក្បាល ខណៈដែលមានតែ ៨ ភាគរយ ទៀតដែលមានការចិញ្ចឹមបសុសត្វធំត្រឹមតែចំនួន ១ ក្បាលប៉ុណ្ណោះ។

រូប៦.៣ ចំនួនគ្រួសារចិញ្ចឹមបសុសត្វធំនៅប្រទេសកម្ពុជា បែងចែកតាមចំនួនសត្វដែលបានចិញ្ចឹម (គិតជាពាន់)




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

នៅតំបន់វាលទំនាប គ្រួសារភាគច្រើន គឺចិញ្ចឹមបសុសត្វធំ (២៨៨ ៨០០ គ្រួសារ) ខណៈដែលនៅតំបន់បឹងទន្លេសាបគ្រួសារភាគច្រើន គឺចិញ្ចឹមបសុសត្វតូច (៤០ ០០០គ្រួសារ) ដូចជាជ្រូក ពពែ ជាដើម។

រូប៦.៤ ចំនួនគ្រួសារចិញ្ចឹមបសុសត្វតូចនៅប្រទេសកម្ពុជា បែងចែកតាមចំនួនសត្វដែលបានចិញ្ចឹម (គិតជាពាន់)




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

ចំនួនគ្រួសារមាន ៥៦ ភាគរយ នៃគ្រួសារចិញ្ចឹមបសុបក្សី ដែលបានចិញ្ចឹមមាន់ ឬ ទា ចន្លោះចំនួនពី ១ ទៅ ២៤ ក្បាល ហើយនិងមាន ៤៣ ភាគរយ មានចន្លោះចំនួនពី ២៥ ទៅ ៤៩៩ ក្បាល និងមានចំនួនតែ ០,៣ ភាគរយប៉ុណ្ណោះ ដែលមានចិញ្ចឹមបសុបក្សីចាប់ពីចំនួន ៥០០ ក្បាល ឡើងទៅ។

រូប៦.៥ ចំនួនគ្រួសារចិញ្ចឹមបសុបក្សីនៅប្រទេសកម្ពុជា បែងចែកតាមចំនួនសត្វដែលបានចិញ្ចឹម (គិតជាពាន់)




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

## ៦.២- គោ ក្របី និងជ្រូក

### *៦.២.១- បសុសត្វធំ*

បសុសត្វធំដែលចិញ្ចឹមនៅក្នុងគ្រួសារកសិកម្មច្រើនជាងគេ គឺគោ ហើយបន្ទាប់គឺក្របី។ ទោះយ៉ាងណាចំនួនគោមានច្រើនជាងក្របីប្រមាណជា១០ដង។ ចំណែកសត្វសេះ មានចំនួនតិចតួច បើប្រៀបធៀបទៅនឹងបសុសត្វធំផ្សេងទៀត ដោយមានចំនួន ៤ ៧០០ ក្បាល ដែលត្រូវបានចិញ្ចឹមមានចំនួន ៤៧១ គ្រួសារកាន់កាប់កសិកម្ម។ បសុសត្វធំភាគច្រើនត្រូវបានចិញ្ចឹមនៅតំបន់បឹងទន្លេសាបមានប្រមាណ ៣៩ ភាគរយ នៃបសុសត្វធំសរុបទូទាំងប្រទេស (១,៣លានក្បាល) បន្ទាប់មក គឺតំបន់វាលទំនាបមានប្រមាណ ១,២ លានក្បាល (៣៧ ភាគរយ), តំបន់ភ្នំនិងខ្ពង់រាបមានប្រមាណ ៦០០ ០០០ ក្បាល (១៨ ភាគរយ) និងតំបន់ឆ្នេរសមុទ្រមានប្រមាណ ២០០ ០០០ក្បាល (៦ ភាគរយ)។ សត្វគោប្រមាណ ៣៨ ភាគរយ (១ ១៥៩ ០០០ ក្បាល) ត្រូវបានចិញ្ចឹមនៅ តំបន់បឹងទន្លេសាប និងប្រមាណជា ៣៧ ភាគរយ (១ ១៣១ ០០០ ក្បាល) នៅតំបន់វាលទំនាប។




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

ចំពោះសត្វក្របីមានប្រមាណ ៤៥ ភាគរយ (១០៧ ០០០ ក្បាល) មាននៅតំបន់បឹងទន្លេសាប ៣២ ភាគរយ (៧៦ ០០០ ក្បាល) នៅតំបន់វាលទំនាប ១៨ ភាគរយ (៤៤ ០០០ ក្បាល) នៅតំបន់ភ្នំនិងខ្ពង់រាប និង ៥ ភាគរយ (១១ ០០០ ក្បាល) មានចិញ្ចឹមនៅតំបន់ឆ្នេរសមុទ្រ។

ក្នុងចំណោមគ្រួសារចិញ្ចឹមបសុសត្វធំទាំងអស់ គិតជាមធ្យមមានគោចំនួន ៤,៦ ក្បាល ក្នុងមួយគ្រួសារ ខណៈដែលក្របីមានជាមធ្យមចំនួន ៥,៧ ក្បាល ក្នុងមួយគ្រួសារ។

រូប៦.៧ ចំនួនសត្វក្របី បែងចែកតាមខេត្ត




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

ជាទូទៅ គេសង្កេតឃើញថាបសុសត្វដែលចិញ្ចឹមដោយគ្រួសារកសិកម្ម គឺជាពូជក្នុងស្រុកជាជាងពូជនាំចូល ឬពូជកូនកាត់។ ចំពោះគោមាន ៩៥ ភាគរយ ត្រូវបានឱ្យដឹងថា ជាពូជគោក្នុងស្រុក។ មានប្រមាណ ៤ភាគរយ ជាពូជកូនកាត់ និង ១ភាគរយជាពូជនាំចូល។ ដូចគ្នានេះដែរ សត្វជ្រូកប្រមាណជា ៩៣ ភាគរយ គឺជាពូជជ្រូកក្នុងស្រុក ៦ ភាគរយ ពូជកូនកាត់ និងមាន ១ ភាគរយ ពូជនាំចូល។

នៅក្នុងប្រទេសកម្ពុជា គោ និងក្របី ត្រូវបានចិញ្ចឹមសម្រាប់គោលបំណងចម្បងសំខាន់ៗចំនួនបួនដោយចាត់ចំណាត់ថ្នាក់តាមចំនួនសត្វ ដែលប្រើប្រាស់សម្រាប់គោលបំណងនីមួយៗមានដូចជា (ក) សម្រាប់លក់រស់ (ខ) បង្កាត់ពូជ (គ) យកសាច់ និង (ឃ) សម្រាប់ជាកម្លាំងអូសទាញ។




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

### *៦.២.២ បសុសត្វតូច (ជ្រូក)*

ក្រៅពីបសុសត្វធំ គ្រួសារមួយចំនួនក៏មានចិញ្ចឹមនូវបសុសត្វតូចផងដែរ ជាពិសេសគឺជ្រូក។ ចំនួនជ្រូកនៅទូទាំងប្រទេសមានចំនួន ៦៥៤ ០០០ ក្បាល ស្មើនឹង ៩៤ ភាគរយ នៃបសុសត្វតូចសរុបទាំងអស់។ នៅតំបន់បឹងទន្លេសាប គ្រួសារកសិកម្មភាគច្រើនបានចិញ្ចឹមជ្រូក (៣១៩ ០០០ គ្រួសារ) ហើយបន្ទាប់គឺតំបន់វាលទំនាប (១៩៣ ០០០ គ្រួសារ) តំបន់ភ្នំនិងខ្ពង់រាប (១០១ ០០០ គ្រួសារ) និងចុងក្រោយនៅតំបន់ឆ្នេរសមុទ្រដែលមានគ្រួសារចិញ្ចឹមជ្រូកតិចតួចចំនួន ៤១ ០០០ គ្រួសារ។ ជ្រូកមានប្រមាណ ៩៣ ភាគរយ គឺជាពូជជ្រូកក្នុងស្រុក មាន ៦ ភាគរយ ជាពូជកូនកាត់ និងជិត១ភាគរយជាពូជនាំចូលពីក្រៅប្រទេស។ ដោយឡែកគ្រួសារកសិកម្មដែលចិញ្ចឹមជ្រូក គឺមានជ្រូកជាមធ្យមចំនួន ៧,១ ក្បាល ក្នុងមួយគ្រួសារកាន់កាប់កសិកម្ម។

រូបទី៦.៩ ចំនួនសត្វជ្រូក បែងចែកតាមខេត្ត




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

ជ្រូកភាគច្រើន ត្រូវបានចិញ្ចឹមទុកសម្រាប់លក់រស់ (មានប្រមាណ ៥៦៩ ៥០០ ក្បាល)។ ក្រៅពីនេះ ជ្រូកមួយចំនួនតូចត្រូវបានចិញ្ចឹមទុកសម្រាប់បង្កាត់ពូជ (ប្រមាណ ៥៥ ៤០០ក្បាល) ឬសម្លាប់យកសាច់ដើម្បីលក់ (ប្រមាណ ២៦ ៤០០ក្បាល)។

រូបទី៦.១០ គោលបំណងចម្បងនៃការចិញ្ចឹមជ្រូក នៅប្រទេសកម្ពុជា




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

### ៦.២.៣ បម្រែបម្រួលបសុសត្វ

បម្រែបម្រួលបសុសត្វ គឺជាសត្វដែលត្រូវបានលក់ ឬ សត្វដែលត្រូវបានប្រែប្រួលក្នុងសកម្មភាពផ្សេងៗទៀតរួមមានកន្លែងសម្លាប់សត្វនៅទីសត្តឃាត កន្លែងអ្នកកាប់សាច់លក់ ឬ រោងចក្រ វេចខ្ចប់សាច់សត្វ ឬ សត្វឱ្យជាអំណោយ សត្វដោះដូរជាមួយសេវាកម្មរួមទាំង សត្វជាអំណោយក្នុងពិធីបុណ្យ និងសហគមន៍ផ្សេងៗទៀត។

បម្រែបម្រួលគោសម្រាប់រយៈ១២ខែមុនពេលធ្វើជំរឿនមានចំនួន ៤៩២ ៣០០ ក្បាល ក្នុងនោះគោមានប្រមាណ ៧៣ ភាគរយ សម្រាប់លក់រស់។ ក្រៅពីគោត្រូវបានលក់រស់មានគោប្រមាណ ៨ភាគរយ ដែលបានងាប់ និងមាន៥ ភាគរយ ត្រូវបានសម្លាប់យកសាច់លក់ ៤ ភាគរយត្រូវបានសម្លាប់យកសាច់លក់ប្រើប្រាស់ក្នុងគ្រួសារ អត្រា៣ ភាគរយ សម្រាប់បាត់បង់ ២ ភាគរយ សម្រាប់ធ្វើជាអំណោយ ឬវិភាគទាន និងគោចំនួន និងមានអត្រា ៦ ភាគរយ ផ្សេងទៀត ត្រូវបានប្រែប្រួលតាមរូបភាពផ្សេងទៀត ដូចជាសងបំណុលគេ។ល។

ក្របីចំនួន ៣៣ ០០០ ក្បាល ត្រូវបានប្រែប្រួលក្នុងរយៈពេល១២ខែដូចខាងលើដែរ ក្នុងនោះក្របីមាន ៦៨ ភាគរយ ត្រូវបានលក់ទាំងរស់ និងមាន ១០ ភាគរយ ដែលងាប់ដោយជំងឺ។ ការបម្រែបម្រួលជ្រូកក្នុងតួលេខចំនួន ៥៦២ ២០០ ក្បាល នៅមានអត្រាខ្ពស់បំផុតស្មើនឹង ៨៤ ភាគរយ សម្រាប់លក់រស់។ អត្រាបន្ទាប់មាន ៧ ភាគរយ ដែលងាប់ដោយសារជំងឺ និងមាន ៥ ភាគរយ ដែលត្រូវបានសម្លាប់យកសាច់សម្រាប់លក់។

រូប៦.១១ បម្រែបម្រួលបសុសត្វនៅប្រទេសកម្ពុជា




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

## ៦.៣- សត្វមាន់ និង សត្វទា

នៅក្នុងប្រទេសកម្ពុជាមានគ្រួសារចំនួនប្រមាណ ៧២៦ ៨០០គ្រួសារ ដែលបានចិញ្ចឹមបសុបក្សី។ មាន់ និងទា គឺជាប្រភពប្រូតេអ៊ីនដ៏សំខាន់មួយត្រូវបានចិញ្ចឹមដោយគ្រួសារកសិកម្ម មាន់ចំនួនប្រមាណ ២២ លានក្បាល និងទាចំនួនប្រមាណ ៧,៥ លានក្បាល ត្រូវបានរាយការណ៍ថាបានចិញ្ចឹមនាថ្ងៃធ្វើជំរឿនកសិកម្ម។ ខេត្តតាកែវ គឺជាខេត្តនាំមុខគេក្នុងចំណោមខេត្តទាំងអស់ ទូទាំងប្រទេសដែលមានមាន់ចំនួន ២,៦ លានក្បាល ដែលបានចិញ្ចឹមនៅក្នុងគ្រួសារកាន់កាប់កសិកម្ម។ ខេត្តតាកែវជាខេត្តដែលឈរលំដាប់នាំមុខគេ ដែលមានសត្វទាប្រមាណ ១,៦ លានក្បាល។ ក្ងាន មាន់ទួកគី និងក្រួច ក៏ត្រូវបានចិញ្ចឹមផងដែរនៅក្នុងប្រទេសកម្ពុជា ក៏ប៉ុន្តែការចិញ្ចឹមសត្វទាំងនោះនៅមានកម្រិតតិចតួចនៅឡើយ។

រូប៦.១២ ចំនួនគ្រួសារកសិកម្មដែលចិញ្ចឹមបសុបក្សី បែងចែកតាមប្រភេទបសុបក្សី នៅប្រទេសកម្ពុជា




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

**រូប៦.១៣ ចំនួនការកើតនៃប្រភេទបសុបក្សី នៅប្រទេសកម្ពុជា**




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

## *៦.៣.១- គោលបំណងចម្បងក្នុងការចិញ្ចឹមបសុបក្សី*

គោលបំណងក្នុងការចិញ្ចឹមមាន់ និងទា គឺពិតជាមានការខុសគ្នាយ៉ាងខ្លាំង។ គ្រួសារកសិកម្មភាគច្រើនបំផុត ដែលបានចិញ្ចឹមមាន់មានចំនួនប្រមាណ១១,៩លានក្បាល បើប្រៀបធៀបទៅនិងការចិញ្ចឹមយកសាច់សម្រាប់លក់មានចំនួន ៧,៧ លានក្បាល និងមានចំនួន ១,៤ លានក្បាល សម្រាប់ទុកបង្កាត់ពូជ ឬ ចិញ្ចឹមមាន់ប្រមាណ ១,៣ លានក្បាល សម្រាប់យកស៊ុត។ ម្យ៉ាងវិញទៀត ការចិញ្ចឹមទាសម្រាប់យកស៊ុតមានចំនួន ៣,៨ លានក្បាល ដែលជាប់លំដាប់ខ្ពស់ជាងគេ បន្ទាប់មកចិញ្ចឹមយកសាច់មានចំនួនប្រមាណ ២,២ លានក្បាល និងសម្រាប់លក់ទាំងរស់មាន ១,៤ លានក្បាល និងការបង្កាត់ពូជមានចំនួន ០,០៩ លានក្បាល។

រូប៦.១៤ គោលបំណងចម្បងនៃការចិញ្ចឹមមាន់និងទា នៅប្រទេសកម្ពុជា




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

### ៦.៣.២- បម្រែបម្រួលបសុបក្សី

មាន់ចំនួនប្រមាណ ១២១ លានក្បាល ដែលបានបម្រែបម្រួលនៅក្នុងរយៈពេល១២ខែកន្លងមក ក្នុងនោះមានមាន់ ១៥ ភាគរយ ត្រូវបានលក់ទៅកាន់ទីផ្សារ និងកន្លែងផ្សេងទៀត។ មាន់មានប្រមាណ ៨ ភាគរយ ដែលត្រូវបានសម្លាប់យកសាច់សម្រាប់លក់ មានប្រមាណ ១១ ភាគរយ ដែលត្រូវបានសម្លាប់យកសាច់សម្រាប់ប្រើប្រាស់ក្នុងគ្រួសារ មានចំណែក ១៦ ភាគរយ ដែលបានបាត់បង់ និងមានអត្រា ២០ ភាគរយ ដែលបានងាប់ដោយសារជំងឺ ចំណែកនៅសល់ប្រមាណ ៣១ ភាគរយ ដែលត្រូវបានធ្វើជាអំណោយ ឬរិភាគទាន។

ទាមានចំនួនប្រមាណ ២៦ លានក្បាល ដែលត្រូវបានបម្រែបម្រួលក្នុងពេលជាមួយគ្នាដែរ។ ទាមានប្រមាណ ៣៨ ភាគរយ ដែលបានលក់ទាំងរស់។ ទាមានប្រមាណ ២៩ ភាគរយ ដែលបានងាប់ដោយសារជំងឺ និងមាន ២២ ភាគរយ ដែលត្រូវបានសម្លាប់យកសាច់សម្រាប់ប្រើប្រាស់ក្នុងគ្រួសារ និងចំណែកអត្រានៅសល់មានប្រមាណ ១១ ភាគរយ ត្រូវបានធ្វើជាអំណោយ ឬរិភាគទានផ្សេងៗ។

រូប៦.១៥ បម្រែបម្រួលបសុបក្សីនៅប្រទេសកម្ពុជា




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

### *៦.៣.៣- បសុបក្សីងាប់ដោយសារជំងឺ*

ជាទូទៅការងាប់របស់បសុបក្សី ត្រូវបានរាយការណ៍នៅក្នុងតំបន់បឹងទន្លេសាបសម្រាប់ទាំងមាន់ និងទា។ តំបន់ឆ្នេរសមុទ្រមានងាប់សត្វទាតិចតួច ទោះជាយ៉ាងណាក៏ដោយ នៅខេត្តកំពត បានរាយការណ៍អំពីចំនួនមាន់ងាប់ច្រើនមានចំនួន ១១,៧ លានក្បាល នៅក្នុងខេត្តនេះដែលធ្វើឱ្យវាក្លាយជាតំបន់នៃការងាប់មាន់ច្រើនជាងគេនៅទូទាំងប្រទេស ស្មើនឹង ៩៩ ភាគរយនៃការងាប់មាន់នៅក្នុងតំបន់ឆ្នេរសមុទ្រ។

**រូប៦.១៦ ចំនួនបសុបក្សីងាប់ បែងចែកតាមតំបន់ និងតាមប្រភេទបសុបក្សី**




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

# ជំពូកទី៧

# សកម្មភាពសេដ្ឋកិច្ចបន្ថែមនៃគ្រួសារកសិកម្ម

គ្រួសារកាន់កាប់កសិកម្មនៅក្នុងប្រទេសកម្ពុជា តែងមានសកម្មភាពសេដ្ឋកិច្ចរបស់ខ្លួនបន្ថែមរបស់គេ ដូចជាសកម្មភាពនានាដែលទាក់ទងនឹងអនុផលព្រៃឈើ សិប្បកម្ម ជំនួញខ្នាតតូច និងធ្វើការនៅក្នុងវិស័យកសិកម្មនៅខាងក្រៅនៃគ្រួសារកាន់កាប់កសិកម្មរបស់គេ និងការងារនៅវិស័យសេវាកម្ម។

## ៧.១- សកម្មភាពទាក់ទងនឹងព្រៃឈើ

យោងតាមជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣ មានគ្រួសារកាន់កាប់កសិកម្មជាច្រើនដែលបានចូលរួមធ្វើសកម្មភាពទាក់ទងនឹងព្រៃឈើ ដូចជាការរកអុស ឬកាប់ឫស្សី ដុតធ្យូង និងកាប់ឈើក្នុងព្រៃ ( ឈើក្រអូប និងឈើផ្សេងទៀត)។

ក្នុងចំណោមគ្រួសារកសិកម្មទាំងអស់ ដែលបានចូលរួមធ្វើសកម្មភាពទាក់ទងនឹងព្រៃឈើ (៣៦១ ៣១៣ គ្រួសារ) ការរកអុស និងកាប់ឫស្សីមានគ្រួសារកសិកម្មចំនួនច្រើនជាងគេ គឺមានប្រមាណ ៣៣០ ០០០ គ្រួសារកសិកម្ម នៅខណៈដែលការស្វែងរកអាហារ ឬបន្លែ និងផ្លែឈើព្រៃផ្សេងទៀតមានចំនួនច្រើននៅលំដាប់បន្ទាប់ គឺមានប្រមាណ ១៣៩ ០០០ គ្រួសារ។ គ្រួសារកសិកម្មតិចតួចដែលបានបរបាញ់សត្វ និងស្វែងរកជ័រឈើ នៅខណៈដែលសកម្មភាពទាំងនេះត្រូវបានហាមឃាត់ដោយច្បាប់។

រូប៧.១ ចំនួនគ្រួសារកសិកម្មដែលបានចូលរួមធ្វើសកម្មភាពទាក់ទងនឹងព្រៃឈើ តាមប្រភេទនៃសកម្មភាព នៅប្រទេសកម្ពុជា




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

ជាទូទៅការរកអុស ឬកាប់ឬស្សីភាគច្រើននៅតំបន់ភ្នំនិងខ្ពង់រាប ដូចជាខេត្តព្រះវិហារ កំពង់ស្ពឺ និងរតនគិរី ដែលត្រូវបានបង្ហាញថាមានគ្រួសារកសិកម្មលើសពី ២០ ០០០ គ្រួសារ ដែលបានធ្វើសកម្មភាពនេះសម្រាប់ខេត្តនីមួយៗ។ ករណីលើកលែងក្នុងតំបន់បឹងទន្លេសាប គឺនៅក្នុងខេត្តបន្ទាយមានជ័យ ដែលការរកអុស ឬកាប់ឬស្សីនេះមានចំនួនច្រើនបំផុតជាមួយនឹងគ្រួសារកសិកម្មជិត ៣៦ ០០០ គ្រួសារ។

គ្រួសារកសិកម្មបានរាយការណ៍ថាមានដីព្រៃ និង/ឬ ព្រៃឈើផ្សេងៗ ដែលជាផ្នែកនៃកសិដ្ឋានមានតិចតួចមានត្រឹមតែ ០,៥ ភាគរយ (៩ ៥៥៩ គ្រួសារ)។ ស្ទើរតែពាក់កណ្តាលនៃគ្រួសារដែលមានដីព្រៃ និង/ឬ ព្រៃឈើផ្សេងៗ (ប្រមាណ ៤ ៨០០ គ្រួសារ) គឺស្ថិតនៅតំបន់ភ្នំនិងខ្ពង់រាប។

## ៧.២- សកម្មភាពសេដ្ឋកិច្ចផ្សេងទៀតរបស់សមាជិកគ្រួសារកសិកម្ម

សមាជិកគ្រួសារកសិកម្មមានប្រមាណ ៦៥ ភាគរយ នៃសមាជិកគ្រួសារកសិកម្មទាំងអស់ដែលមានអាយុចាប់ពី ៥ ឆ្នាំឡើងទៅ បានចូលរួមក្នុងសកម្មភាពកសិកម្មនៅក្នុងគ្រួសារកាន់កាប់កសិកម្មរបស់គេ សម្រាប់នៅក្នុងរយៈពេល ១២ ខែកន្លងមកនេះ។ សមាជិកគ្រួសារនេះមានប្រមាណ ៣ ភាគរយ ជាបុរសខ្ពស់ជាងស្ត្រី។ សម្រាប់គ្រួសារជាបុរស (៦៧ ភាគរយ) និងស្ត្រី (៦៤ ភាគរយ) ។ សមាជិកគ្រួសារមានប្រមាណ ២២ ភាគរយ នៃសមាជិកគ្រួសារកសិកម្ម ដែលមានអាយុលើសពី ៥ ឆ្នាំ ដែលបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចក្រៅពីវិស័យកសិកម្ម។ ជាថ្មីម្តងទៀត សមាជិកគ្រួសារជាបុរសមានអត្រាខ្ពស់ ៣ ភាគរយ ក្នុងចំណោមបុរស (២៤ ភាគរយ) គឺខ្ពស់ជាងសមាជិកជាស្ត្រី (មានអត្រា ២១ ភាគរយ) ។

# ជំពូកទី៨
# គ្រួសារកសិកម្ម និង ចំនួនប្រជាជន

## ៨.១- គ្រួសារកសិកម្ម

នៅក្នុងប្រទេសកម្ពុជាមានចំនួនគ្រួសារសរុប ៣,៧៤ លានគ្រួសារ ផ្អែកតាមលទ្ធផលអង្កេតចន្លោះជំរឿនប្រជាជនកម្ពុជានៅឆ្នាំ២០២៤។ ជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣ បានធ្វើការចុះបញ្ជីគ្រួសារចំនួន ៣,៤១ លានគ្រួសារ ដោយបានប្រើប្រាស់កម្រងសំណួរទម្រង់២ ដើម្បីកំណត់អត្តសញ្ញាណគ្រួសារកាន់កាប់កសិកម្ម ក្នុងនោះមានគ្រួសារកាន់កាប់កសិកម្មចំនួន ១,៨៥ លានគ្រួសារ។ ភាពខុសគ្នានេះដោយសារតែការចុះបញ្ជីគ្រួសារនៃជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣ មិនបានរាប់បញ្ចូលតំបន់ទីប្រជុំជន នៃរាជធានីភ្នំពេញ ដែលត្រូវបានកំណត់ថាមានសកម្មភាពកសិកម្មតិចតួច ឬ គ្មាន។ គ្រួសារដែលត្រូវបានរាប់ចុះបញ្ជីគ្រួសារបានរាយការណ៍ថាមានចំនួនប្រជាជនប្រមាណ ៧,៣ លាននាក់ (ប្រមាណ ៤២ ភាគរយ) នៃចំនួនប្រជាជនសរុបនៅទូទាំងប្រទេសក្នុង ឆ្នាំ២០២៣។

ក្នុងចំណោមគ្រួសារកាន់កាប់កសិកម្មសរុបមានប្រមាណ ៥៤ ភាគរយ នៃគ្រួសារសរុបដែលត្រូវបានរាប់ចុះបញ្ជីនៃជំរឿនកសិកម្មឆ្នាំ២០២៣។ គ្រួសារទាំងនេះបានរាយការណ៍ថាបានចូលរួមក្នុងការដាំដុះដំណាំ និង/ឬ ការចិញ្ចឹមបសុសត្វ និងបសុបក្សីនៅក្នុងវិស័យកសិកម្មរបស់គេ។ តំបន់វាលទំនាបមានចំនួន ៤០ ភាគរយ នៃគ្រួសាររស់នៅបានប្រកបរបរកសិកម្ម ហើយនៅតំបន់បឹងទន្លេសាបមានប្រមាណ ៣៨ ភាគរយ តំបន់ឆ្នេរសមុទ្រមានប្រមាណ ៦ ភាគរយ និងតំបន់ខ្ពង់រាបនិងភ្នំមានប្រមាណ ១៦ ភាគរយ។

**រូប៨.១ ចំនួននិងភាគរយនៃសមាជិកគ្រួសារកាន់កាប់កសិកម្ម បែងចែកតាមតំបន់**




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

ខេត្តព្រៃវែងមានចំនួនប្រជាជនរស់នៅដែលប្រកបរបរកសិកម្មច្រើនជាងគេ ខណៈខេត្តកែបមានចំនួនអ្នកធ្វើកសិកម្មតិចជាងគេ។ ខេត្តចំនួន ៩ មានប្រជាជនធ្វើសកម្មភាពកសិកម្មច្រើនជាងគេគឺ ខេត្តព្រៃវែង តាកែវ សៀមរាប កំពង់ស្ពឺ បាត់ដំបង បន្ទាយមានជ័យ កំពង់ចាម ស្វាយរៀង និងត្បូងឃ្មុំ ដែលខេត្តនីមួយៗមានប្រជាជនចូលរួមធ្វើកសិកម្មជាង ៤០០ ០០០ នាក់នៅក្នុងគ្រួសារកាន់កាប់កសិកម្ម។

ចំនួនបុរសស្ទើរតែស្មើគ្នា (៤៩,៦ ភាគរយ) និងស្ត្រី (៥០,៤ ភាគរយ) ជាហេតុនាំឱ្យអនុបាតអត្រាភេទស្មើ ៩៨,៤ ក្នុងចំនួនប្រជាជនគ្រួសារកសិកម្ម។ ទោះបីជាចំនួនមេគ្រួសារជាបុរសមានលើសពីមេគ្រួសារជាស្ត្រីក៏ដោយ។ សម្រាប់មេគ្រួសារជាបុរស សមាជិកបុរសដែលប្រកបរបរកសិកម្មមានប្រហែល ៥១ ភាគរយ និងសមាជិកស្ត្រីមានប្រហែល ៤៩ ភាគរយបានចូលរួមក្នុងសកម្មភាពវិស័យកសិកម្ម។ ម្យ៉ាងវិញទៀត គ្រួសារដែលមានមេគ្រួសារជាស្ត្រី មានសមាជិកស្ត្រីច្រើន (៦០ ភាគរយ) ជាងសមាជិកបុរស (៤០ ភាគរយ)។

រូប៨.២ ចំនួនសមាជិកគ្រួសារកាន់កាប់កសិកម្ម បែងចែកតាមខេត្ត
(ខេត្ត១០ដែលមានចំនួនច្រើនជាងគេ)




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

## ៨.២- ក្រុមអាយុប្រជាជន

ប្រជានជនប្រមាណ ១,៣៩ លាននាក់ មានអាយុនៅចន្លោះចាប់ពី ១០ ទៅ ១៩ ឆ្នាំគឺជាក្រុមអាយុដែលមានច្រើនជាងគេបំផុត នៃចំនួនប្រជាជនទាំងអស់ ដែលជាគ្រួសារកសិកម្ម។ បន្ទាប់មកមានក្រុមអាយុចាប់ពី ៣០ - ៣៩ ឆ្នាំ (១,២៣ លាននាក់) និងអាយុចាប់ពី ២០ - ២៩ ឆ្នាំ (១,១៩ លាននាក់)។ ចំនួនស្ត្រីមានច្រើនជាងបុរសក្នុងក្រុមអាយុនីមួយៗ ចាប់ពី ២០ - ២៩ ដល់ ៦០ ឆ្នាំឡើងទៅ។ ទោះបីជាយ៉ាងណាក៏ដោយនៅក្នុងក្រុមអាយុចាប់ពី ១០ - ១៩ ឆ្នាំ និងក្រុមអាយុតិចជាង ១០ ឆ្នាំមានបុរសច្រើនជាងស្ត្រី។ សមភាពយេនឌ័រក្នុងក្រុមអាយុនីមួយៗ គឺនៅអាយុចាប់ពី ៦០ ឆ្នាំឡើងទៅ មានស្ត្រីចំនួន ៥៣,៩ ភាគរយ នៃចំនួនប្រជាជនតាមក្រុមអាយុ។ នៅក្នុងក្រុមអាយុក្មេងបំផុតតិចជាងពី ១០ ឆ្នាំបុរសមានចំនួន ៥១,៥ ភាគរយនៃចំនួនប្រជាជនតាមក្រុមអាយុ។

សមាជិកគ្រួសារកសិកម្ម ដែលបានរាយកាណ៍មានអាយុជាមធ្យមគឺ ៣១,៨ ឆ្នាំ។ ដោយឡែក នៅរាជធានីភ្នំពេញបានរាយការណ៍ថា អាយុជាមធ្យមខ្ពស់បំផុត គឺអាយុ ៣៥ ឆ្នាំ។ ចំណែកឯនៅខេត្តរតនគិរី និងខេត្តមណ្ឌលគិរី អាយុជាមធ្យមទាបបំផុតនៅក្នុងគ្រួសារកសិកម្មបានរាយការណ៍គឺ ២៦,៤ ឆ្នាំ និង ២៦,៥ ឆ្នាំរៀងៗខ្លួន។

រូប៨.៣ ចំនួនប្រជាជនតាមភេទនិងក្រុមអាយុក្នុងគ្រួសារកសិកម្ម




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

## ៨.៣- អត្រាអ្នកនៅក្នុងបន្ទុកគ្រួសារកសិកម្ម

សមាជិកគ្រួសារមាន ៦៧ ភាគរយ នៃសមាជិកគ្រួសារទាំងមេគ្រួសារជាបុរស និងមេគ្រួសារជាស្ត្រី បានចូលរួមធ្វើសកម្មភាពសេដ្ឋកិច្ចការងារកសិកម្មគ្រួសារ (ឧទាហរណ៍៖ អាយុពី ១៥ ដល់ ៥៩ ឆ្នាំ)។ អនុបាតនៃអ្នករស់នៅក្នុងបន្ទុកគ្រួសារកសិកម្ម គឺមានអាយុតិចជាង ១៥ ឆ្នាំ និងមានអាយុ ៦០ ឆ្នាំឡើង ត្រូវបានគណនាស្មើនឹង ៣៣ ភាគរយ នៃចំនួនសមាជិកគ្រួសារកសិកម្មទាំងអស់ មានន័យថាអនុបាតនៃអ្នករស់នៅក្នុងបន្ទុកទាំងអស់គិតជាមធ្យមមានចំនួន ០,៤៩។ អនុបាតនៃអ្នករស់នៅក្នុងបន្ទុកនេះត្រូវបានគណនាដោយយកផលបូកនៃចំនួនមនុស្សមានក្រុមអាយុតិចជាង១៥ ឆ្នាំ និងក្រុមអាយុពី៦០ ឆ្នាំឡើង ចែកនឹងចំនួនមនុស្សសរុបដែលមានសកម្មភាពសេដ្ឋកិច្ចស្ថិតក្នុងក្រុមអាយុចន្លោះពី១៥ ទៅ ៥៩ ឆ្នាំ។ អនុបាតនៃអ្នករស់នៅក្នុងបន្ទុក គឺមានអត្រាខ្ពស់នៅក្នុងតំបន់បឹងទន្លេសាប តំបន់ភ្នំនិងខ្ពង់រាប មានអត្រា ០,៥ និងនៅតំបន់ឆ្នេរសមុទ្រមានអត្រាទាប ០,៤៣។ ផ្ទុយមកវិញ អនុបាតនៃមនុស្សចាស់នៅក្នុងបន្ទុកគ្រួសារមានអត្រាខ្ពស់នៅតំបន់វាលទំនាប និងមានអត្រាទាបនៅតំបន់បឹងទន្លេសាប។

តារាងទី៨.១ អត្រាអ្នកនៅក្នុងបន្ទុកគ្រួសារកាន់កាប់កសិកម្មតាមតំបន់

| តំបន់/ចំនួននៃក្រុមអាយុ | ចំនួនគ្រួសារសរុប | | |
|---|---|---|---|
| | ចំនួន | អនុបាតនៃអ្នករស់នៅក្នុងបន្ទុក* | អនុបាតនៃមនុស្សចាស់រស់នៅក្នុងបន្ទុក** |
| ប្រទេសកម្ពុជា | ៧ ២៥៦ ១១៤ | 0,៤៩ | 0,១៥ |
| តំបន់វាលទំនាប | ២ ៨៨៧ ៦៨0 | 0,៤៨ | 0,១៧ |
| តំបន់បឹងទន្លេសាប | ២ ៧៣៤ 0៩១ | 0,៥0 | 0,១៤ |
| តំបន់ឆ្នេរសមុទ្រ | ៤៥៨ ៥១៤ | 0,៤៣ | 0,១៥ |
| តំបន់ភ្នំនិងខ្ពង់រាប | ១ ១៧៥ ៨២៩ | 0,៥0 | 0,១១ |

** អត្រាអ្នកនៅក្នុងបន្ទុក គឺជាអត្រានៃចំនួនមនុស្សដែលមានអាយុតិចជាង ១៥ឆ្នាំ និងអាយុច្រើនជាង ៥៩ឆ្នាំ ធៀបទៅនឹងចំនួនមនុស្សអាយុពី ១៥ ទៅ ៥៩ឆ្នាំ។*

*** អត្រាមនុស្សចាស់នៅក្នុងបន្ទុក គឺជាអត្រានៃចំនួនមនុស្សដែលមានអាយុច្រើនជាង៥៩ឆ្នាំ ធៀបទៅនឹងចំនួនមនុស្សអាយុពី ១៥ ទៅ ៥៩ឆ្នាំ។*

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២0២៣*

## ៨.៤- ទំនាក់ទំនងមេគ្រួសារ

នៅក្នុងជំរឿនកសិកម្មកម្ពុជា ឆ្នាំ២0២៣បានរកឃើញ ថាមានចំនួន ១ ៨១៧ ៥៨៤ គ្រួសារ ដែលមានប្រជាជនចំនួន ៧ ២៥៦ ១១៤ នាក់ ដែលបានកំពុងធ្វើសកម្មភាពកសិកម្មក្នុងគ្រួសារកាន់កាប់កសិកម្មនៅទូទាំងប្រទេសកម្ពុជា។ ប្រជាជនមានប្រមាណ ២៥,៥ ភាគរយ (១ ៨៥0 000នាក់) គឺជាមេគ្រួសារមានប្រមាណ ២១,២ ភាគរយ (ប្រជាជន ១ ៥៤២ 000នាក់) ជាប្តី/ប្រពន្ធ ប្រមាណ ៤២,២ ភាគរយ (ប្រជាជន ៣ 0៦៣ 000នាក់) ជាកូនបង្កើតមានប្រមាណ ៤,៩ ភាគរយ (ប្រជាជន ៣៥២ 000 នាក់) ជាចៅ ប្រមាណ ២,៤ ភាគរយ (១៧៧ 000 នាក់) ជាកូនប្រសារ និងមានប្រមាណ ២,៣ ភាគរយ (១៧0 000 នាក់) គឺជាសាច់ញាតិផ្សេងទៀត ខណៈដែលបងប្អូនបង្កើត ក្មួយ បងប្អូនថ្លៃ ... មានចំនួនតិចតួចប៉ុណ្ណោះដែលបានរាយការណ៍ក្នុងទំនាក់ទំនង ជាមួយមេគ្រួសារ។

រូប៨.៤ ទំនាក់ទំនងជាមួយមេគ្រួសារនៃសមាជិកគ្រួសារកសិកម្ម




** "ផ្សេងៗ" រួមមានបងប្អូនថ្លៃ កូនចុង កូនចិញ្ចឹម ឪពុកម្ដាយក្មេក អ្នកបម្រើ និងអ្នកមិនជាប់សាច់ញាតិ។*

*ប្រភព: វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣*

## ៨.៥- ការអប់រំ

ប្រជាជនមានប្រមាណ ២៦,៧ ភាគរយ នៃប្រជាជនសរុបដែលមានអាយុ៥ឆ្នាំឡើងទៅនៅក្នុងគ្រួសារកសិកម្មដែលបានសិក្សាចប់ត្រឹមថ្នាក់ទី៥ និងមានអត្រា ៥,៥ ភាគរយ តែប៉ុណ្ណោះ ដែលបានរាយការណ៍ថាបានបញ្ចប់សិក្សាត្រឹមថ្នាក់ទី១២។ អត្រាត្រឹមតែ ១,៤ ភាគរយប៉ុណ្ណោះ ដែលបានរាយការណ៍ថាបានទទួលវិញ្ញាបនបត្រមធ្យមសិក្សាបឋមភូមិ និង ១,៧ ភាគរយបានរាយការណ៍ថាទទួលបានវិញ្ញាបនបត្រមធ្យមសិក្សាទុតិយភូមិ។ ស្រដៀងគ្នានេះដែរ ចំនួនប្រជាជនបានរាយការណ៍ថាទទួលបានការអប់រំត្រឹមកម្រិតបរិញ្ញាបត្រ ដែលមានអត្រាទាបគឺ ១,២ ភាគរយ តែប៉ុណ្ណោះ។

ជាទូទៅ សមាជិកមួយចំនួនតូចនៃគ្រួសារកសិកម្ម ដែលបានបញ្ចប់ការអប់រំកម្រិតខ្ពស់ និងការចូលរួមគឺចំនួនស្ត្រីមានកម្រិតទាបជាងបុរស។ ឧទាហរណ៍ ២,៦ ភាគរយ នៃស្ត្រីបានបញ្ចប់កម្រិតសិក្សាថ្នាក់ទី១២ ប្រៀបធៀបទៅនឹងបុរសមាន ២,៩ ភាគរយ ០,៣ ភាគរយនៃស្ត្រីបានសិក្សាដល់ថ្នាក់មហាវិទ្យាល័យ ឬសាកលវិទ្យាល័យ ខណៈដែល ០,៤ ភាគរយ នៃស្ត្រីបានសិក្សាត្រឹមកម្រិតបឋមភូមិ បើធៀបនឹងបុរសមានអត្រា ០,៨ ភាគរយ។

# ៨.៦- ស្ថានភាពអាពាហ៍ពិពាហ៍

សមាជិកគ្រួសារមាន ៦៤ ភាគរយ នៃសមាជិកគ្រួសារកាន់កាប់កសិកម្ម ដែលបានរៀបការ នៅខណៈដែលមានអត្រា ៦ ភាគរយ ជាស្ត្រីមេម៉ាយ អត្រា១ ភាគរយដែលបានលែងលះ ឬរស់នៅផ្សេងៗគ្នា និងាមនអត្រា ២៩ ភាគរយ សម្រាប់មិនទាន់រៀបការនិងមិនបានរស់នៅជាមួយដៃគូ។

មេគ្រួសារជាស្ត្រីភាគច្រើនដែលរស់នៅដោយមិនបានរៀបការ ឬរស់នៅជាមួយដៃគូមានអត្រា ៣២ ភាគរយ បើប្រៀបធៀបទៅនឹងបុរសជាមេគ្រួសារដែលមិនបានរៀបការ ឬមិនបានរស់នៅជាមួយដៃគូមានអត្រា ២៧ ភាគរយ។ មេគ្រួសារជាស្ត្រីជាច្រើនដែលបានលែងលះ មានអត្រា ៩ ភាគរយ បើប្រៀបធៀបទៅនឹងបុរសជាមេគ្រួសារមានអត្រា ៣ ភាគរយ និងជាស្ត្រីជាមេគ្រួសារជាច្រើនទៀត ត្រូវបានលែងលះ ឬរស់នៅផ្សេងគ្នា (មានអត្រា ១ ភាគរយ បើប្រៀបធៀបទៅនឹងបុរសជាមេគ្រួសារមានអត្រា ០,៥ ភាគរយ)។

រូប៨.៥ ស្ថានភាពអាពាហ៍ពិពាហ៍របស់សមាជិកគ្រួសារកសិកម្ម
(អាយុចាប់ពី១៣ឆ្នាំឡើង)




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣*

# ឧបសម្ព័ន្ធ

# វិសាលភាព វិធីសាស្ត្រ និងគុណភាពនៃទិន្នន័យ

## ៩.១- សេចក្តីផ្តើម

ជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា ត្រូវបានធ្វើឡើងនៅឆ្នាំ២០២៣ ដើម្បីប្រមូល និងចងក្រងព័ត៌មានស្តីពីការដាំដុះដំណាំ ចិញ្ចឹមបសុសត្វ និងបសុបក្សី។ ទិន្នន័យដែលប្រមូលបានពីជំរឿននេះ នឹងត្រូវប្រើប្រាស់ក្នុងការរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធី ដើម្បីការអភិវឌ្ឍ និងការកែលម្អវិស័យកសិកម្មនៅក្នុងរាជរដ្ឋាភិបាលកម្ពុជា។ ជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា ត្រូវបានធ្វើឡើងជាលើកទី២ បន្ទាប់ពីជំរឿនកសិកម្មនៅក្នុងឆ្នាំ២០១៣។

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ សហការជាមួយនិងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការធ្វើជំរឿនកសិកម្មនៅឆ្នាំ២០២៣។ វិទ្យាស្ថានជាតិស្ថិតិមានភារកិច្ចដឹកនាំអនុវត្តធ្វើជំរឿនកសិកម្ម ចំណែកឯក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាអ្នកប្រើប្រាស់ទិន្នន័យដែលបានពីជំរឿនកសិកម្មនេះ។

ជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ ត្រូវបានធ្វើឡើងដោយផ្អែកតាមច្បាប់ស្តីពីស្ថិតិ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ដែលបានចែងអំពីការរក្សាភាពសម្ងាត់នៃទិន្នន័យដោយយោងតាមមាត្រា២២។ រាល់ព័ត៌មានទាំងឡាយដែលបានប្រមូលបានពីបុគ្គល គ្រួសារកាន់កាប់កសិកម្ម គ្រឹះស្ថានសហគ្រាសនៅក្នុងជំរឿនកសិកម្មត្រូវតែរក្សាជាសម្ងាត់បំផុត និងមិនត្រូវបានបែងចែកទៅឱ្យបុគ្គលណាម្នាក់ឡើយ លើកលែងតែមន្ត្រីវិទ្យាស្ថានជាតិស្ថិតិ និងមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលទទួលការអនុញ្ញាតអនុវត្តភារកិច្ចរបស់ខ្លួន។

ទស្សនាទាន និងនិយមន័យដែលបានអនុវត្តក្នុងដំណើរការធ្វើជំរឿនកសិកម្មនេះ ត្រូវបានរៀបចំឡើងដោយអនុលោមតាមឯកសារណែនាំរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) និងអនុលោមតាមវិធីសាស្ត្របច្ចេកទេសនៃជំរឿនកសិកម្មពិភពលោកឆ្នាំ២០២០ (WCA2020)។ ការរក្សាក្នុងទិដ្ឋភាពតម្រូវការរបស់ជាតិ និងការប្រៀបធៀបដែលមានលក្ខណៈអន្តរជាតិ ការផ្លាស់ប្តូរមួយចំនួនត្រូវបានស្វែងយល់អំពីសារៈសំខាន់សម្រាប់ការ

បកស្រាយប្រកបដោយអត្ថន័យ និងភាពងាយស្រួលនៃប្រតិបត្តិការជំរឿនកសិកម្មលើកនេះ។

គុណភាពនៃការប្រមូលទិន្នន័យ គឺអាស្រ័យលើការយកចិត្តទុកដាក់ជាពិសេសចំពោះផ្តោតលើកត្តាសំខាន់គឺ៖

- វិធីសាស្ត្របច្ចេកទេស
- ការរៀបចំដំណើរការអនុវត្តជំរឿន
- ការរៀបចំ និងអនុវត្តការសម្ភាសប្រមូលទិន្នន័យ

គុណភាពនៃទិន្នន័យស្ថិតិមានមួយផ្នែកធំ វាអាស្រ័យទៅលើការរៀបចំធ្វើផែនការ វិធីសាស្ត្រ និងការគ្រប់គ្រងកំហុសឆ្គង ឬកម្រិតលម្អៀងស្ថិតិ។ គុណភាពនៃទិន្នន័យអាចត្រូវបានវាយតម្លៃតាមរយៈការពិនិត្យភាពត្រឹមត្រូវ និងភាពជឿជាក់នៃទិន្នន័យដែលបានប្រមូល។ កំណត់សម្គាល់នេះ ដើម្បីបង្ហាញអំពីព័ត៌មានទាក់ទងនឹងទិដ្ឋភាពទាំងអស់នៅក្នុងការធ្វើជំរឿនកសិកម្មនៅឆ្នាំ២០២៣ រួមជាមួយនឹងការវិភាគសង្ខេបអំពីភាពត្រឹមត្រូវ និងភាពជឿជាក់នៃទិន្នន័យដែលបានប្រមូល។

## ៩.២- គោលបំណង

គោលបំណងសំខាន់នៃជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ គឺដើម្បីផ្តល់ទិន្នន័យស្តីពីស្ថានភាពកសិកម្មនៅក្នុងប្រទេស ដែលនឹងត្រូវបានប្រើប្រាស់ដោយអ្នករៀបចំផែនការយុទ្ធសាស្ត្រ កម្មវិធីអភិវឌ្ឍន៍ និងអ្នកធ្វើគោលនយោបាយនានា។ ជាពិសេសទិន្នន័យជំរឿននឹងមានប្រយោជន៍យ៉ាងសំខាន់គឺ៖

- ការផ្តល់ទិន្នន័យកសិកម្មនៅអង្គភាពរដ្ឋបាលដែលមានកម្រិតតូចជាងគេបំផុតនៅក្នុងប្រទេស
- ការផ្តល់ទិន្នន័យអំពីរចនាសម្ព័ន្ធនៃអង្គភាពកសិកម្ម និងសកម្មភាពដាំដុះដំណាំការចិញ្ចឹមសត្វ និងបសុបក្សីនៅក្នុងប្រទេស។
- ការផ្តល់ក្របខ័ណ្ឌជ្រើសរើសសំណាកគំរូក្នុងការធ្វើអង្កេតកសិកម្ម

## ៩.៣- វិសាលភាពការធ្វើជំរឿន

ជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ ត្រូវបានធ្វើដោយប្រើប្រាស់

តារាងសំណួរមានចំនួន៤ទម្រង់ ដើម្បីប្រមូលទិន្នន័យ៖ (១) ទម្រង់សំណួរភូមិ ដែលផ្តោតលើការសម្ភាសមេភូមិរាល់ភូមិទាំងអស់នៅប្រទេសកម្ពុជាក្នុងតំបន់ដែលបានជ្រើសរើស (២) ទម្រង់ចុះបញ្ជីគ្រួសារដែលសម្ភាសន៍គ្រប់គ្រួសារនៅក្នុងប្រទេសកម្ពុជា និងនៅក្នុងតំបន់ជំរឿន ដើម្បីកំណត់ថាតើគ្រួសារណាកំពុងធ្វើសកម្មភាពកសិកម្ម (៣) ទម្រង់សំណួរគ្រួសារកសិកម្ម ដែលប្រមូលព័ត៌មានពេញលេញអំពីគ្រួសារកាន់កាប់កសិកម្មដែលកំពុងធ្វើសកម្មភាពកសិកម្ម និង (៤) ទម្រង់សំណួរសម្រាប់គ្រឹះស្ថានសហគ្រាសកសិកម្មខ្នាតធំ (មិនមែនគ្រួសារ)។ ទម្រង់សំណួរទាំងនេះអាចរកបាននៅលើគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ។

វិសាលភាពនៃតារាងសំណួរតាមទម្រង់នីមួយៗ មានដូចខាងក្រោម៖

- **ទម្រង់១**- ព័ត៌មានភូមិរួមមាន ប្រភេទដី គ្រោះធម្មជាតិ/គ្រោះមហន្តរាយនៅក្នុងរយៈពេល ៥ឆ្នាំកន្លងមក សកម្មភាពសេដ្ឋកិច្ចដែលមានរយៈពេលដាំដុះដំណាំ ឧបករណ៍/គ្រឿងយន្ត/គ្រឿងបរិក្ខារកសិកម្ម មធ្យោបាយដឹកជញ្ជូន សាលារៀន មធ្យោបាយទំនាក់ទំនង ការថែទាំសុខភាព ការប្រើប្រាស់ទឹក ស្ថានភាពផ្លូវថ្នល់ និងទីផ្សារ វត្តមានសមាគមប្រជាជន វត្តមានអង្គការក្រៅរដ្ឋាភិបាល ជនជាតិដើមភាគតិច/ជនជាតិផ្សេងៗ និងជំនឿសាសនា។
- **ទម្រង់២**- តារាងចុះបញ្ជីគ្រួសារ រួមមានប្រមូលព័ត៌មានភូមិសាស្ត្រដែលគ្រួសារនីមួយៗ ដែលបានរកឃើញ និងព័ត៌មានទាក់ទងនឹងគ្រួសារធ្វើសកម្មភាពកសិកម្ម ចំនួនសត្វចិញ្ចឹម ភេទ និងចំនួនសមាជិកគ្រួសារ។
- **ទម្រង់៣ និងទម្រង់៤**- ព័ត៌មានមូលដ្ឋានទាក់ទងនឹងគ្រួសារកាន់កាប់កសិកម្ម (ទម្រង់៣) និងគ្រឹះស្ថានសហគ្រាសកសិកម្មខ្នាតធំ (ទម្រង់៤) រួមមានទីតាំងភូមិសាស្ត្រនៃគ្រួសារកាន់កាប់កសិកម្ម ឈ្មោះ ភេទ និងអាយុរបស់ម្ចាស់កសិដ្ឋាន ព័ត៌មានគ្រួសាររបស់ម្ចាស់កសិដ្ឋាន ភាពស្របច្បាប់របស់ម្ចាស់កសិដ្ឋាន ទំហំ និងចំនួនក្បាលដីដែលបានកាន់កាប់ ទីតាំងផ្ទៃដីជាក់ស្តែង ការប្រើប្រាស់ដីជាចម្បង និងស្ថានភាពនៃក្បាលដីនីមួយៗ ក្នុងកសិដ្ឋានព្រៃឈើ និងដីព្រៃផ្សេងទៀត ការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ ដំណាំដាំដុះរយៈពេលខ្លី និងដំណាំរយៈពេលវែង គោលបំណងចម្បងនៃផលិតកម្ម បសុសត្វ/បសុបក្សីដែលបានចិញ្ចឹមក្នុងកសិដ្ឋាន ការធ្វើវារីវប្បកម្ម ការកែច្នៃផលិតផលកសិកម្ម កម្លាំងពលកម្មដែលប្រើប្រាស់ដោយកសិដ្ឋាន គ្រឿងយន្ត និងឧបករណ៍ប្រើប្រាស់ និងឥណទាន និងប្រាក់កម្ចី។

គ្រួសារកាន់កាប់កសិកម្មទាំងអស់នៅប្រទេសកម្ពុជា (លើកលែងតែគ្រួសារមួយចំនួននៅក្នុងតំបន់ដែលមិនត្រូវបានរាប់បញ្ចូល)ត្រូវបានសម្ភាសន៍នៅក្នុងដំណាក់កាលទី១ ដោយប្រើប្រាស់តារាងសំណួរទម្រង់២ ដើម្បីកំណត់អត្តសញ្ញាណគ្រួសារចូលរួមក្នុងវិស័យកសិកម្ម (ឬគ្រួសារកាន់កាប់កសិកម្ម)។ ក្នុងករណីដែលគ្រួសារនោះត្រូវបានចូលរួមក្នុងសកម្មភាពធ្វើកសិកម្ម ហើយនិងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដោយផ្អែកលើនិយមន័យនៃគ្រួសារកាន់កាប់កសិកម្ម (អង្គភាពកសិកម្ម) គ្រួសារកាន់កាប់កសិកម្មនោះ ត្រូវបានសម្ភាសន៍ដោយប្រើប្រាស់តារាងសំណួរទម្រង់៣។

## ៩.៤- វិសាលភាពគ្របដណ្តប់ទីតាំងភូមិសាស្ត្រ

គ្រួសារកាន់កាប់កសិកម្មទាំងអស់នៅទូទាំងប្រទេសកម្ពុជា លើកលែងតែខណ្ឌមួយចំនួននៅក្នុងរាជធានីភ្នំពេញ និងភូមិដែលមានគ្រួសារកាន់កាប់កសិកម្មមានតិចជាងចំនួន៥គ្រួសារ ដែលមាននៅក្នុងទិន្នន័យជំរឿនទូទៅប្រជាជនកម្ពុជាឆ្នាំ២០១៩ ដែលត្រូវបានចាត់ទុកថាជាតំបន់ស្នូលទីក្រុង ត្រូវបានគ្របដណ្តប់នៅក្នុងជំរឿនកសិកម្មនៅឆ្នាំ២០២៣ នេះ។ លើសពីនេះ គ្រឹះស្ថានកសិកម្មខ្នាតធំដែលប្រតិបត្តិការដោយក្រុមហ៊ុន សហករណ៍ ស្ថាប័នរដ្ឋាភិបាល និងស្ថាប័នឯកជន ដែលហៅថា "ដីកសិកម្មគតិយុត្ត" ត្រូវបានកត់ត្រាដាច់ដោយឡែកនៅក្នុងផ្នែកសហគ្រាសខ្នាតធំ ដែលវាមិនមែនជាគ្រួសារកាន់កាប់កសិកម្ម (ទម្រង់៤)។

## ៩.៥- ពេលវេលាជំរឿន និង រយៈពេលយោង

ជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ ត្រូវបានអនុវត្តជាពីរដំណាក់កាលបន្តបន្ទាប់គ្នាភ្លាមៗ (១) ការសម្ភាសមេភូមិ (ទម្រង់១) និងការចុះបញ្ជីគ្រប់គ្រួសារទាំងអស់នៅក្នុងភូមិនៅទូទាំងប្រទេសកម្ពុជា (ទម្រង់២) ត្រូវបានធ្វើឡើងក្នុងរយៈពេល១០ថ្ងៃ ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣។ បន្ទាប់ពីនេះ ការសម្ភាសគ្រួសារកាន់កាប់កសិកម្ម និងគ្រឹះស្ថានសហគ្រាសកសិកម្មខ្នាតធំប្រើប្រាស់ទម្រង់៣ និងទម្រង់៤ ដែលត្រូវបានអនុវត្តចាប់ពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៣។ ការពន្យាបន្តិចនៃរយៈពេលចុះបញ្ជី ជាមួយនឹងរយៈពេលនៃការធ្វើជំរឿននេះ ដោយសារតំបន់ខ្លះមានដំណើរការយឺតជាងតំបន់ផ្សេងទៀត តែផ្នែកខ្លះមានបញ្ហាក្នុងដំណើរការអនុវត្តដោយសារមានភ្លៀងធ្លាក់ខ្លាំង និងបញ្ហាលំបាកក្នុងការធ្វើដំណើររបស់មន្ត្រីជំរឿន ជាពិសេសនៅតំបន់ភ្នំនិងតំបន់ឆ្ងាយៗដាច់ស្រយាល។

ជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ បានប្រើប្រាស់រយៈពេលយោងសម្រាប់១២ខែកន្លងមក ដោយគិតនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣ ជាកាលបរិច្ឆេទយោង (ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣)។ ទោះបីជាយ៉ាងណា រយៈពេលយោងសម្រាប់ធាតុមួយចំនួន គឺខុសពីរយៈពេលដែលបានបញ្ជាក់ខាងលើ ដូចដែលបានបង្ហាញពីការបែងចែកទិន្នន័យផ្សេងៗ នៅក្នុងកម្រងសំណួរនីមួយៗ។

## ៩.៦- វិធីសាស្ត្របច្ចេកទេស នៃការធ្វើជំរឿនកសិកម្ម

ជំរឿនកសិកម្មនៅឆ្នាំ២០២៣ទាំងអស់ ត្រូវបានប្រមូលទិន្នន័យដោយប្រើប្រាស់តាមវិធីសាស្ត្រ ឃើញរាប់ (De-facto)។ ក្រុមមន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យដែលបានទទួលការបណ្តុះបណ្តាលរួច ត្រូវបានចាត់ឱ្យចុះធ្វើការសម្ភាសដោយផ្ទាល់នៅតាមគោលដៅមណ្ឌលជំរឿនដែលត្រូវសម្ភាសន៍ជាមួយនិងសមាជិកដែលមានសិទ្ធិនៃគ្រួសារកាន់កាប់កសិកម្ម ឬកសិដ្ឋាន។ អ្នកឆ្លើតបការសម្ភាស គឺជាសមាជិកពេញវ័យ (អាយុ ១៨ ឆ្នាំឡើង) នៃគ្រួសារដែលគួរតែបានដឹងអំពីសកម្មភាពកាន់កាប់កសិកម្ម។ អ្នកឆ្លើយតបការសម្ភាសដែលត្រូវលក្ខខណ្ឌល្អបំផុតគឺម្ចាស់អង្គភាពកសិកម្ម ឬកសិដ្ឋាន។ ទោះយ៉ាងណាក៏ដោយនៅពេលដែលម្ចាស់កសិដ្ឋានអវត្តមាន អ្នកតំណាងជាប្តី/ប្រពន្ធ ឬកូនប្រុស ឬកូនស្រីណាម្នាក់ដែលមានអាយុ១៨ឆ្នាំឡើង ក៏អាចជាអ្នកឆ្លើយតបការសម្ភាសនេះផងដែរ។ គ្មានសមាជិកគ្រួសារដែលមានអាយុក្រោម ១៨ឆ្នាំ ឬអ្នកជិតខាង ឬគ្រួសារដទៃផ្សេងទៀត ត្រូវបានអនុញ្ញាតឱ្យធ្វើការសម្ភាសជំនួស ឬសុំព័ត៌មាននៃគ្រួសារកាន់កាប់កសិកម្មដែលបានជំរឿនកសិកម្មនោះទេ។

ជំរឿនកសិកម្មនៅឆ្នាំ២០២៣ ត្រូវបានសម្ភាសន៍ប្រមូលទិន្នន័យដោយប្រើប្រាស់កម្រងសំណួរដែលមានរចនាសម្ព័ន្ធ ស្តង់ដារបច្ចេកទេស ដែលមានការណែនាំនៅក្នុងឯកសារណែនាំមន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យ ដែលផ្តល់នូវគោលគំនិតលម្អិត និយមន័យ និងវិធីសាស្ត្រដែលត្រូវបានអនុវត្ត ដើម្បីប្រមូលទិន្នន័យកសិកម្មនីមួយៗ។ តារាងសំណួរ និងសៀវភៅណែនាំមន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យ ត្រូវបានរៀបចំឡើងដោយផ្អែកលើអនុសាសន៍របស់ក្រុមការងារបច្ចេកទេស និងសិក្ខាសាលាអំពីអ្នកប្រើប្រាស់ និងអ្នកផលិត។ កម្រងសំណួរជំរឿន និងសៀវភៅណែនាំមន្ត្រីសម្ភាសន៍ត្រូវបានកែលម្អ និងបញ្ចប់ ដោយផ្អែកលើលទ្ធផលនៃការធ្វើជំរឿនសាកល្បង និងបទពិសោធន៍ដែលបានទទួលនៅក្នុងកំលុងពេលអនុវត្តន៍សាកល្បង។ សៀវភៅណែនាំសម្រាប់មន្ត្រីសម្ភាសន៍ត្រូវបានបំពេញបន្ថែមដោយការត្រួតពិនិត្យជាកញ្ចប់លើភាពស៊ីសង្វាក់នៃទិន្នន័យដែលប្រមូលបានពីមូលដ្ឋាន ដំណាក់កាលបញ្ចូលទិន្នន័យ និងនៅក្នុង

ដំណើរការផ្ទៀងផ្ទាត់ទិន្នន័យជាបន្តបន្ទាប់។

## ៩.៧- ផែនការឃោសនាផ្សព្វផ្សាយ

មុនពេលការចុះប្រមូលទិន្នន័យបានចាប់ផ្តើម ការឃោសនាផ្សព្វផ្សាយជំរឿន ត្រូវបានធ្វើឡើងដើម្បីទទួលបានការគាំទ្រ និងកិច្ចសហការពីគ្រួសារកាន់កាប់កសិកម្ម និងមិនមែនគ្រួសារទាំងអស់នៅទូទាំងប្រទេសដែលបានចូលរួមនៅក្នុងសកម្មភាពកសិកម្ម ដើម្បីទទួលបានការគាំទ្រ និងកិច្ចសហប្រតិបត្តិការ ព្រមទាំងថ្នាក់ដឹកនាំភូមិក្នុងការផ្តល់ព័ត៌មាន។ ការផ្សព្វផ្សាយនេះជាការកាត់បន្ថយបន្ទុករបស់អ្នកឆ្លើយតបដោយប្រយោលក្នុងការផ្តល់ព័ត៌មាន។

យុទ្ធនាការឃោសនាបង្កើនការយល់ដឹង ត្រូវបានធ្វើតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានាដូចជាទូរទស្សន៍ វិទ្យុ បណ្តាញសង្គម ការប្រើប្រាស់បដារ ប័ណ្ណប្រកាស ផ្ទាំងរូបភាព ការបោះពុម្ពនៅលើថង់ អាវយឺត និងមួកត្រូវបានប្រើប្រាស់ក្នុងការធ្វើជំរឿន និងអង្កេត។ ខិត្តប័ណ្ណ និងអត្ថបទនិពន្ធខ្លីៗ ត្រូវបានរៀបចំដោយមានសេចក្តីពន្យល់ដូចជា "តើជំរឿនកសិកម្មនៅកម្ពុជា គឺជាអ្វី?" "តើស្ថាប័នណាមួយដែលទទួលខុសត្រូវធ្វើជំរឿនកសិកម្មនៅក្នុងប្រទេសកម្ពុជា? "តើជំរឿនកសិកម្មនៅក្នុងប្រទេសកម្ពុជាមានសារៈសំខាន់ដូចម្តេចដែរ? "ឯកសារជំរឿនកសិកម្មទាំងនេះគឺអាចរកបាននៅលើគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។

## ៩.៨- ដំណើរការចុះប្រមូលទិន្នន័យជំរឿនកសិកម្ម

ការចុះប្រតិបត្តិការប្រមូលទិន្នន័យត្រូវបានធ្វើឡើងជាបីដំណាក់កាលគឺ៖

- ការរៀបចំ និងផែនការប្រតិបត្តិ
- ការប្រមូល និងដំណើរការបញ្ជូនទិន្នន័យ ឧទាហរណ៍ការត្រួតពិនិត្យភាពពេញលេញ ការអនុវត្តការត្រួតពិនិត្យភាពអាចជឿជាក់បាន ចាប់ផ្តើមរម្លឹកពីវិធីសាស្ត្របច្ចេកទេស ឬនីតិវិធីអនុវត្ត។
- ការរៀបចំសម្អាត និងវិភាគទិន្នន័យក្នុងទម្រង់ជាតារាង និងក្រាហ្វិច ការបោះពុម្ពលទ្ធផលនៅក្នុងការបោះពុម្ពផ្សាយជាច្រើន ការរៀបចំ និងបង្ហាញការប្រើប្រាស់ទិន្នន័យជាសាធារណៈ។

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ សហការជាមួយនិងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ មានភារកិច្ចក្នុងការអនុវត្តជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣។

ក្រុមអ្នកឯកទេស ត្រូវបានគាំទ្រដោយអ្នកជំនាញការរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO)។ គណៈកម្មាធិការជាតិសម្រាប់ជំរឿនកសិកម្មនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងផែនការ ជាមួយនឹងតំណាងពីក្រសួងផ្សេងៗជាសមាជិកនៃគណៈកម្មាធិការ។ គណៈកម្មាធិការនេះ មានការគាំទ្រផ្នែកបច្ចេកទេសដោយគណៈកម្មាធិការបច្ចេកទេសស្តីពីជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ ដឹកនាំដោយរដ្ឋលេខាធិការនៃក្រសួងផែនការ។ ប្រធានទីប្រឹក្សាបច្ចេកទេសនៃអង្គការ FAO ត្រូវបានចូលរួមផ្តល់ធាតុចូលបច្ចេកទេសទាំងអស់ដល់គណៈកម្មាធិការបច្ចេកកទេសជំរឿនកសិកម្ម។ ក្រៅពីនេះ មានគណៈកម្មាធិការចំនួនពីរទៀត ដែលត្រូវបានបង្កើតឡើង៖ (១) ក្រុមប្រឹក្សាភិបាលស្ថិតិសម្រាប់កំណត់គោលនយោបាយស្ថិតិផ្លូវការ កំណត់អាទិភាពស្ថិតិ និងតម្រូវការដែលត្រូវដោះស្រាយដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង។ ការកំណត់កាលបរិច្ឆេទនៃការធ្វើជំរឿនប្រជាជន ជំរឿនកសិកម្ម និងជំរឿនសេដ្ឋកិច្ច (២) គណៈកម្មការជំរឿនកសិកម្មនៅរាជធានី ខេត្តឆ្នាំ២០២៣ សម្រាប់កិច្ចសហប្រតិបត្តិការជាមួយគណៈកម្មាធិការបច្ចេកទេសជំរឿនកសិកម្ម ដើម្បីរៀបចំឯកសារ សម្ភារៈ បរិក្ខារទាំងអស់ និងរៀបចំអនុវត្តកម្មវិធីបណ្តុះបណ្តាលមន្ត្រីជំរឿន។ ការធ្វើប្រតិបត្តិការជំរឿនជាមួយថ្នាក់ក្រោមជាតិមានគណៈកម្មាធិការជំរឿនកសិកម្មរាជធានី ខេត្តដែលដឹកនាំដោយប្រធានមន្ទីរផែនការរាជធានី ខេត្ត ដែលបង្កើតឡើងដោយប្រកាសរបស់ក្រសួងផែនការ ដើម្បីសម្របសម្រួលរាល់សកម្មភាពក្នុងស្រុក ឃុំ និងភូមិ ដើម្បីរៀបចំឯកសារទាំងអស់។ លើសពីនេះ ក៏មានចំនួនមន្ត្រីត្រួតពិនិត្យ និងមន្ត្រីសម្ភាសន៍ជាច្រើនដែលបានចូលរួមក្នុងដំណើរការប្រមូលទិន្នន័យ និងត្រួតពិនិត្យ។

រដ្ឋបាលថ្នាក់ថ្នាក់ក្រោមជាតិ ឃុំ និងភូមិក្នុងរាជធានី ខេត្តនីមួយៗ ត្រូវបានផ្សារភ្ជាប់ជាមួយនឹងជំរឿនកសិកម្ម។ អត្ថប្រយោជន៍នៃការចូលរួមជាមួយរដ្ឋាភិបាល រដ្ឋបាលថ្នាក់មូលដ្ឋានមេភូមិក្នុងការប្រមូលទិន្នន័យ ដោយសារគាត់បានស្គាល់ដោយផ្ទាល់ជាមួយអ្នកឆ្លើយតបការសម្ភាសសំណួរមួយចំនួន ហើយយល់ដឹងពីកាលៈទេសៈនៅក្នុងតំបន់ដែលជួយកែលម្អគុណភាពទិន្នន័យដោយប្រយោល។

ទម្រង់សំណួរចុះបញ្ជីគ្រួសារ (ទម្រង់២) នៃជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣ ត្រូវបានធ្វើចុះបញ្ជីគ្រួសារចំនួន ៣,៤ លានគ្រួសារ នៅក្នុងភូមិចំនួន ១៤ ២០១ ភូមិ។ ភូមិទាំងនេះមានស្ថិតក្នុងឃុំចំនួន ១ ៦៣៣ ស្រុកចំនួន ២០៦ នៅទូទាំង២៥ រាជធានី ខេត្ត ។ ការសម្ភាសត្រូវបានធ្វើឡើងដោយមន្ត្រីសម្ភាសន៍តាមរយៈការបណ្តុះបណ្តាលនៅរាជធានី ខេត្ត ហើយមន្ត្រី

សម្ភាសន៍ត្រូវបានជ្រើសរើសដោយប្រធានមន្ទីរផែនការរាជធានី ខេត្ត និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅរាជធានី ខេត្តរៀងៗខ្លួន ដោយផ្អែកតាមចំនួនកំណត់។

ប្រតិបត្តិការនេះរួមមានការបណ្តុះបណ្តាលមន្ត្រីត្រួតពិនិត្យ និងមន្ត្រីសម្ភាសន៍ ជាមួយគ្នា មុននឹងធ្វើការចុះប្រមូលទិន្នន័យ និងការត្រួតពិនិត្យ។ មន្ត្រីថ្នាក់កណ្តាលជាមន្ត្រីមកពីវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ត្រីត្រួតពិនិត្យ និងមន្ត្រីសម្ភាសន៍ ដែលបានជ្រើសរើសមានចំនួនសរុប ៦ ០០០ នាក់ ត្រូវបានបណ្តុះបណ្តាលតាមកម្រិតមុនពេលពួកគេធ្វើការចុះប្រមូលនិងត្រួតពិនិត្យទិន្នន័យ។ ការបណ្តុះបណ្តាលមានចំនួនពីរកម្រិត ដែលត្រូវបានធ្វើឡើងដាច់ដោយឡែកពីគ្នា។ វគ្គបណ្តុះបណ្តាលមានពីរកម្រិតៈ (ក) វគ្គបណ្តុះបណ្តាលគ្រូបង្គោល ដែលរួមមានមន្ត្រីការិយាល័យកណ្តាលនៃវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ មន្ត្រីមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរខេត្ត ឬតំណាង។ (ខ) ការបណ្តុះបណ្តាលមន្ត្រីត្រួតពិនិត្យ និងមន្ត្រីសម្ភាសន៍ ជាមន្ត្រីថ្នាក់ក្រោមជាតិមកពីមន្ទីរផែនការ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត។ មន្ត្រីជំនាញទាំងអស់រួមទាំងមន្ត្រីត្រួតពិនិត្យគ្រប់លំដាប់ថ្នាក់ ត្រូវបានបណ្តុះបណ្តាលយ៉ាងទូលំទូលាយលើគោលគំនិតនិយមន័យ និងនីតិវិធីសម្រាប់ការប្រមូលទិន្នន័យ។

ការប្រមូលទិន្នន័យសម្រាប់គ្រួសារកាន់កាប់កសិកម្មដោយប្រើប្រាស់កម្រងសំណួរលម្អិត (ទម្រង់៣) ត្រូវបានប្រមូលទិន្នន័យពីគ្រួសារចំនួនជាង ១,៨ លានគ្រួសារ ដែលបានកំណត់សម្រាប់គ្រួសារកាន់កាប់កសិកម្ម។ កម្រងសំណួរភូមិ (ទម្រង់១) ក៏ត្រូវបានសម្ភាសន៍មេភូមិនៅគ្រប់ភូមិផងដែរ ក្នុងអំឡុងប្រតិបត្តិការធ្វើជំរឿននេះ។

ភាពត្រឹមត្រូវលទ្ធផលចុងក្រោយនៃជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ អាស្រ័យលើគុណភាពនៃការប្រមូលទិន្នន័យពីគ្រួសារដែលត្រូវបានចុះក្នុងបញ្ជីគ្រួសារ និងបានសម្ភាសន៍ប្រមូលទិន្នន័យ។ ទោះបីជាការបណ្តុះបណ្តាល ត្រូវបានអនុវត្តប្រកបដោយជំនាញ និងយកចិត្តទុកដាក់លើដំណើរការទិន្នន័យ ត្រូវបានអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាពក៏ដោយ ប្រសិនបើការត្រួតពិនិត្យគុណភាពមិនគ្រប់គ្រាន់ត្រូវបានអនុវត្តក្នុងអំឡុងពេលប្រមូលទិន្នន័យនោះទេ ទិន្នន័យចុងក្រោយគឺនៅតែមានគុណភាពមិនល្អដែរ។ យើងមានអ្នកត្រួតពិនិត្យជាច្រើនកម្រិតនៅក្នុងដំណើរការជំរឿនកសិកម្ម និងបណ្តាញទំនាក់ទំនងមានសរសេរយ៉ាងលម្អិតនៅក្នុងសៀវភៅណែនាំរបស់មន្ត្រីត្រួតពិនិត្យ។ ឋានានុក្រមរួមជាមួយនឹងគោលការណ៍ណែនាំដាច់ដោយឡែកមួយត្រូវបានរៀបចំសម្រាប់អ្នកត្រួតពិនិត្យជំរឿនថ្នាក់ខេត្ត និងក្រុមអ្នកត្រួតពិនិត្យ

ការវិលេចសកម្មភាព និងនីតិវិធីនៃការត្រួតពិនិត្យគុណភាពផ្សេងៗគ្នា ដើម្បីតាមដានវឌ្ឍនភាពនៃការចុះបញ្ជីគ្រួសារ និងដំណើរការប្រមូលទិន្នន័យជំរឿនកសិកម្មឱ្យបានត្រឹមត្រូវ និងការរកឃើញអំពីបញ្ហាណាមួយនៅក្នុងការប្រមូលទិន្នន័យជាមុន។

## ៩.៩- ដំណើរការប្រព្រឹត្តកម្មទិន្នន័យ

